ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jan-2017, 14:50
CMS/CFO: Sann Rada

# **កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**
# **ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤៥៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោកស្រី ស្តាវរូឡា ប៉ាប៉ាដូពូឡូស
*(Ms.Stavroula PAPADOPOULOS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆរ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោកស្រី ដូរីន ជិន *(Ms. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី មុំ វុន (2-TCCP-283) | ខ្មែរ |
| លោក សែម អំ (2-TCW-1031) | ខ្មែរ |

# ខ្លឹមសារឡើង

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី មុំ ធុន** (2-TCCP-283)


សួរបន្តដោយលោក លីវ សុវណ្ណា ផ្តើមពី .................................................................. ទំព័រ ៣

សួរដោយលោកស្រី ដូរីន ជិន ផ្តើមពី ....................................................................... ទំព័រ ១០


**ការសួរសំណួរទៅសាក្សី៖ លោក សែម អ៊ំ** (2-TCW-1031)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ............................................................................ ទំព័រ ២០

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................................................ ទំព័រ ២៣

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ..................................................................... ទំព័រ ៦២

01375173



# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បញ្ចប់ ហើយនិងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1031 ពាក់ព័ន្ធនឹងអង្គហេតុការបោសសម្អាតផ្ទៃក្នុង។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ាយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោកស្រី ម៉ារី ហ្គីរ៉ូដ៍ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយគ្មានមូលហេតុ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា មានបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺលោកស្រី មុំ វុន លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ នៅថ្ងៃនេះដែរមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-1031។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺ លោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាព្រឹកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ឯម ហ៊ាយ។ ជាដំបូង អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦នេះ។

[០៩:០៣:០៣]

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះ មានការចុកចាប់ពេលអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៤:១២]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ឲ្យចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់សវនាការថ្ងៃនេះ។

ជាបន្តទៅទៀត អង្គជំនុំជម្រះសូមផ្ដល់វេទិកាដល់មេធាវីការពារក្ដីលោក នួន ជា ដើម្បីបន្តតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន។ សូមរំឭកថា មេធាវីការពារក្ដីទាំងពីរក្រុមនៅសល់ពេល

វេលាមួយវគ្គកន្លះទៀត។ សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោក លីវ សុវណ្ណា៖**

សូមគោរពលោកប្រធាន ខ្ញុំបាទសូមគោរពលោក លោកស្រីចៅក្រម សូមគោរពភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរសាជាថ្មីចំពោះលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ លីវ សុវណ្ណា សូមបន្តសំណួរ។ ឥឡូវខ្ញុំចង់បញ្ជាក់ជូនលោកស្រីមួយ កាលពីថ្ងៃទី១៦ ខែ៩ ២០១៦ វេលាម៉ោង១១:១៣នាទី សូមទោស ម៉ោង១១:០៦នាទី លោកស្រីបានមានប្រសាសន៍ថា កូនលោកស្រីស្លាប់អស់បីនាក់មុនរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយនៅម៉ោង១៣:៥៣នាទី លោកស្រីបានឆ្លើយថា កូនលោកស្រីបានស្លាប់ពីរនាក់ទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកនៅម៉ោង១៥:៣៧នាទី លោកស្រីថា កូនលោកស្រីបានកើតនៅឆ្នាំពីរពាន់ -- នៅឆ្នាំ១៩៨២ ចំនួនពីរនាក់ ហើយបានស្លាប់ទៅ។ អ៊ីចឹងសំណួរខ្ញុំសួរថា ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ក្រៅពីកូនដែលកើតពីឆ្នាំ៨២ កូនភ្លោះកើតឆ្នាំ៨២ ដែលស្លាប់ទៅហ្នឹង មានកូនណាទៀត ផ្សេងទៀតបានស្លាប់ក្នុងអំឡុងពេលក្រោយកម្ពុជាប្រជាធិបតេយ្យដែរទេ?

[០៩:០៦:៣០]

**លោកស្រី មុំ វុន៖**

**ឆ៖** ក្រោយប្រជាធិបតេយ្យនេះ គឺកូនខ្ញុំនៅក្នុងឆ្នាំ៧៩ហ្នឹងបានស្លាប់បួននាក់ទៀត។ ស្លាប់អស់បួននាក់ហ្នឹង គឺស្លាប់ក្រោយ៧៩។ មានតែប៉ុណ្ណឹងទេ។

**ស៖** បាទ អរគុណលោកស្រី។ ឥឡូវចូលដល់ម្ដាយរបស់លោកស្រី នៅម៉ោងដប់ – នៅថ្ងៃទី១៦ ខែ៩ ២០១៦ ម៉ោង១១:១៣នាទី លោកស្រីបានថ្លែងថា ម្ដាយលោកស្រីបានឈឺស្លាប់ បន្ទាប់ពីគេហៅឪពុករបស់លោកស្រី និងបងប្អូនលោកស្រីបីនាក់ទៅរៀនសូត្រ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ តើគាត់ស្លាប់ហ្នឹងនៅពេលណា លោកស្រីចាំទេ? នៅអាចខែណា ឆ្នាំណា ឬក៏ប៉ុន្មានថ្ងៃ ប៉ុន្មានខែបន្ទាប់ពីបាត់ឪពុកលោកស្រី?

**ឆ៖** ចាស ក្នុងឆ្នាំ៧៥ហ្នឹង ឪពុកខ្ញុំស្លាប់។ ឪពុកខ្ញុំគេយកទៅរៀនសូត្រ ហើយក៏ស្លាប់ទៅ។ ហើយម្យ៉ាងទៀត ដល់ម្ដាយខ្ញុំហ្នឹង គាត់កន្លងមកគាត់បានឈឺៗរីងៗហើយ ក៏ស្លាប់ទៅជាមួយគ្នាក្នុងឆ្នាំ

៧៥ហ្នឹងដែរ ចុងឆ្នាំ។

**ស៖** លោកស្រីអាចចងចាំបានទេ ចុងឆ្នាំ៧៥ តើក្នុងអំឡុងខែណាដែរ លោកស្រី?

**ឆ៖** ចាំអត់បាន។ ដឹងថាក្នុងឆ្នាំ៧៥ហ្នឹង មិនដឹងថាខែប៉ុន្មានអីប៉ុន្មានទេ ខ្ញុំអត់ដឹងខែបារាំង ខែអីផង។ ដឹងតែស្លាប់ក្នុងឆ្នាំ៧៥ ចុងឆ្នាំ៧៥ហ្នឹង។

[០៩:០៨:៣០]

**ស៖** បាទ លោកស្រីបានថ្លែងថា លោកស្រីនៅម្នាក់ឯង អ៊ីចឹងក្រៅពីម្ដាយលោកស្រីស្លាប់ទៅ តើលោកស្រីមានម្ដាយណាផ្សេងទៀត ដូចជាម្ដាយក្មេក ឬម្ដាយសុំអីទេបាទ?

**ឆ៖** ខ្ញុំអត់មានម្ដាយក្មេកទេ។ ម្ដាយធំក៏អត់មានដែរ ព្រោះគាត់ចាស់ៗ គាត់ឈឺស្លាប់ដោយខ្លួនឯង។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់បញ្ជាក់ចំណុចមួយទាក់ទងនឹងកូនលោកស្រី។ នៅថ្ងៃទី១៦ ខែ៩ ២០១៦ លោកស្រីបាន នៅវេលាម៉ោងប្រហែល១៣:៥៣នាទី លោកស្រីបានថ្លែងថា កូនលោកស្រីបានស្លាប់ពីរនាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែបើសិនជាយើងពិនិត្យទៅលើឯកសារចម្លើយរបស់លោកស្រីនៅក្នុងឯកសារ E3/7235 ដែលមាន ERN ជាភាសាខ្មែរគឺ 0103 -- សូមទោស 0100 3348, ជាភាសាអង់គ្លេស 01074568, ជាភាសាបារាំង 01112077។ ក្នុងហ្នឹងលោកស្រីបានថ្លែង -- សំណួររបស់គណៈវិនិច្ឆ័យ គេសួរថា៖ “ចុះកូនដែលបានស្លាប់នោះ ពួកគាត់ស្លាប់នៅក្នុងរបបនោះ ឬក៏ពេលដែលចេញមកស្លាប់បន្តៗ?” ចម្លើយលោកស្រីឆ្លើយថា៖ “ស្លាប់បន្តៗ។ របប ប៉ុល ពត ស្លាប់អស់ប្រាំមួយនាក់ និងអត់បាយមហាវេទនា។” ចុះហេតុអីបានជាចម្លើយលោកស្រីកាលពីមុន លោកស្រីថាកូនរបស់លោកស្រីបានស្លាប់ក្នុងរបប ប៉ុល ពត ប្រាំមួយនាក់ ហើយលោកស្រីថ្លែងកាលពីថ្ងៃទី១៦ ខែ៩ ២០១៦ ថាកូនស្រីស្លាប់តែពីរនាក់ទៅវិញ?

[០៩:១០:៥៤]

**ឆ៖** ចាស សំណួរដែលឲ្យខ្ញុំឆ្លើយហ្នឹងគឺថា កូនខ្ញុំស្លាប់ក្នុងរបបខ្មែរក្រហមហ្នឹង គឺស្លាប់ពីរនាក់ស្លាប់បន្តបន្ទាប់គ្នា។ ប៉ុន្តែដល់ឆ្លើយច្រំដែលធ្វើយ៉ាងអ៊ីចឹង ខ្ញុំដូចជាបានជម្រាបមេធាវីខ្ញុំ ហើយនិងព្រះរាជអាជ្ញារួចអស់ ដូចជាពាក្យនេះ ដូចជាខ្ញុំថាអត់បានឆ្លើយទៀតទេ។

**ស៖** សូមទោសលោកស្រី ដោយសារឃើញចម្លើយដែលលោកស្រីឆ្លើយកាលពីថ្ងៃទី១៦ហ្នឹង វាផ្ទុយពីឯកសារដែលលោកស្រីឆ្លើយពីមុនៗ។ ដែលមុនលោកស្រីថា កូនលោកស្រីស្លាប់ៗក្នុងរបប ប៉ុល

ពត ហ្នឹងអស់ប្រាំមួយនាក់។ ដោយសារមានភាពផ្ទុយគ្នា បានខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់មើល ហេតុអីបានជាមានភាពផ្ទុយគ្នារវាងចម្លើយពីមុន និងចម្លើយដែលលោកស្រីបានឆ្លើយកាលពីថ្ងៃទី១៦ ខែ៩ ២០១៦ នៅក្នុងអង្គសវនាការនេះ?

**ឆ៖** ចាស ចម្លើយនេះដែលថា ឆ្លើយនៅស្លាប់ពីរនៅក្នុងរបបខ្មែរក្រហម ហើយប្អូននាក់ទៀតដែលបានស្លាប់ក្រោយ៧៩ហ្នឹង ពាក្យហ្នឹងឡូងគ្នាបណ្តោយ វាមិនមែនស្លាប់ទាំងអស់គ្នាក្នុងឆ្នាំនោះទេ។ វាឡូងពាក្យគ្នា ថាឆ្លើយមួយដែលក្រោយ៧៩ប្អូន ក្នុងរបបហ្នឹងពីរទៀត វាទៅជាប្រាំមួយ អាដល់អ៊ីចឹងវាឡូងពាក្យហ្នឹងទៅទាំងអស់តែម្តង។

[០៩:១២:២៤]

**ស៖** បាទ ឥឡូវចំណុចកាន់តែពិបាកយល់មួយទៀតគឺ អំមិញលោកស្រីបានឆ្លើយថា ម្តាយលោកស្រីបានស្លាប់នៅចុងឆ្នាំ៧៥។ ប៉ុន្តែបើពិនិត្យទៅលើឯកសារ E3/6307 ដែលជាឯកសារលោកស្រីបំពេញទម្រង់បែបបទក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី ដែលមាន ERN ជាភាសាខ្មែរគឺមានលេខ 00532025, ជាភាសាអង់គ្លេស 01168544, ជាភាសាបារាំង 01137823។ នៅក្នុងនេះខ្ញុំបាទសូមដកស្រង់៖ "ខែធ្នូ ឆ្នាំ១៩៧៧ គេបានបញ្ជូនខ្ញុំឲ្យទៅច្រូតស្រូវនៅភូមិទំព័រ -- ខែធ្នូ ឆ្នាំ១៩៧៦ គេបានបញ្ជូនខ្ញុំឲ្យទៅច្រូតស្រូវនៅភូមិទំព័រ ឃុំស្ពានត្នោត ស្រុកជីក្រែក ខេត្តសៀមរាប ទុកកូនឲ្យម្តាយមើលថែ ពេលនោះខ្ញុំឃើញយោធាខ្មែរក្រហម។" ចុះនៅក្នុងនេះ លោកស្រីបានបញ្ជាក់ថា នៅខែធ្នូ ឆ្នាំ៧៦ លោកស្រីបានទុកកូននៅម្តាយរបស់លោកស្រីឲ្យថែ។ អ៊ីចឹងចម្លើយឃើញថាវាផ្ទុយគ្នា ហើយនៅក្នុងឯកសារដែលលោកស្រីបានបំពេញទម្រង់បែបបទ គឺពុំមានបញ្ជាក់ថា ម្តាយលោកស្រីត្រូវស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងទេ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់លោកស្រីថា ហេតុអីបានជាចម្លើយលោកស្រីថាម្តាយលោកស្រីស្លាប់ចុងឆ្នាំ៧៥ ប៉ុន្តែឯកសារនេះបានបញ្ជាក់ថា ម្តាយរបស់លោកស្រីហ្នឹងរហូតដល់ឆ្នាំខែធ្នូ ឆ្នាំ១៩៧៦ គឺម្តាយលោកស្រីនៅរស់ ហើយលោកស្រីបានផ្ញើកូននៅម្តាយឲ្យជួយមើលថែទៀត?

**ឆ៖** ចាស នៅក្នុងដែលខ្ញុំផ្ញើកូននឹងម្តាយហ្នឹងគឺថា មិនមែនជាម្តាយយើងបង្កើតទេ ព្រោះយាយ ៗអ្នកដាំបន្លែ ម្ល៉ោះហើយគាត់ជាពុកម៉ែរបស់ក្មេងហ្នឹង។ កាលណាគេចល័តយើងទៅគ្រប់កន្លែង យើងត្រូវទុកកូននៅកន្លែងហ្នឹងឲ្យគាត់មើល គាត់ថែ។ ហើយម៉ែចេញទៅចល័តធ្វើការនៅខាងមុខ។ ទៅភូមិណាមិនថាភូមិណាទេ ឲ្យតែអង្គការត្រូវការគឺគេបញ្ជាយើងគឺត្រូវតែទៅ នៅអត់បានទេ មិនអាចប្រឆាំងនឹងបដិវត្តន៍បាន។ ម្ល៉ោះហើយខ្ញុំក៏ផ្ញើទុកនឹងពុកម៉ែនៅខាងក្រោយដែលគាត់នៅមើលថែ ព្រោះខ្ញុំអត់មាន

អ្នកណា ម៉ែឯណានឹងផ្ញើទេ គឺមានតែម៉ែៗដែលគាត់នៅថែរក្សានៅកន្លែងដាំបន្លែ ដាំអីហ្នឹង គាត់សម្រាប់មើលក្មេងហ្នឹងគឺ យកផ្ញើទុកនៅហ្នឹង។ ចំណែកម្ដាយខ្ញុំគឺស្លាប់មែន មានចម្លើយតែប៉ុណ្ណឹងទេ។

[០៩:១៥:១៣]

**ស៖** បាទ លោកស្រីដោយសារនៅក្នុងទម្រង់បែបបទអត់ឃើញការបញ្ជាក់ថា ម្ដាយលោកស្រីស្លាប់ ដូច្នេះបានវាមានមន្ទិលសង្ស័យ។ អ៊ីចឹងខ្ញុំសួរថាតើលោកស្រីហៅអ្នកយាយៗដែលមើលកូនហ្នឹង ហៅម៉ែៗអ៊ីចឹង ឬមួយក៏យ៉ាងម៉េចបាទ?

**ឆ៖** ចាស នៅក្នុងរបបនោះគឺអ្នកដែលមើលថែកូន គឺគេហៅម៉ែៗទាំងអស់ ពុកម៉ែ អ្នកនៅថែមើលកូនទាំងអស់ហ្នឹង គេហៅថាម៉ែៗ។ ហើយអ្នកម្ដាយៗដែលយើងចេញទៅធ្វើការងារហ្នឹង អាចទុកកូនចោលជាមួយនឹងម៉ែនោះឲ្យគាត់មើលថែ នឹងហើយបានថាហៅថាពាក្យ "ម៉ែ"។ ព្រោះរបបនោះគេហៅពុកម៉ែអើយ ពុកម៉ែខ្ញុំខំធ្វើស្រែបង្កបង្កើតផលដើម្បីពុកម៉ែ ហើយឲ្យម៉ែថែទាំមើលកូនឲ្យខ្ញុំ ហើយខ្ញុំចេញទៅមុខ ខ្ញុំចេញទៅចល័តធ្វើការសព្វបែបយ៉ាងទាំងអស់នៅក្នុងរបបនោះ។

**ស៖** បាទ ឥឡូវបើថាៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា លោកស្រីហៅយាយៗដែលមើលកូនថាម៉ែៗ។ អ៊ីចឹងឥឡូវនេះខ្ញុំដកស្រង់ឯកសារមួយទៀតគឺ ឯកសារលេខ E3/7234 ដែលមាន ERN ជាភាសាខ្មែរ 01003337, ជាភាសាអង់គ្លេស 01077097, បារាំង 01030452 ដែលជាចម្លើយរបស់លោកស្រីនៅក្នុងជាមួយអង្គការ ធី.ភី.អូ។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំក៏បានចែកផ្លូវគ្នាជាមួយគាត់នៅឆ្នាំ ១៩៨៤ ហើយក្នុងឆ្នាំដដែលនោះ ខ្ញុំបានទៅរកស៊ីនៅប្រទេសថៃ ដោយទុកកូនឲ្យនៅជាមួយម្ដាយ។" អ៊ីចឹងតើម្ដាយនេះនៅក្នុងឆ្នាំ៨៤ ដែលលោកស្រីក្រោយកម្ពុជាប្រជាធិបតេយ្យហើយ លោកស្រីទុកកូននៅម្ដាយនេះ ចុះលោកស្រីបកស្រាយថាម៉េចវិញ ម្ដាយលោកស្រីរហូតដល់ឆ្នាំ៨៤នេះ?

[០៩:១៧:១៨]

**ឆ៖** ចាស ដែលខ្ញុំផ្ញើកូនខ្ញុំជាមួយនឹងម្ដាយ ១ធម៌របស់ខ្ញុំនេះ ដែលខ្ញុំចេញទៅក្នុងប្រទេសថៃនេះ គឺខ្ញុំគ្មានបង្អែកអ្នកណាទៀតទេ គឺខ្ញុំផ្ញើកូននឹងម្ដាយធម៌របស់ខ្ញុំនៅបន្ទាយមានជ័យហ្នឹង ហើយខ្ញុំក៏ចូលទៅធ្វើការនៅស្រុកថៃទៅ ក្នុងឆ្នាំ៨៤ហ្នឹង។ ព្រោះខ្ញុំអត់មានអ្នកណាជាទីពឹងទេ មានតែម្ដាយធម៌ទេ អ្នកស្រុកទេដែលជាទីពឹងរបស់ខ្ញុំ ដែលខ្ញុំបានផ្ញើកូន ហើយខ្ញុំទៅស៊ីឈ្នួលគេដើម្បីយកប្រាក់មកទិញអង្ករហូបនៅក្នុងគ្រួសារខ្ញុំ។ នេះចម្លើយរបស់ខ្ញុំ។

**ស៖** បាទ ប៉ុន្តែមុននេះដែលខ្ញុំបានសួរសំណួរលោកស្រីថា ក្រៅពីម្ដាយបង្កើត មានម្ដាយក្មេក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម្ដាយធម៌អីឬក៏អត់ លោកស្រីបានឆ្លើយថាអត់មានទេ។ ដល់ឥឡូវលោកស្រីថាម្ដាយឆ្នាំ១៩៨៤គឺជាម្ដាយធម៌ទៅវិញ។ អ៊ីចឹងអំមិញលោកស្រីឆ្លើយថាអត់ អ៊ីចឹងអាហ្នឹងវាមានន័យម៉េចដែរលោកស្រី?

**ឆ៖** ចាស នៅក្នុងរបបខ្មែរក្រហម គឺខ្ញុំអត់មានម៉ែ អត់មានអំ អត់មានមាមីងមែន ប៉ុន្តែដល់ឆ្នាំ៨៤ ដែលវៀតណាមចូលមកហើយនេះ ខ្ញុំក៏បានដើររកស៊ីទៅតាមភូមិស្រុកគេ ហើយខ្ញុំក៏បានសួរនាំអ្នកស្រុក ហើយក៏ខ្ញុំសូមគេធ្វើជាម្ដាយធម៌ ហើយខ្ញុំនឹងអាចផ្ញើកូនខ្ញុំបាន ពឹងគេបានហើយខ្ញុំក៏បានផ្ញើ។ ខ្ញុំគ្មានអ្នកណាជាទីពឹងពិតប្រាកដមែន។

[០៩:១៨:៥៩]

**ស៖** បាទ ឥឡូវចូលដល់ប្ដីមុនរបស់លោកស្រី លោក តាន់ ហ៊ីង។ លោកស្រីបានឆ្លើយនៅក្នុងអង្គសវនាការកាលពីថ្ងៃ១៦ ខែ៩ ឆ្នាំ២០១៦ វេលាម៉ោងប្រហែល១១:១៣នាទី លោកស្រីបានឆ្លើយថា ប្ដីលោកស្រីគេហៅទៅរៀនសូត្រនៅពាក់កណ្ដាលឆ្នាំ១៩៧៥ ហើយបាត់ខ្លួនរហូត។ ប៉ុន្តែអ្វីដែលលោកស្រីឆ្លើយ គឺផ្ទុយពីទម្រង់បែបបទរបស់លោកស្រីដែលបានធ្វើគឺឯកសារ E3/6307 ដែលមានERN ជាភាសាខ្មែរគឺ 00532025, ជាភាសាអង់គ្លេស 01168544, ជាភាសាបារាំង 01137822។ ក្នុងហ្នឹងលោកស្រីបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "នៅខែតុលា ឆ្នាំ១៩៧៥ អង្គការខ្មែរក្រហមបានជម្លៀសខ្ញុំឱ្យទៅធ្វើជាកងចល័តនៅភ្នាវព្រំ ភូមិតាយ៉ុន ឃុំស្ពានត្នោត ស្រុកជីក្រែង បង្ខំឱ្យធ្វើការទាំងយប់ថ្ងៃ។ ពេលថ្ងៃច្រូត ពេលស្រូវ -- ពេលថ្ងៃច្រូតស្រូវ ពេលយប់ជីករណ្ដៅកប់ខ្មោច និងរែកដីម្នាក់៣ម៉ែត្រគូប ហូបបបររាវម្នាក់មួយចានចង្កេះប៉ុណ្ណោះ។ ហេវហត់ស្ទើរដួល តែមិនហ៊ានឈប់ទេ ខ្លាចគេសម្លាប់ចោល។ ចំណែកប្ដីខ្ញុំ គេឱ្យឡើងត្នោតនៅក្នុងភូមិ។" អ៊ីចឹងហេតុអីបានជាចម្លើយរបស់លោកស្រី ថាដល់រហូតដល់ខែតុលា ឆ្នាំ១៩៧៥ ប្ដីលោកស្រីកំពុងតែឡើងត្នោតនៅក្នុងភូមិរបស់លោកស្រី?

**ឆ៖** ចម្លើយនេះគឺឆ្នាំ១៩៧៥ ខ្ញុំទៅចល័តមែន។ ក្នុងឆ្នាំ១៩៧៥នេះ គេបានហៅប្ដីខ្ញុំទៅរៀនសូត្រ ហើយខ្ញុំនៅកងចល័ត។ តែហៅទៅហើយ ក៏ទៅបាត់រហូតទៅ មិនឃើញមកវិញ។ ហើយដល់រួចហើយ ខ្ញុំថាចុះទៅឯណា ក៏ទៅបាត់សូន្យ មិនឃើញវិលមកវិញ។ ក្នុងឆ្នាំ៧៥នោះ គាត់នៅឡើងត្នោតពិតប្រាកដនៅក្នុងសហករណ៍ មិនមែនទៅធ្វើការងារទេ គេឱ្យតែឡើងត្នោតទេ។ ដល់រួចហើយ គេហៅគាត់ទៅរៀននៅឆ្នាំ៧៥ហ្នឹង ពាក់កណ្ដាល៧៥ហ្នឹងឯង។

[០៩:២១:៤៧]

**ស៖** បាទ មិនថ្វីទេ ឥឡូវថាខែតុលា ឆ្នាំ៧៥ហ្នឹង ថាវាកៀកគ្នា។ អ៊ីចឹងឥឡូវចម្លើយរបស់លោក

ស្រី វាផ្ទុយពីអ្វីដែលមាននៅក្នុងឯកសាររបស់លោកស្រីនេះ។ នៅក្នុងឯកសារដដែលគឺ E3/6307 ដែលមានERN ជាភាសាខ្មែរគឺ 00532025, ជាភាសាអង់គ្លេសគឺមានលេខ 01168544, ជាភាសាបារាំងមានលេខ 01137823។ ខ្ញុំសូមដកស្រង់៖ “លុះខែមករា ឆ្នាំ១៩៧៧ គេបានបញ្ជូនខ្ញុំឲ្យមកធ្វើស្រែក្នុងភូមិវិញ ចំណែកប្ដីខ្ញុំ គេឲ្យឡើងក្នុងភូមិធម្មតា។” អ៊ីចឹងរហូតដល់ខែមករា ឆ្នាំ១៩៧៧ លោកស្រីឆ្លើយថា ប្ដីលោកស្រីគឺកំពុងតែឡើងត្នោតនៅក្នុងភូមិជាធម្មតា។ ហេតុអីបានជាវាផ្ទុយគ្នាពីចម្លើយដែលលោកស្រីឆ្លើយនៅក្នុងអង្គសវនាការនេះ?

**ឆ៖** ចាស ដែលគាត់បានឡើងត្នោតនេះ ក្នុង១៩៧៥ គាត់ឡើងត្នោតមែន។ តែក្នុងឆ្នាំ១៩៧៧ហ្នឹង គេដកខ្ញុំមកនៅស្ទូងក្នុងភូមិ។ តែទៅតាមការផ្ទុយ ដែលលោកសួរខ្ញុំច្រឡំដែរអ៊ីចឹង ខ្ញុំអត់ដឹងឆ្លើយថាម៉េចទេ ព្រោះឆ្នាំ១៩៧៥ គេហៅទៅ។ ឆ្នាំ១៩៦៧ -- ៧៧ គេហៅខ្ញុំមកធ្វើការនៅក្នុងភូមិវិញ។ ដល់ពាក្យវាផ្ទុយអ៊ីចឹង ខ្ញុំអត់ដឹងឆ្លើយថាម៉េចទេ ព្រោះខ្ញុំចូលមកធ្វើការ៧៧ គេជម្លៀសគាត់ចេញ ហៅទៅរៀនហ្នឹង៧៥។ ដល់សំណុំរឿងវាមក៧៧ទាំងអស់គ្នានេះ ចម្លើយនេះខ្ញុំឆ្លើយអត់បាន។

[០៩:២៣:៤២]

**ស៖** បាទ ដោយសារវាផ្ទុយហ្នឹង ដោយសារខ្ញុំឃើញនៅក្នុងទម្រង់បែបបទដែលលោកស្រីបានបំពេញជាមួយអង្គភាពជនរងគ្រោះហ្នឹង គឺមានស្នាមមេដៃរបស់លោកស្រី។ ហើយក្នុងហ្នឹង គឺអត់មាននិយាយថា ប្ដីលោកស្រីត្រូវបានគេយកទៅកសាង ក៏យកទៅរៀនសូត្រអីទេ។ គឺលោកស្រីបានឆ្លើយហើយថា ដល់ខែមករា ១៩៧៧ គឺប្ដីលោកស្រីនៅឡើងត្នោតធម្មតា។ អ៊ីចឹងហើយបាន ដើម្បីស្វែងរកការពិតនៅទីនេះ អ៊ីចឹងលោកស្រីអាចបញ្ជាក់មើល ថាតើចម្លើយលោកស្រីមួយណាដែលវាត្រឹមត្រូវ?

**ឆ៖** ចាស ចម្លើយដែលត្រឹមត្រូវ ខ្ញុំឆ្លើយយកឆ្នាំ១៩៧៥ ហើយខ្ញុំមកធ្វើការនៅក្នុងសហករណ៍ឆ្នាំ១៩៧៧។ នេះចម្លើយពិតប្រាកដរបស់ខ្ញុំ។ តែដល់ពាក្យមានទៅថា៧៧ ឡើងត្នោតរហូតនោះ គឺខ្ញុំអត់ដឹងទេ។ សូមមិនឆ្លើយ។

**ស៖** ចំណុចមួយទៀត នៅក្នុងឯកសារដដែលហ្នឹងគឺ E3/6307 ដដែលហ្នឹង នៅក្នុងទំព័រដែលមាន ERN ជាភាសាខ្មែរលេខ 00532026, ជាភាសាបារាំង 01137824 ហើយជាភាសាអង់គ្លេសគឺពុំមានការបកប្រែទំព័រនេះទេ។ គឺនៅក្នុងទំព័រហ្នឹង គេដាក់ថាសាក្សីដែលបានដឹងពីជនរងគ្រោះ ក្នុងហ្នឹងជនរងគ្រោះដែលលោកស្រីរៀបរាប់ក្នុងឯកសាររបស់លោកស្រីឈ្មោះ មុំ ឆន ដែលជាបងរបស់លោកស្រី, មុំ រឹម, មុំ ពុធ ដែលជាពូ ហើយនិងបងជីដូនមួយលោកស្រី, អន សក់ ដែលម្ដាយមីងថ្លៃរបស់

លោកស្រី, ឈ្មោះ រ៉ូន ឈ្មោះរី ឈ្មោះអីជាដើមហ្នឹង។ ហើយនៅផ្នែកមួយទៀតដែលគេដាក់ថាសាក្សីដែលដឹងឮហ្នឹង គឺលោកស្រីបានបញ្ជាក់នៅក្នុងរៀងទី៤នៃសាក្សីហ្នឹង លោកស្រីបានបញ្ជាក់ថា សាក្សីដែលដឹងឮថាឧក្រិដ្ឋកម្មដែលកើតឡើងហ្នឹងគឺមានឈ្មោះ តាន់ ហ៊ឹង ភេទប្រុស អាយុ៤៧ឆ្នាំ (ប្តី) លោកស្រីបកថាជាប្តី រស់នៅក្នុងភូមិសង្កែមានជ័យ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប។

[០៩:២៦:០០]

ហើយនៅក្នុងខាងក្រោមកទៀត ចំណុចលេខ៦ហ្នឹង គឺលោកស្រីគេបានសួរថា តើអ្នកដែលទំនាក់ទំនងអ្វីជាមួយសាក្សីទាំងនោះ? លោកស្រីបានឆ្លើយថា -- បានសរសេរថា តាន់ ហ៊ឹង ត្រូវជាប្តីរបស់លោកស្រី។ ឈ្មោះ មុំ ពៅ ប្អូនជីដូនមួយរបស់លោកស្រី។ អ៊ីចឹងរហូត បើតាមឯកសាររបស់លោកស្រីនេះ រហូតដល់ឆ្នាំ -- ដល់ខែនៅពេលដែលលោកស្រីបំពេញបែបបទហ្នឹងរហូតដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ហ្នឹង គឺប្តីលោកស្រីនៅមានជីវិត ដែលលោកស្រីអះអាងថាគាត់ជាសាក្សី។ អ៊ីចឹងខ្ញុំឆ្ងល់ថាហេតុអីបានជាពេលនេះ លោកស្រីថាប្តីលោកស្រីត្រូវគេកសាងតាំង -- យកទៅកសាងហើយបាត់តាំងពី១៩៧៥? សូមលោកស្រីបញ្ជាក់ឲ្យបានច្បាស់លាស់។

**ឆ៖** ចាស សាក្សីឈ្មោះ តាន់ ហ៊ឹង នោះគឺច្រឡំហើយ។ ឈ្មោះ ចាន់ ហ៊ឹង ដែលជាសាក្សី មិនមែន តាន់ ហ៊ឹង ទេ មិនមែនជាប្តីទេ។ តាន់ ហ៊ឹង ជាសាក្សី។ តាន់ ហ៊ឹង ហ្នឹងជាស្រីទេ មិនមែនប្រុសទេ ដែលជាសាក្សីខ្ញុំនោះ។

**ស៖** ប៉ុន្តែលោកស្រីបានបញ្ជាក់ច្បាស់នៅក្នុងឯកសារលាយលក្ខណ៍អក្សរហ្នឹងគឺឈ្មោះ តាន់ ហ៊ឹង ភេទប្រុស អាយុ៤៧ឆ្នាំ (ប្តី) រស់នៅភូមិសង្កែមានជ័យ ដែលជាភូមិរបស់លោកស្រីរស់នៅ។ ហើយដល់ខាងក្រោយ គេសួរថា តើលោកស្រីមានទំនាក់ទំនងអីជាមួយសាក្សីទាំងអស់ហ្នឹង? លោកស្រីថា តាន់ ហ៊ឹង ហ្នឹងត្រូវជាប្តី។ អ៊ីចឹងឥឡូវលោកស្រីថា តាន់ ហ៊ឹង ភេទស្រីឯណាវិញ ឥឡូវអានេះក្នុងនេះសរសេរថាប្តី ហើយភេទប្រុស។

[០៩:២៧:៥៣]

**ឆ៖** ចាស ដែលអ្នកសរសេរហ្នឹងសរសេរ ចេះតែសរសេរទៅ ចំណែកឯខ្ញុំអត់មានដឹងថាអ្នកសាក្សីហ្នឹងជាឈ្មោះ តាន់ ហ៊ឹង ទេ ឈ្មោះ ចាន់ ហ៊ឹង ជាសាក្សីរបស់ខ្ញុំ។ ដែលអ្នកសរសេរច្រឡំថាយ៉ាងណានោះ ខ្ញុំអត់មានទទួលខុសត្រូវទេ ហើយខ្ញុំអត់មានចម្លើយនឹងឆ្លើយប្រាប់ទេ ព្រោះអ្នកណាគឺខ្ញុំប្រាប់អ្នកនោះ បើនិយាយតាមវាំង គឺខ្ញុំអត់ដឹង។

**លោក លីវ សុវណ្ណា៖**

អរគុណលោកប្រធាន។ ខ្ញុំសូមប្រគល់វេទិកាជូនទៅសហភាតាអន្តរជាតិរបស់ខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវី -- លោកស្រីមេធាវីការពារលោក នួន ជា។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកប្រធាន។ លោក លោកស្រីចៅក្រម ភាគីទាំងអស់។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ ដូរីន ជិន ហើយខ្ញុំមានសំណួរបន្តិចបន្តួចទេ ដែលត្រូវសួរក្រោយសហការីរបស់ខ្ញុំ។ ហើយសំណួររបស់ខ្ញុំក៏ទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី ពាក្យសុំតាំងខ្លួនរបស់លោកស្រីផងដែរ។ លោកស្រីដើមបណ្តឹង នៅក្នុងពាក្យសុំតាំងខ្លួនរបស់លោកស្រី គឺឯកសារE3/6307 គេបានឲ្យលោកស្រីបញ្ជាក់អំពីព្យសនកម្ម និងការឈឺចាប់របស់លោកស្រី ដូចដែលមេធាវីសហការីខ្ញុំបាននិយាយហើយ<នៅក្នុងឯកសារជាភាសាខ្មែរ និងបារាំង> គឺលោកស្រីបាននិយាយថា <លោកស្រីបានបាត់បង់>មនុស្សប្រាំពីរនាក់ ហើយក្នុងនោះ រួមមានបង<ប្រុសម្នាក់> ហើយនិងពូ<ម្នាក់> ហើយនិងមីង<ម្នាក់> ហើយនិងបងប្អូនជីដូនមួយ<ម្នាក់> និងបីនាក់ទៀត ឈ្មោះ រ៉ូន, <រី> ហើយនិង រិទ្ធ។

[០៩:២៩:៣៦]

លោកប្រធាន ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺឯកសារនេះគឺមានលេខ 01168545 ជាភាសាខ្មែរ និង01137824 ជាភាសាបារាំង។ ហើយដូចដែលខ្ញុំបញ្ជាក់រួចមកហើយ គឺមិនមានភាសាអង់គ្លេសទេ។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីក៏បាននិយាយអំពីព្យសនកម្មមួយចំនួនដែលលោកស្រីបានទទួលផងដែរ។ លោកស្រីបាននិយាយថា នៅពេលនិយាយអំពីរឿងរ៉ាវខ្មែរក្រហម លោកស្រីភ័យខ្លាច ហើយនិងចុកទ្រូង ហើយលោកស្រីមិនអាចនិយាយឲ្យបាន ឲ្យអស់ពាក្យពេចន៍នោះទេ។ លោកស្រីតែងតែមានការភ័យខ្លាច ហើយនិងរន្ធត់ដោយសារតែខ្មែរក្រហមបានសម្លាប់ពូ មីង ហើយនិងសាច់ញាតិរបស់លោកស្រី។ លោកស្រីបាននិយាយបន្ថែមទៀតថា លោកស្រីបានបាត់បងប្អូន ពូមីង ហើយនិងសាច់ញាតិ ហើយនៅចុងក្រោយលោកស្រីនិយាយថា លោកស្រីបាត់បង់ដី ហើយនិងផ្ទះ។

ឥឡូវនេះខ្ញុំចង់សួរលោកស្រីដូចតទៅនេះ សំណួរទី១ របស់ខ្ញុំ។ លោកស្រីបានបញ្ជាក់ជាមួយសហការីរបស់ខ្ញុំ លោក សុវណ្ណ នៅព្រឹកនេះថា ឪពុកម្ដាយរបស់លោកស្រីស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែលោកស្រីមិនបានបញ្ជាក់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រីឡើយ។ ដូចដែលខ្ញុំបានបញ្ជាក់អំពីចឹង លោកស្រីបានបញ្ជាក់ជាពិសេសគឺការបាត់បងប្អូន ពូមីង ហើយនិងសាច់ញាតិ។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា ហេតុអ្វីបានជាលោកស្រីមិនបញ្ជាក់អំពីការបាត់បង់ឪពុកម្ដាយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងពាក្យសុំតាំងខ្លួន?

[០៩:៣១:១៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអភ័យទោស ខ្ញុំត្រូវកាត់ដោយសារតែ<ខ្ញុំទើបតែបើកឯកសារ ខ្ញុំសង្ឃឹមថាខ្ញុំបើកចំឯកសារ ប៉ុន្តែតើវាមិនបានលើកឡើងដូច្នេះទេឬ៖ "<ខ្ញុំចង់បាន>ដីផ្ទះ<ត្រឡប់មកវិញ ពីព្រោះខ្មែរក្រហមបាន> សម្លាប់ឪពុកម្ដាយ<សាច់ញាតិ>របស់ខ្ញុំ"។ <គឺនៅត្រង់ទំព័រទី៥ នៃឯកសារដែលលោកស្រីទើបតែលើកឡើង គឺ E3/6307។> ខ្ញុំសង្ឃឹមថា ខ្ញុំបើកឯកសារត្រូវ គឺមួយជួរនៅខាងលើ ជួរចុងក្រោយ។

**លោកស្រី ដូរីន ជិន៖**

ចាស លោកស្រីចៅក្រម គឺត្រឹមត្រូវហើយ។ ប៉ុន្តែនៅក្នុងផ្នែកមួយទៀតនៃពាក្យសុំតាំងខ្លួន គឺភាសាខ្មែរ ហើយនិងភាសាបារាំង ប៉ុន្តែខ្ញុំមើលទៅអត់ឃើញមានភាសាអង់គ្លេសទេ។ គឺថាគេឲ្យដើមបណ្ដឹងរៀបរាប់អំពីឈ្មោះ អំពីបុគ្គលជាក់លាក់នីមួយៗ ដែលគាត់អះអាងថាបាត់បង់នោះ ប៉ុន្តែអត់មាននិយាយអំពីឪពុកម្ដាយទេ ប្រហែលជាវាមានភាពផ្ទុយគ្នា។ <តើនេះគឺជាអ្វីដែលខ្ញុំអាចសួរបានដែរឬទេ?>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយណាស់ក្នុងភាសាអង់គ្លេស គឺមានសរសេរបែបនេះ បើតាមដែលខ្ញុំមើល។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

[០៩:៣២:៣១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់បន្តិច គឺគាត់បាននិយាយអំពីការបាត់បង់ឪពុកម្ដាយ

របស់គាត់នៅក្នុងទម្រង់បែបបទជនរងគ្រោះ។ អ៊ីចឹង<ប្រសិនបើមេធាវីការពារអាចសួរ>បញ្ជាក់ឲ្យបានច្បាស់ ថាតើហេតុអីបានជា<គាត់និយាយអំពីការបាត់បង់ឪពុកម្ដាយ នៅក្នុងពេលមួយ ហើយ>មិន<បានលើកឡើងនៅក្នុងបញ្ជីឈ្មោះដែលលោកស្រីទើបតែអាននោះបាន។ ប៉ុន្តែនៅក្នុងករណីនេះ គឺវាមិនត្រឹមត្រូវទេក្នុងការនិយាយថា ដោគវាសនារបស់>ឪពុកម្ដាយគាត់ហ្នឹង <មិនត្រូវបានលើកឡើង>នៅក្នុង<ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់>។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណ នេះគឺជាការបញ្ជាក់ដែលខ្ញុំចង់បាន។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** នៅក្នុងផ្នែកមួយនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីបាននិយាយជាទូទៅអំពីការបាត់បង់ឪពុកម្ដាយ ប៉ុន្តែខ្ញុំចង់សួរថា នៅពេលដែលគេឲ្យលោកស្រីរៀបរាប់លម្អិតអំពីអត្តសញ្ញាណអ្នកដែលបាត់បង់នៅក្នុងពាក្យសុំរបស់លោកស្រីនោះ នៅពេលនុ៎ងគឺលោកស្រីអត់បានរៀប-រាប់អំពីឪពុកម្ដាយទេ។ លោកស្រីរៀបរាប់ត្រឹមតែពូមីង បងប្អូន ហើយនិង<មនុស្សបីនាក់>ទៀត គឺឈ្មោះ រ៉ូន, <រី និង> រិទ្ធ <ដែលលោកស្រីថាពួកគាត់ជាសិស្សនោះ>។ តើលោកស្រីអាចបញ្ជាក់បានទេ ហេតុអ្វីក៏វាមានភាពខុសគ្នានៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រីបែបនេះ?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស ខ្ញុំបញ្ជាក់បាន ប៉ុន្តែកន្លែងដែលថា ឪពុកម្ដាយគ្មានដាក់ចូលនៅក្នុងសំណុំរឿងហ្នឹង គឺថា ថ្ងៃនោះគឺនិយាយតែពីរឿងបាត់បងប្អូន តែម្ដាយឪពុកខ្ញុំក៏គាត់ស្លាប់ដែរហើយ។ ប៉ុន្តែដល់កន្លែងនោះឲ្យខ្ញុំមកនិយាយថា គ្មានឪពុកម្ដាយដាក់ចូលក្នុងនោះ គឺថាខ្ញុំបានដាក់រៀបចំអស់ហើយ ដូចខ្ញុំបានជម្រាបមេធាវីរបស់ខ្ញុំ និងព្រះរាជអាជ្ញារបស់ខ្ញុំ និងមេធាវីនាំមុខ ខ្ញុំបានជម្រាបប្រាប់គាត់អស់ហើយ។ ដូចគាត់បានជម្រាបអំមិញហ្នឹងឯង។

[០៩:៣៤:២៧]

**ស៖** ប៉ុន្តែថ្ងៃនេះ ហើយនិងកាលពីថ្ងៃសុក្រ គឺយើងនិយាយអំពីការបាត់បងប្ដីទី១ របស់លោកស្រី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំចង់សួរដដែលថា ហេតុអ្វីក៏លោកស្រីមិនបានបញ្ជាក់អំពីការបាត់បង់ស្វាមីទី១ របស់លោកស្រីនៅក្នុងពាក្យសុំតាំងខ្លួនរបស់លោកស្រីដូច្នេះ?

**ឆ៖** ចាស ខ្ញុំឆ្លើយបញ្ជាក់រួចអស់។ ឆ្នាំ១៩៧៥ គឺស្វាមីទី១ ខ្ញុំគេហៅទៅរៀនសូត្រ។ ហើយសួរ

ហើយក៏សួរទៀត ចម្លើយនេះខ្ញុំឆ្លើយ ៗហើយក៏ឆ្លើយទៀត បញ្ជាក់ហើយក៏នៅតែបញ្ជាក់ទៀត ឆ្លើយទៅមានសំណួរចម្លើយតែមួយ តើឲ្យខ្ញុំឆ្លើយទៅរបៀបណាទៀត។ ខ្ញុំឆ្ងល់កន្លែងហ្នឹង ព្រោះប្តីខ្ញុំស្លាប់មែន បងប្អូនខ្ញុំក៏ស្លាប់មែន ឪពុកម្តាយខ្ញុំក៏ស្លាប់មែន។ ដល់ទៅចម្លើយមកថា អត់មានឪពុកម្តាយខ្ញុំដាក់ចូលក្នុងក្លឹបនេះ គឺដូចថា ខ្ញុំឆ្ងល់ ខ្ញុំអត់មានចម្លើយអីនឹងឆ្លើយតទៅមុខទៀតទេ។

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ។ ខ្ញុំដឹងថាលោកស្រីបានពិភាក្សាលម្អិតហើយកាលពីថ្ងៃសុក្រ ហើយនិងព្រឹកមិញនេះ អំពីការបាត់បង់ប្តីទី១ របស់លោកស្រី។ ដូចលោកស្រីបានបញ្ជាក់អ៊ីចឹង គឺគាត់ត្រូវបានគេហៅទៅរៀនសូត្រ ហើយអត់ឃើញត្រឡប់មកវិញ។ ខ្ញុំចង់សួរអ៊ីចេះ នៅពេលដែលលោកស្រីបំពេញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី នៅចំពោះមុខតុលាការមួយនេះ លោកស្រីបានរៀបរាប់ថា លោកស្រីបាត់បងប្អូនពូមីង ហើយនិងសាច់ញាតិ។ ប៉ុន្តែលោកស្រីមិនសរសេរថា លោកស្រីបាត់ប្តីទី១របស់លោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ ខ្ញុំចង់សួរហេតុអ្វីបានជាលោកស្រីមិនសរសេរថា បាត់ស្វាមីទី១របស់លោកស្រីនៅរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រីនោះ?

[០៩:៣៦:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំឃើញមួយព្រឹកនេះទាំងលោកមេធាវីលីវ សុវណ្ណា ទាំងលោកស្រីមេធាវី ដូរីន ជិន សួរទៅលើលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីនូវសំណួរដែលខ្ញុំយល់ថា វាអត់សមស្រប។ សំណួរទាំងអស់នោះមិនសមស្របយ៉ាងម៉េច កាលណាចាប់ផ្តើមអំពីហេតុអ្វីៗ ហើយជាសំណួរដែលធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានការលំបាកនៅក្នុងការឆ្លើយ ហើយដែលមានទម្រង់ជាការបន្ទោសទៅលើដើមបណ្តឹងរដ្ឋប្បវេណីដែលជា ពួកគាត់ជាទូទៅមិនមែនជាអ្នកចេះដឹង ហើយមានលទ្ធភាពនៅក្នុងការផ្ទៀងផ្ទាត់ព័ត៌មានគាត់នៅលើអ្វីដែលត្រូវបានសរសេរនោះដូចអ្នកផ្សេងៗទៀតដែលមានចំណេះដឹងខ្ពស់ទេ។ ដូច្នេះការប្រើប្រាស់ពាក្យ ឬក៏ទម្រង់នៅក្នុងការសួរនេះវាអត់សមស្របសម្រាប់ពួកគាត់ទេ។ អ៊ីចឹងខ្ញុំសូមជំទាស់ ហើយខ្ញុំគិតថាបើសួរថាមានអ្វីកើតឡើង ហើយការពិតអ្វីដែលជាការពិតដែលកើតឡើងពេលនោះ ខ្ញុំគិតថាជាសំណួរសមស្រប ហើយសំណួរដែលបាន

សួរនេះ ខ្ញុំគិតថាមិនសមស្រប ហើយសូមជំទាស់វិធីសំណួរនេះ។ សូមអរគុណលោកប្រធាន។

[០៩:៣៨:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកប្រធាន។ តើលោកប្រធានចង់ឲ្យខ្ញុំឆ្លើយតប ឬក៏ខ្ញុំបន្តសួរទៅមុខទៀត។ <យើងគ្រាន់តែលើកឡើងនូវមតិយោបល់មួយ ចំពោះការ>ឆ្លើយតប<នេះប៉ុណ្ណោះ។>

**ប្រធានអង្គជំនុំ៖**

មេធាវីឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនេះ។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកប្រធាន។ យើងគ្រាន់ចង់តែនិយាយថា យើងកំពុងតែស្វែងរកការពិត ហើយយើងគិតថា សំណួររបស់យើងពិតជាត្រឹមត្រូវ <ក្នុងព្រំដែននៃការតាំងសំណួរដែលយើងអាចសួរបាននៅចំពោះមុខអង្គជំនុំជម្រះ>។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះពិតជាអាចឆ្លើយតប និងពន្យល់បានអំពីភាពខុសគ្នាបែបនេះ។ តើខ្ញុំអាចបន្តទៅមុខទៀតទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់ សូមអញ្ជើញមេធាវីបន្តសំណួរទៀត!

[០៩:៣៩:០២]

**សួរដោយលោកស្រី ដូរីន ជិន៖**

សូមអរគុណលោកប្រធាន។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីប្រហែលជាភ្លេចសំណួរខ្ញុំ ឥឡូវខ្ញុំបញ្ជាក់ឡើងវិញ។ ខ្ញុំចង់សួរថា ហេតុអ្វីបានជានៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី លោកស្រីមិនបានសរសេរអំពីការបាត់បង់ស្វាមីទី១របស់លោកស្រី ដែលលោកស្រីបានឆ្លើយថា ប្ដីរបស់លោកស្រីហ្នឹងត្រូវបានគេយកទៅរៀនសូត្រ ហើយមិនត្រឡប់មកវិញ។ ខ្ញុំចង់សួរហេតុអ្វីបានលោកស្រីមិនសរសេរអំពីការបាត់ស្វាមីរបស់លោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស នៅនឹងការសរសេរហ្នឹងដែលខ្ញុំជាអ្នកស្រែ អ្នកជនបទ ខ្ញុំគ្មានចេះច្បាប់ទម្លាប់ គ្មានចេះអក្សរអីនឹងបានសរសេរដាក់នៅក្នុងហ្នឹងទេ។ តែនៅបច្ចុប្បន្ននេះ ខ្ញុំបានមកនិយាយប្រាប់ការពិតដែលប្ដីរបស់ខ្ញុំគេស្នើទៅឱ្យរៀនសូត្រ ឪពុកម្ដាយខ្ញុំក៏ស្លាប់ក្នុងរបបនោះ ហើយខ្ញុំអត់បានសរសេរដាក់ចូលក្នុងសំណុំរឿងហ្នឹង គឺខ្ញុំអត់ចេះអក្សរ ហើយខ្ញុំក៏អត់បានគិតថា នឹងសរសេរបែបនេះដែរ។ ព្រលឹមឡើងដឹងតែការងារ ហើយមិននឹកឃើញថាសរសេរអត្ថបទទាំងអស់នេះបានទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមទោស ខ្ញុំសូមកាត់បន្តិចចុះ។ ព្រោះលោកស្រីនិយាយថា លោកស្រីអត់ចេះអក្សរ អ៊ីចឹងបានន័យថា លោកស្រីអត់បានអានទម្រង់ហ្នឹងទេ មិនបានអានទម្រង់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ។ អ៊ីចឹងមែនទេ?

[០៩:៤០:៤៧]

**លោកស្រី មុំ វុន៖**

ចាស ខ្ញុំជាអ្នកដើមបណ្ដឹងមែន ប៉ុន្តែខ្ញុំអត់ចេះសរសេរ ចេះអាន ខ្ញុំដឹងថាសរសេរ និយាយដោយការពិតតែម្ដង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងមានអ្នកណាអានទម្រង់ពាក្យសុំតាំងខ្លួនហ្នឹងឱ្យលោកស្រីស្ដាប់ទេ? ខ្ញុំឃើញថាលោកស្រីផ្ដិតមេដៃ ប៉ុន្តែចង់ដឹងថាមុនលោកស្រីផ្ដិតមេដៃហ្នឹង មានគេអានឱ្យស្ដាប់ទេ?

**លោកស្រី មុំ វុន៖**

ចាស គេអានឱ្យស្ដាប់ គេអ្នកសរសេរអានឱ្យស្ដាប់។ កាលណាដែលស្ដាប់ហើយគឺបានតែមួយការស្ដាប់ហ្នឹងហើយ ប៉ុន្តែដល់រួចមកខ្ញុំភ្លេច ចាំអត់បាន។ មានតែប៉ុណ្ណឹងទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកស្រី។

[០៩:៤១:៤២]

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** លោកស្រីដើមបណ្ដឹង ខ្ញុំនៅសល់មួយសំណួរទៀត។ កាលពីថ្ងៃសុក្រ ហើយនិងថ្ងៃនេះ

01375188



យើងបាននិយាយអំពីការបាត់បង់កូនរបស់លោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោកស្រីបានបញ្ជាក់ជាច្រើនដងមកហើយ រួមទាំងព្រឹកនេះជាមួយ លោក សុវណ្ណា លោកស្រីថាលោកស្រីបាត់បង់កូនពីរនាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយសារអត់ឃ្លាន។ ខ្ញុំចង់សួរដដែលឡើងវិញថា ហេតុអ្វីបានជាលោកស្រីមិនបានសរសេរអំពីការបាត់បង់កូនពីរនាក់របស់លោកស្រីនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែលោកស្រីបែរជានិយាយតែត្រឹម -- តែលោកស្រីបែរជាសរសេរតែត្រឹមការបាត់បង់ពូមីង បងប្អូនសាច់ញាតិទៅវិញ?

**លោក ពេជ អង្គ៖**

បាទ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការលើកសំណួរនេះ ដោយសារលោក លីវ សុវណ្ណា បានលើកអំពីសំណួរនេះរួចហើយ ខ្ញុំគិតថាជាសំណួរច្រំដែល។ ដូច្នេះខ្ញុំសូមបដិសេធ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើគាត់មានបានសរសេរសាច់ញាតិ<ផ្សេងដែរ ឬ>ទេ? ខ្ញុំកំពុងតែ<រក>មើល<ផ្នែកហ្នឹង>។

[០៩:៤២:៥៤]

**លោកស្រី ដូរីន ជិន៖**

គឺនិយាយក្នុងពាក្យទូទៅថាសាច់ញាតិ។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** ដូច្នេះខ្ញុំចង់សួរថាហេតុអ្វីបានជាចាំបាច់លោកស្រីសរសេរអំពីការបាត់បង់ពូមីង បងប្អូនសាច់ញាតិ ប៉ុន្តែលោកស្រីបែរជាមិនសរសេរអំពីការបាត់បង់ស្វាមី ហើយនិងកូន<ពីរនាក់>ទៅវិញ?

**លោកស្រី មុំ វុន៖**

**ឆ៖** ចាស បាត់បង់សាច់ញាតិបងប្អូនជាមួយនឹងប្ដីកូន។ ពាក្យដែលគេសរសេរ គឺអ្នកសរសេរកន្លែងដែលប្ដីនិងកូនដែលស្លាប់នៅពេលក្រោយ គឺខ្ញុំអត់បានសរសេរ ព្រោះខ្ញុំភ្លេច ខ្ញុំមិនការ ខ្ញុំមិនចាំនូវពាក្យទាំងអស់នេះ ហើយខ្ញុំក៏អត់ចេះអក្សរ ហើយក៏អត់បានសរសេរនូវគម្រោងអស់នេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ចុះចំពោះការបាត់បង់កូនពីរនាក់ហ្នឹង លោកស្រីចាំទេនៅពេលសរសេរហ្នឹង តើលោកស្រីមានចាំថាលោកស្រីបាត់បង់កូនទេនៅពេលនុ៎ង?

**ឆ៖** ចាស នៅក្នុងពេលនោះខ្ញុំដឹងថា កូនខ្ញុំដែលពីរនាក់ស្លាប់នោះ ស្លាប់នៅឆ្នាំ២០០៧ ចាំបានតែប៉ុណ្ណឹងទេ។ អត់មានចាំអីទៀតទេ ចាំតែកូនខ្ញុំស្លាប់ក្នុងឆ្នាំ២០៧៧ -- ពីរពាន់ -- ៩៧៧ហ្នឹង។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណចំពោះការអត់ធ្មត់របស់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារ លោក នួន ជា!

[០៩:៤៤:៥២]

**លោក លីវ សុវណ្ណា៖**

បាទ អរគុណលោកប្រធាន។ ដើម្បីប្រតិចារឹកដែលយើងដេញដោលមុននេះ ដែលទម្រង់បែបបទគាត់ផ្នែក “គ” ដែលនិយាយពីម្ដាយឬអីហ្នឹង គឺជាភាសាខ្មែរដែលមាន ERN ជាភាសា -- ERN 00532027 នៅ*ត្រែ*ទី២ គាត់ដាក់ថា៖ “មានជំងឺបាក់ស្បាត ភ័យខ្លាច និងវន្ធត់ស្មារតី ព្រោះខ្មែរក្រហមសម្លាប់ឪពុកមា ម្ដាយមីង និងបងប្អូន។” អ៊ីចឹងមិនមែនឪពុកបង្កើត ឬម្ដាយបង្កើត ដូចជាភាសាបារាំងទេ។ ហើយនៅ*ត្រែ*ទី៣ ដាក់ថា៖ “បាត់បង់បងបង្កើត ឪពុកមា ម្ដាយមីង និងប្អូនៗ។” មិនមែនជាឪពុកម្ដាយបង្កើតរបស់គាត់ទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាបន្តសូមអញ្ជើញលោកមេធាវីលោក ខៀវ សំផន!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមទោស។ អ៊ីចឹងឪពុកម្ដាយដែលគេសរសេរនៅចុងខាងក្រោយ និងអាផ្នែកខាងក្រោយហ្នឹងយ៉ាងម៉េចដែរ <គឺដាក់ថា “បានស្លាប់ឪពុកម្ដាយខ្ញុំ”>។ ឥឡូវនេះ គឺយើងគ្រាន់តែបញ្ជាក់ជាកំណត់ត្រាប្រតិចារឹកប៉ុណ្ណោះ។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកស្រីចៅក្រម។ នៅក្នុងផ្នែក “គ” ជាភាសាខ្មែរ ក្នុងចំណុចទី២ដែលគេ

ឲ្យបញ្ជាក់អំពីព្យសនកម្ម ការបាត់បង់ហ្នឹង *ត្រេ*ទី២ គឺគាត់ដាក់ថា គាត់មានជំងឺបាក់ស្បាត ភ័យខ្លាច និងវង្វេងស្មារតី ព្រោះខ្មែរក្រហមសម្លាប់ឪពុកមា។ អ៊ីចឹងបានន័យថា ជាពួ--

[០៩:៤៦:២៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំយល់អំពីចំណុចនេះ។ យើងឃើញបីដងហើយ ប៉ុន្តែអ្វីដែលខ្ញុំនិយាយដដែលៗ គឺនៅចំណុចទី៧ គឺមានសរសេរអំពីឪពុកម្ដាយ។ ហើយខ្ញុំនិយាយនេះ គ្រាន់តែដើម្បីជាកំណត់ត្រាប្រតិចារឹក។ ហើយឥឡូវយើងបានកត់ត្រាទាំងអស់ចូលប្រតិចារឹកអស់ហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន យើងខ្ញុំយល់ថា ដូចជាមិនចាំបាច់អ្វីត្រូវសួរសំណួរបន្ថែមទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ លោកស្រី មុំ វុន ក្នុងឋានៈលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្ដាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ និងអំពីស្ថានភាពព្យសនកម្ម គឺការខូចខាតដែលកើតមានឡើងចំពោះលោកស្រីជាអាទិ៍ ខូចខាតខាងរាងកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត ហើយជាផលប៉ះពាល់ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណង និងជាសហមូភាពពីជនជាប់ចោទ។

បើសិនជាលោកស្រីមានបំណងធ្វើដូច្នេះ គឺលោកស្រីអាចថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មចំពោះមុខអង្គជំនុំជម្រះបាន ឬក៏អាចតាំងសំណួរទៅកាន់ជនជាប់ចោទ តាមរយៈប្រធានអង្គជំនុំជម្រះ។ សូមអញ្ជើញលោកស្រី!

[០៩:៤៨:២៣]

**លោកស្រី មុំ វុន៖**

អរគុណលោកប្រធាន។ ការដែលឈឺចាប់នៅក្នុងរបបខ្មែរក្រហមដែលបានធ្វើបាបខ្ញុំ ហើយឱ្យធ្វើការងារលើសកម្លាំង ឱ្យធ្វើការលើសកម្លាំង ហូបក៏មិនឆ្អែត ហើយឱ្យលាយជីលាមកអាចម៍មនុស្សហ្នឹង ជាមួយនឹងអង្កាមដុតហ្នឹង ហើយឱ្យកញ្ឆ្រៀវនឹងដៃ ឱ្យខ្ញុំមានការឈឺចាប់។ កញ្ឆ្រៀវនឹងដៃរួចហើយ ឱ្យលិឍលាមកហ្នឹង តើសាប ឬក៏ប្រៃ។ ចាស ហ្នឹងចំណុចមួយ។ ចំណុចមួយទៀត គឺថ្ងៃមួយដែលខ្ញុំខ្លាចឈ្លើង ខ្ញុំមិនហ៊ានចុះទៅស្ទូងទេ គឺកន្លែងហ្នឹងឈ្លើងច្រើនណាស់ ខ្ញុំខ្លាច ហើយគេឆ្លើយថាឈ្លើងអត់មានអា.កាទេ ចុះ ឬក៏មិនចុះ។ ដល់ខ្ញុំប្រឆាំងថា ខ្ញុំអត់ចុះទេ។ ខ្ញុំខ្លាច ហើយគេទាយយកអាឈើជ្រុងស្រួចបុកភ្លៅស្តាំខ្ញុំហ្នឹង មានភស្តុតាងនៅសព្វថ្ងៃហ្នឹង។ ហើយដល់រួចហើយ ខ្ញុំឈឺគ្រាំគ្រាទ្រុឌទ្រោមមក។ ម្យ៉ាងទៀត ហើយក៏ស្អែកឡើង យើងអត់ទៅធ្វើការ ក្អកឈាម អត់ទៅធ្វើការ គេថាយើងធ្វើពុត។ ដល់តែធ្វើពុតហើយ ដល់រួចមកទៀត បានគេផុតពីនោះមក បានគេហៅខ្ញុំមកថា ឥឡូវទៅ ទៅរៀបការទៅ ឱ្យរៀបការ។ មុននឹងរៀបការផុតពីរថ្ងៃហ្នឹង គេហៅខ្ញុំ ប្រាំនាក់ហ្នឹងគេហៅខ្ញុំទៅរំលោភសិន។ រំលោភហើយ បានគេរៀបការ។ សេចក្ដីឈឺចាប់របស់ខ្ញុំនេះគឺមាន។ រំលោភរួចហើយ ឱ្យខ្ញុំទៅរៀបការជាមួយនឹងប្ដីហ្នឹងហើយ គេបង្ខំឱ្យផ្សំដំណេក ដូចដាក់បាយជ្រូកអីចឹង។ សេចក្ដីឈឺចាប់អាម៉ាស់របស់ខ្ញុំ គឺថាគ្មានទេ។ ប៉ុន្តែខ្ញុំលាក់ទុកទាំងអស់ ខ្ញុំមិនដែលហ៊ាននិយាយប្រាប់អ្នកណាទាំងអស់ តែមុខអង្គសវនាការនេះ គឺថាខ្ញុំហ៊ានបញ្ចេញទាំងអស់ ដើម្បីឱ្យលោកប្រធានបានដឹង បងប្អូនប្រជាពលរដ្ឋ អស់លោក លោកស្រីទាំងអស់នឹងបានដឹងរឿងរ៉ាវរបស់ខ្ញុំថា គេធ្វើបាបខ្ញុំ មានសេចក្ដីអាម៉ាស់យ៉ាងខ្លាំង។

[០៩:៥០:១៩]

ហើយមួយទៀត ដល់រៀបៗរួចហើយនេះ កាលណាដែលយើងធ្វើការងារ នៅគេបង្ខំចិត្តរួមដំណេក ការរំលោភ ការមើលងាយ មើលថោក ឱ្យយើងឈឺចាប់។ ឈឺចាប់យ៉ាងខ្លាំងនៅក្នុងជីវិតរបស់ខ្ញុំនេះ ថាគ្មានប្រៀបផ្ទៀបបានទេ។ ទោះបីជាខ្ញុំស្លាប់ ក៏ខ្ញុំនៅការចងចាំចំពោះរបបដែលបានធ្វើអំពើឧក្រិដ្ឋកម្មចំពោះរូបខ្ញុំ។ ហើយចំណុចម្យ៉ាងទៀត ខ្ញុំសូមថា លោកជនជាប់ចោទទាំងពីរនេះ តើអាចផ្ដត់នឹងក្រុមគ្រួសារខ្ញុំដែលខាតបង់ ទៅទាំងប៉ុន្មាន ហើយនិងប្រជាពលរដ្ឋរាប់លាន់នាក់នេះ តើជីវិតពីរហ្នឹងអាចប៉ះប៉ូវបានដែរឬទេ? ដែលបានធ្វើទារុណកម្មនៅក្នុងចិត្តខ្ញុំបែបនេះ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ហើយចំណុចចុងក្រោយ គឺខ្ញុំសូមអរគុណជាមួយលោកប្រធាន ដែលបានឲ្យខ្ញុំមកឡើងនៅលើសវនាការនេះ កន្លែងដែលមានតម្លៃ។ ខ្ញុំមានយោបល់តែប៉ុណ្ណឹងទេ។ លោកប្រធាន ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ សវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកស្រីដែលបានចំណាយពេលវេលាមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរូបនេះ វិលត្រឡប់ទៅវិញ។

សូមអញ្ជើញ!

*(ដើមបណ្ដឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

[០៩:៥២:៣៥]

បន្តស្ដាប់សក្ខីកម្មសាក្សី 2-TCW-1031។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-1031 មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកសាក្សីឈ្មោះអីដែរ?

**លោក សែម អំ៖**

**ឆ៖** ខ្ញុំឈ្មោះ សែម អំ។

**ស៖** លោកមានឈ្មោះអ្វីហៅផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំឈ្មោះ ព្រំ អ៊ាត ឈ្មោះផ្សេង។

**ស៖** ចុះនៅក្នុងអត្តសញ្ញាណប័ណ្ណលោក លោកដាក់ឈ្មោះអី?

**ឆ៖** ក្នុងអត្តសញ្ញាណប័ណ្ណខ្ញុំឈ្មោះ សែម អំ។

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** កើតនៅថ្ងៃទី១៨ ខែ៦ ៥៥។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើលោករស់នៅកន្លែងណាសព្វថ្ងៃ? ហើយប្រកបមុខរបរអីដែរ?

[០៩:៥៥:៤៧]

**ឆៈ** រស់នៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។ មុខរបរធ្វើស្រែ ប៉ុន្តែធ្វើប្រធានភូមិ។

**សៈ** ឪពុកម្តាយលោកឈ្មោះអីដែរ?

**ឆៈ** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**សៈ** លោកៗសាក្សីកុំអាលទាន់ឆ្លើយ! ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំលោកឆ្លើយ។ សូមលោកឆ្លើយម្តងទៀត។

**ឆៈ** បាទ ឪពុកខ្ញុំឈ្មោះ ព្រំ សែម, ម្តាយឈ្មោះ ស៊ុំ ហៀវ ស្លាប់ទាំងអស់។

**សៈ** អរគុណលោកសាក្សី។ ចុះប្រពន្ធលោកឈ្មោះអីដែរ? ហើយមានកូនប៉ុន្មាននាក់?

**ឆៈ** ប្រពន្ធឈ្មោះ ផ្កៅ ម៉ៅ មានកូនម្នាក់។

**សៈ** អរគុណ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីបានបញ្ជាក់ថា សមត្ថភាពនិងលទ្ធភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះទេ។ តើពិតមែនទេ?

**ឆៈ** បាទ ខ្ញុំអត់មានពាក់ព័ន្ធជាមួយគាត់ទេ សាច់ញាតិ។

**សៈ** អរគុណលោកសាក្សី។ ហើយថាលោកបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ តើពិតជាអ៊ីចឹងមែនទេ?

**ឆៈ** បាទ ខ្ញុំបានធ្វើសម្បថរួចអស់ហើយជូន--។

[០៩:៥៧:៣៤]

**សៈ** អរគុណលោកសាក្សី។ ជាបន្តទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការណ៍ណាដែលលោកធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឱ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក នាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់លោកអម្បាញ់មិញនេះ។

ក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគីសួរចំពោះលោក។

លោក សែម អំ តើលោកដែលធ្លាប់ផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងពេលកន្លងមក? ហើយប្រសិនបើមានធ្វើ ១ប៉ុន្មានដង? ហើយធ្វើនៅកន្លែងណា?

[០៩:៥៩:០៥]

**ឆ៖** បាទ ខ្ញុំបានធ្វើសក្ខីកម្មជាមួយអ្នកសម្ភាស ធ្វើតែម្ដងទេនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

**ស៖** អរគុណ។ ហើយនៅមុនពេលចូលចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអានកំណត់ហេតុដែលលោកបានផ្ដល់ចម្លើយកាលពីពេលមុន ជាមួយអ្នកស៊ើបអង្កេតសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរទេ?

**ឆ៖** បាទ ខ្ញុំបានអានសាចុះសាឡើងដែរ ប៉ុន្តែដូចថាខ្ញុំវាចាស់ហើយ វាអត់សូវជាផង វាមិនសូវមានការចងចាំច្រើន លោកគ្រូបាទ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹងវាពិតជាត្រឹមត្រូវ វាស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានមើលកំណត់ហេតុហ្នឹងដែលធ្វើសក្ខីកម្មហ្នឹង ក៏បានឯកភាពស្របតាមការចម្លើយរបស់ខ្ញុំដែលបានដឹង។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសាក្សី។ ក្នុងការសួរដេញដោលសាក្សីរូបនេះអនុវត្តតាមបញ្ញត្តិ៩១ស្ទួននៃវិធានផ្ទៃ

ក្នុងអ.វ.ត.កអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា សួរដេញដោលសាក្សី សែម អំ នេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយមេធាវីការពារក្តី នួន ជា រួមជាមួយមេធាវីការពារក្តីលោក ខៀវ សំផន មានរយៈពេលពីរវគ្គសវនាការ។ សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

[១០:០០:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីលោកសាក្សី ខ្ញុំសូមសួរសំណួរបឋម<>ចំនួន<ពីរ>។ លោកបានឆ្លើយថា លោកត្រូវបានគេសម្ភាសមួយលើក <ពិតណាស់ គឺយើង>មានកំណត់ហេតុស្តាប់ចម្លើយ<មួយ>។ នៅពេលដែលលោកផ្តល់កិច្ចសម្ភាសន៍នេះ តើលោកចង់និយាយថា លោកនេះត្រូវបានសម្ភាសដោយស្ត្រីម្នាក់ជាជនបរទេសមែនទេ មិនមែនជាជនជាតិខ្មែរទេ គឺអ្នកសម្ភាសលោកហ្នឹង គឺជនបរទេសមែនទេ?

**លោក សែម អំ៖**

**ឆ៖** បាទ អ្នកសម្ភាសខ្ញុំ គឺមានជនបរទេស។

**ស៖** តើលោកនៅនឹកឃើញទេ ថាលោកក៏ត្រូវបានគេសម្ភាសដែរ ៣ឆ្នាំមុននោះ គឺអ្នកដែលសម្ភាសលោកហ្នឹងមកពីអង្គការមួយឈ្មោះថា មជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកដែលសម្ភាសលោកហ្នឹងគឺឈ្មោះ ផាន់ សុជា លោកនៅនឹកឃើញទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១០:០២:២០]

**ប្រធានអង្គជំនុំ៖**

លោកៗសាក្សីចាំៗមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំលោកឆ្លើយ។

**លោក សែម អំ៖**

**ឆ៖** បាទ ខ្ញុំបានឃើញគេសម្ភាសខ្ញុំដែរបាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនៅចាំទេថាគេមានថត

ខ្សែអាត់សំឡេង<>អីដែរទេ? <តើគេមានអានឲ្យលោកស្ដាប់ឡើងវិញដែរ ឬទេ? ថាតើលោកចាំអ្វីខ្លះអំពីកិច្ចសម្ភាសន៍នោះ គេធ្វើឡើងយ៉ាងម៉េចដែរ?>

**ឆ៖** បាទ ការគេសម្ភាសនោះមានឯកសារមួយចំនួន ហើយនិងគេថតជាសំឡេងដាក់ក្នុងខ្សែអាត់។

**ស៖** ហើយតើលោកនៅនឹកឃើញថា ការថតជាខ្សែអាត់សំឡេងនេះគេមានចាក់ឲ្យលោកស្ដាប់វិញដែរឬទេ ឬក៏ថាលោកអត់មានចាំអ្វីទេ? អ៊ីចេះខ្ញុំចង់និយាយថា តើប្រតិចារឹកដែលគេកត់ត្រាចេញពីខ្សែអាត់សំឡេងហ្នឹង ក្រោយពីកត់ត្រាចេញពីខ្សែអាត់សំឡេងហ្នឹង តើគេមានអានឲ្យលោកស្ដាប់ទេ?

**ឆ៖** បាទ គេអានឲ្យខ្ញុំស្ដាប់ បានខ្ញុំស្ដាប់បានដឹងច្បាស់ហើយ ខ្ញុំអានខ្លួនខ្ញុំទៀត។

**ស៖** សូមអរគុណច្រើនលោកសាក្សី។ សំណួរបឋមមួយចំនួនផ្សេងទៀត មុននឹងខ្ញុំចូលទៅដល់ព្រឹត្តិការណ៍ចន្លោះពីឆ្នាំ៧៥ ដល់៧៩ គឺចម្លើយរបស់លោក ដែលលោកបានឆ្លើយថា លោកទើបនឹងឆ្លើយនេះ ថាលោកគឺជាកសិករ។ ប៉ុន្តែ<តើត្រឹមត្រូវដែរ ឬទេ ថានាពេលណាមួយនោះ គឺលោកធ្លាប់ធ្វើជា>មេភូមិមែនទេ?

[១០:០៤:៣៩]

**ឆ៖** បាទ ខ្ញុំជាមេភូមិ។

**ស៖** ចុះសព្វថ្ងៃនេះ លោកនៅតែធ្វើជាមេភូមិដដែលឬ?

**ឆ៖** បាទ សព្វថ្ងៃក៏ខ្ញុំធ្វើជាមេភូមិដដែល។

**ស៖** តើលោកជាមេភូមិក្របៅ ឃុំដូងហ្នឹងឬ?

**ឆ៖** បាទ ខ្ញុំមេភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

**ស៖** ហើយសំណួរចុងក្រោយ គឺជាសំណួរបឋម គឺតើលោកគឺជាមន្ត្រីជាប់ដោយការបោះឆ្នោត <តើលោកត្រូវបានគេបោះឆ្នោតឲ្យធ្វើ>ជាមេភូមិ <ឬ>?

**ឆ៖** បាទ ខ្ញុំជាប់ជាមន្ត្រីបោះឆ្នោត។

**ស៖** ហើយចុះឆ្នាំក្រោយនេះ លោកនឹងប្រកួតប្រជែង ឈរឈ្មោះឲ្យគេបោះឆ្នោតទៀតទេ?

**ឆ៖** បាទ សព្វថ្ងៃខ្ញុំកំពុងតែប្រឹងប្រែងប្រមូលប្រជាពលរដ្ឋដើម្បីចុះឈ្មោះ ប្រឡងប្រណាំងដើម្បីការបោះឆ្នោតនៅឆ្នាំក្រោយទៀត។

01375197



**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកសាក្សី។ លោកប្រធាន ប្រហែលជាដល់ពេលល្មមនឹងឈប់សម្រាកសិនហើយ មុននឹងចូលទៅដល់សម័យកម្ពុជាប្រជាធិបតេយ្យ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៦ នាទី ដល់ម៉ោង ១០:២៩ នាទី)*

[១០:២៨:៤៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា បន្តសំណួរ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំភ្លេចសំណួរមួយដែលមិនទាន់បានសួរទៅលោក លោកសាក្សី គឺពាក់ព័ន្ធទៅនឹងការបោះឆ្នោតឆ្នាំ២០១៧។ តើលោកជាបេក្ខជនឈរឈ្មោះឲ្យគណបក្សប្រជាជន ឬក៏លោកជាបេក្ខជនឈរឲ្យគណបក្សសង្គ្រោះជាតិ <គណបក្ស សម រង្ស៊ី>?

**ប្រធានអង្គជំនុំ៖**

លោក ៗមេធាវី! តើសំណួររបស់លោកហ្នឹង មានពាក់ព័ន្ធនឹងអង្គហេតុអីដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាច លោកប្រធាន ដោយសារ<មានចំណុចមួយចំនួន ដែលគាត់បានឆ្លើយនៅក្នុង>ចម្លើយ<របស់គាត់ជាមួយនឹង>មជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺខ្ញុំចង់ដឹងថា តើ<គាត់មាន>និន្នាការនយោបាយទៅណាដែរ<។ វាគឺជាព័ត៌មានសាធារណៈ ហើយគឺ>ជាសំណួរតែមួយទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សំណួរនេះសំណួរក្រៅអង្គហេតុ។ សូមតទៅសំណួរថ្មីទៀត លោកមេធាវី។

[១០:៣០:៥០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំសូមត្រឡប់ទៅសួរលោកពីអំឡុងពេល ចន្លោះពីឆ្នាំ១៩៧៥ដល់១៩៧៩ ក៏ដូចជា អំឡុងពេលមុនរំដោះទីក្រុងភ្នំពេញ <ក្នុងខែមេសា> ឆ្នាំ១៩៧៥ តើលោកអាចជម្រាបជូនតុលាការបានទេថា លោកចូលបដិវត្តន៍នៅពេលណាដែរ?

**លោក សែម អ៊ំ៖**

**ឆ៖** បាទ ខ្ញុំចូលបដិវត្តន៍នៅពី១៩៧៣។

**ស៖** តើលោកចូលបដិវត្តន៍ហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** បាទ នៅភូមិសូរជ័យ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាលោកបានក្លាយទៅសមាជិកកងពលលេខ១ នៅពេលនោះជាកងទ័ពចំណុះឲ្យកងពលលេខ១ មែនទេ?

**ឆ៖** បាទ ជាកងទ័ពចំណុះកងពលលេខ១ វរៈ៥០២។

**ស៖** តើកងពលលេខ១នេះ ជាកងពលមួយដែលក្លាយទៅជាកងពល៣១០នុ៎ងមែនទេ ក្រោយរំដោះទីក្រុងភ្នំពេញរួចមក?

**ឆ៖** បាទ កងពលលេខ១នេះ ក្លាយទៅជាកងពល៣១០ បាទ ពិតមែន។

**ស៖** ហើយតើត្រឹមត្រូវដែរឬទេ វរសេនាតូចលេខ៥០២ <ដែលលោកធ្វើការហ្នឹង> ក៏ក្លាយទៅជាវរសេនាធំលេខ១៣ ក្រោយឆ្នាំ១៩៧៥។ ត្រឹមត្រូវដែរ ឬក៏អត់ទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកនៅចាំបានទេថា អ្នកណាជាមេបញ្ជាការវរសេនាធំលេខ១៣ នៅពេលនោះ?

[១០:៣៣:៣៤]

**ឆ៖** បាទ ជាតាហុន គាត់ជាបញ្ជាការកង១៣ វរសេនាតូចលេខ១៣។

**ស៖** សូមសួរបញ្ជាក់ឈ្មោះគាត់ឲ្យបានច្បាស់បន្តិច នៅមេបញ្ជាការអម្បាញ់មិញនេះ តាហុន ឬក៏ តាហាន់?

**ឆ៖** តាហ៊ឹម ហុន, បាទ ហ៊ឹម ហុន។

**ស៖** នៅពេលដែលកងពលលេខ១ ក្លាយទៅជាកងពល៣១០ តើលោកមានឋានន្តរសក្តិប៉ុនណាដែរ ឬលោកគ្រាន់តែជាយុទ្ធជនតូចបំផុតនៅក្នុងកងពលនោះទេ?

**ឆ៖** ខ្ញុំកាលនោះ ខ្ញុំនៅជានីរសាររវរសេនាធំ១៣។

**ស៖** នៅក្នុងចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកថា លោកគ្រាន់តែជាយុទ្ធជន <ថ្នាក់ទាប>។ តើត្រឹមត្រូវដែរទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំមិនជំទាស់ទេ ក៏ប៉ុន្តែខ្ញុំចង់សុំឲ្យមានការ -- នៅក្នុងការសួរសុំឲ្យផ្តល់ឯកសារយោង ហើយនិង ERN ផងដើម្បីយើងខ្ញុំអាចមានលទ្ធភាពផ្ទៀងផ្ទាត់។ សូមអរគុណលោកប្រធាន។

[១០:៣៥:៤៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មិនថ្វីទេគឺ E3/7523 ERNជាភាសាអង់គ្លេស 00875567, បារាំង 00884227, ខ្មែរ 00061157។ លោកសាក្សី តើមាននៅពេលណាមួយនោះលោកធ្លាប់បានមកធ្វើការនៅកន្លែងសេនាធិការរបស់កងពល<លេខ១> ដែរឬទេ? តើនៅមុនឆ្នាំ១៩៧៥ លោកធ្លាប់<មានតួនាទីមួយ>នៅក្នុងសេនាធិការ<>របស់កងពល<លេខ១> ដែរឬទេ?

**លោក សែម អ៊ំ៖**

**ឆ៖** មុន៧៥ ខ្ញុំអត់ដែលបាននៅក្នុងកងពលទេ ខ្ញុំនៅតែក្នុងវរសេនាតូច១៣ប៉ុណ្ណោះឯង។

**ស៖** ខ្ញុំសូមអានចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោកហ្នឹង សួរទៅកាន់លោកហើយសួរមើល តើវាត្រឹមត្រូវដែរឬអត់? នេះគឺឯកសារ E3/7523, ERN ជាភាសាអង់គ្លេស 00875566, បារាំង 00884226, ខ្មែរ 00061156។ គេបានសួរសំណួរទៅកាន់លោកអំពី តាពក ហើយលោក

បានឆ្លើយថា៖ "ខ្ញុំស្គាល់គាត់ ដោយសារខ្ញុំធ្លាប់ទៅសមរភូមិ ខ្ញុំធ្លាប់ធ្វើការនៅសេនាធិការ<> ហើយទទួលខុសត្រូវខាងផ្នែកភស្តុភារ។" ហើយនៅខាងក្រោមបន្តិច ទំព័រដដែលលោកឆ្លើយថា៖ "សួរ៖ តើលោកមានន័យថា សេនាធិការ<ឬ>? បាទ គឺសេនាធិការ<។ អ្នកសួរ និយាយថា៖ "ចុះលោកបាននិយាយឈ្មោះ ឃួន។ តើ ឃួន ហ្នឹងនរណាដែរ? ហើយលោកបានឆ្លើយថា ">ជាប្រធានសេនាធិការ។ តើឈ្មោះគាត់ <ឃួន> ឬ? ហើយលោកថា ឈ្មោះ កុយ ធួន នេះឯង។" អ៊ីចឹងសំណួររបស់ខ្ញុំសួរថា តើនេះគឺអ្វីដែលលោកឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាថាអ៊ីចឹងមែនទេ?

[១០:៣៨:៥៣]

**ឆ៖** បាទ ខ្ញុំអ៊ីចឹងមែនថា កុយ ធួន គាត់ជាសេនាធិការនៅពីលើកងពល៣១០។

**ស៖** សំណួររបស់ខ្ញុំសួរថា នៅពេលដែលលោកធ្វើការនៅសេនាធិការ <ហើយ>លោកទទួលខុសត្រូវខាងផ្នែកភស្តុភារ។ តើនៅពេលនោះកងពលនេះនៅតែជាកងពលលេខ១ នៅឡើយឬ <គឺវានៅមុនឆ្នាំ១៩៧៥>? ឬក៏<នៅពេលហ្នឹង លោកបានក្លាយជាសមាជិករបស់>កងពល៣១០ ទៅហើយ?

**ឆ៖** បានក្លាយមកជាកងពល៣១០ហើយ ជំនាន់នោះ ជំនាន់ទីក្រុងភ្នំពេញ។

**ស៖** លោកក៏ទើបតែឆ្លើយដែរ លោកឆ្លើយថា<> កុយ ធួន។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ក៏លោកនិយាយអំពី កុយ ធួន នេះគឺឯកសារ <E3/5149> ERN ជាភាសាអង់គ្លេស 00205044, ខ្មែរ 00170633, បារាំង 00524398 សូមទោស 97។ លោកនិយាយអំពី កុយ ធួន ហើយក្រោយមកលោកឆ្លើយថា កុយ ធួន ជាប្រធានសេនាធិការគឺគាត់ធំជាង តាអឿន គាត់មានឋានន្តរស័ក្តិខ្ពស់ជាង តាអឿន។ អ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយចាំពេលមីក្រូហ្វូនមានៗភ្លើងក្រហម។

**លោក សែម អំ៖**

**ឆ៖** បាទ អ៊ីចុះហើយមែនបាទ។

**ស៖** ចុះ តាអឿន នេះជាអ្នកណាដែរលោក?

[១០:៤១:២៩]

**ឆ៖** តាអឿន គឺជាកងពល៣១០។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើគាត់គ្រប់គ្រងត្រួតត្រាទៅលើកងពល៣១០ ដែលជាកងពលមួយប្តូរមកពីកងពលលេខ១ហ្នឹងមែនទេ? អ៊ីចឹងគាត់ហ្នឹងគឺជាមេបញ្ជាការកងពល៣១០នេះឬ?

**ឆៈ** បាទ គាត់ជាមេបញ្ជាការកងពល៣១០ពិតមែន។

**សៈ** ហើយពាក់ព័ន្ធទៅនឹងឋានន្តរសក្តិ គឺបុណ្យស័ក្តិនៅក្នុងជួរកងទ័ពនេះ តើ កុយ ធួន ជាមេរបស់ អឿន ឬ? ដោយសារតែ កុយ ធួន ហ្នឹងគាត់ជាប្រធានសេនាធិការទាំងមូលតែម្តង អ៊ីចឹងតើ កុយ ធួន នេះធំជាង តាអឿន ឬ?

**ឆៈ** បាទ តាកុយ ធួន ហ្នឹងគាត់ធំជាងលើ តាអឿន កងពលទៅទៀត។

**សៈ** ខ្ញុំយល់ហើយ តែលោកកំពុងនិយាយអំពីនិយាយអំពីបុណ្យស័ក្តិនេះ លោកនិយាយពីបុណ្យស័ក្តិក្នុងជួរកងទ័ព ឬក្នុងជួរស៊ីវិល?

**ឆៈ** ជួរកងទ័ព។

**សៈ** សូមអរគុណលោកសាក្សី។ ឥឡូវខ្ញុំសូមសួរពីមនុស្សម្នាក់ទៀត តើលោកនៅចាំមនុស្សម្នាក់ទទួលបន្ទុកស្រុក១០៦ គឺខាងសៀមរាប ឧត្តរមានជ័យ គឺគាត់ឈ្មោះ សុត លោកចាំទេ លោកនឹកឃើញមនុស្សម្នាក់ឈ្មោះ សុត ទេ?

**ឆៈ** អត់ដែលស្គាល់ទេ ខ្ញុំអត់បាននឹងផងឈ្មោះ សុត។

[១០:៤៣:៣៩]

**សៈ** ប្រហែលជាគាត់មានឈ្មោះបដិវត្តន៍ហើយមើលទៅ។ តើលោក<មានចាំថា តើនរណា>គឺជាលេខាស្រុក១០៦ នៅចន្លោះពីឆ្នាំ១៩៧៦ ដល់១៩៧៧? លោកស្គាល់ទេ លោកនឹកឃើញទេ?

**ឆៈ** អត់ស្គាល់ទេ ខ្ញុំអត់ស្គាល់ សុត នោះទេ។

**សៈ** មិនថ្វីទេ បើលោកមិនស្គាល់។ មុនខ្ញុំចូលទៅរយៈពេលក្រោយឆ្នាំ១៩៧៥ <និង>សួរអំពីទីកន្លែងដែលលោកឈរជើង។ ខ្ញុំសូមសួរសំណួរមួយបន្ថែមទៀត ពាក់ព័ន្ធទៅនឹង តាអឿន។ លោកបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំនឹងផ្តល់ERNជូននៅពេលក្រោយនេះ។ លោកថា អឿន សូមដកស្រង់៖ "ត្រូវបានដំឡើងបុណ្យស័ក្តិជិតមកដល់មជ្ឈិមទៅហើយ"។ នេះគឺឯកសារ E3/7523 លោកប្រធាន ERNជាភាសាអង់គ្លេស 00875565, ខ្មែរ 00061155 និងបារាំង 00884225។ លោកបានឆ្លើយថា "តាអឿន ត្រូវបានគេដំឡើងបុណ្យស័ក្តិ ឡើងដល់កំពូលតែម្តងនៅក្នុងកងពល ហើយជិតនឹងឡើងមកដល់មជ្ឈិមទៅហើយ"។ តើលោកនឹកឃើញទេថាលោកបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារ

ថាអ៊ីចឹង? មិនម៉េចបានជាលោកដឹងនៅពេលនុ៎ង នៅក្នុងសម័យនោះលោកដឹង តាអឿន គេដំឡើងដល់ថ្នាក់នេះ?

**ឆ៖** ខ្ញុំឮ តាហុន ដែលខ្ញុំនៅជាមួយ គាត់ៗថា តាអឿន គាត់ឡើងធំហើយ។

**ស៖** ហើយតើលោកដឹងថា តាអឿន នេះត្រូវបានគេដំឡើងបុណ្យស័ក្តិមកដល់ថ្នាក់មជ្ឈិមនេះនៅពេលណាដែរ?

[១០:៤៦:០៥]

**ឆ៖** ខ្ញុំចាំអត់បានទេ ដឹងពីឆ្នាំណាទេ។ វាយូរណាស់ហើយ ខ្ញុំភ្លេចអស់បាត់។

**ស៖** ខ្ញុំនឹងសួរលម្អិតអំពី អឿន និង កុយ ធួន នៅពេលក្រោយ។ ឥឡូវខ្ញុំសួរបន្តសំណួរផ្សេងទៅមុខទៀតសិន។ លោកគឺជា<សមាជិកម្នាក់នៅក្នុង>កងពល៣១០ វរសេនាធំលេខ១៣ នេះតាមចម្លើយលោក។ តើត្រឹមត្រូវដែរឬទេ ដែលថាលោក ហើយនិងអង្គភាពកងពល៣១០ហ្នឹងឈរជើងនៅវត្តភ្នំ ជិតផ្សារថ្មី និងឈរជើងនៅជិតមន្ទីរពេទ្យកាល់ម៉ែតផងដែរ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវពិតមែន។

**ស៖** តើកងពល៣១០ មានឈរជើងនៅកន្លែងណាផ្សេងទៀតដែរឬទេ ឬក៏ឈរជើងតែកន្លែងសំខាន់ៗប៉ុន្មាននេះទេ?

**ឆ៖** មាននៅច្រាំងចំរេះ នៅអន្លង់ក្ងាន នៅទួលគោក នៅជ្រោយចង្វា។

**ស៖** នៅពេលដែលលោកជាយុទ្ធជនចំណុះឱ្យកងពល៣១០ តើខ្លួនលោកផ្ទាល់ឈរជើងនៅកន្លែងណាដែរ ក្នុងចំណោមកន្លែងដែលលោកបានទើបរៀបរាប់អម្បាញ់មិញនេះ?

**ឆ៖** មុនដំបូងខ្ញុំនៅជិតផ្សារថ្មី រហូតមកគេដកខ្ញុំមកនៅគល់ស្ពានជ្រោយចង្វា ផ្ទះសេង ថៃ។

**ស៖** តើលោកមានភារកិច្ចធ្វើអ្វី ក្នុងឋានៈលោកយុទ្ធជនកងពល៣១០នេះ?

**ឆ៖** ខ្ញុំអត់មានឋានៈធ្វើអីទេ ប៉ុន្តែខ្ញុំគ្រាន់ក្តាប់សេដ្ឋកិច្ចទៅដូចខ្លះ ដើម្បីបើកអង្ករជូនកងទ័ពជាមួយ តាអុល នោះឯង។

**ស៖** តើត្រឹមត្រូវដែរឬទេ នៅពេលមួយក្នុងឆ្នាំ១៩៧៧ ខ្ញុំគិតថាបំណាច់ឆ្នាំ៧៧ហើយ គឺលោកនិង<សមាជិកកងវរសេនាធំរបស់លោក> ត្រូវបានបញ្ជូនទៅប្រយុទ្ធនៅតាមព្រំដែនជាមួយនឹងកងទ័ពវៀតណាម អ៊ីចឹងមែនទេ?

[១០:៤៩:១២]

**ឆ៖** បាទ ត្រឹមត្រូវ។ គេបញ្ជូនហ្នឹងទៅវាយនៅវៀតណាម។

**ស៖** តើលោកនៅចងចាំអ្វីខ្លះដែរនូវភារកិច្ចរបស់លោកនៅឯព្រំដែនហ្នឹង? លោកធ្វើអីដែរនៅព្រំដែនឲ្យពិតប្រាកដទៅ?

**ឆ៖** បាទ ខ្ញុំនៅព្រំដែន ខ្ញុំកាន់តេអូធំ។ ខ្ញុំនៅសម្រាប់វាយការណ៍ពីសមរភូមិមុខមកសមរភូមិក្រោយ។

**ស៖** លោកនៅសមរភូមិក្រោយហ្នឹង តើលោកនៅ<ជាមួយនរណាដែរ? លោកបាន>ន័យថា <មេបញ្ជាការ>កងពល៣១០ហ្នឹងឬ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! ចាំមីក្រូហ្វូនប្រតិបត្តិការសិន។

**លោក សែម អំ៖**

**ឆ៖** បាទ ខ្ញុំនៅមួយជំនាន់នោះ ខ្ញុំនៅកងកាំភ្លើង -- នៅជាមួយកងកាំភ្លើងធំ កាន់តេអូ។ តែខ្ញុំនៅចំណុះក្នុងកងពល អត់មាននៅវរៈ នៅអីទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** នៅពេលដែលលោកកាន់វិទ្យុទាក់ទងនៅតាមព្រំដែនកម្ពុជា-វៀតណាម តើលោកឈរជើងនៅកន្លែងមួយ គេហៅថាមេមត់ នោះឬ?

[១០:៥១:១០]

**ឆ៖** បាទ ខ្ញុំនៅត្រពាំងថ្លុង ត្រពាំងថ្លុងយើងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំសព្វថ្ងៃ ពីដើមកំពង់ចាម។

**ស៖** លោកសាក្សី ចម្លើយរបស់លោកគឺ E3/7523 ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN អង់គ្លេស 00875554, ខ្មែរ 00061147, បារាំង 00884217។ លោកបាននិយាយអំពីតំបន់មេមត់ក្នុងខេត្តកំពង់ចាម ហើយលោកក៏និយាយអំពីទីក្រុងមួយ <ឬក៏កន្លែងមួយ>ឈ្មោះថា ឡធ្យូង <នៅក្នុងខេត្ត>កំពង់ចាម នៅក្នុងស្រុកស្នួង។ តើជាកន្លែងដែលលោកឈរជើងមែនទេ?

**ឆ៖** អត់ទេ! ណាំទេ។ តេអូធំគឺនៅឡធ្យូង ខ្ញុំនៅត្រពាំងថ្លុង។ កន្លែងកងពលនៅឡធ្យូង។

**ស៖** សូមបញ្ជាក់បន្តិច តើបឹងកុកនៅឯណាដែរ?

**ឆ៖** ខ្ញុំបាទអត់ដែលដឹងទេបឹងកុក មិនដឹងត្រង់ណាបឹងកុក មិនដែលឮ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ឥឡូវខ្ញុំសូមអាននូវចម្លើយរបស់លោក ដើម្បីជម្រះការមន្ទិលសង្ស័យ។ ទំព័រដដែលនេះទេលោកប្រធាន។ មានសហការីប្រាប់ខ្ញុំថា អំណានរបស់ខ្ញុំនេះវាមិនច្បាស់លាស់។ ឥឡូវខ្ញុំសូមអាន៖ "សួរ៖ តើស្រុក ខេត្តណាដែលលោកឈរជើង? ឆ្លើយ៖ នៅស្រុកមេមត់។ តើស្រុកមេមត់មែនទេ? បាទ ស្រុកមេមត់។ ហើយក្រោយមក ខ្ញុំក៏ចេញពីកន្លែងមួយទៅកន្លែងមួយទៀត ហើយត្រូវបានគេចាត់តាំងឲ្យខ្ញុំនៅ<> បឹងកក់ បានដំឡើងអង់តែនធំនោះឯង។"

ឥឡូវខ្ញុំសូមអានបន្តទៅទៀត។ សូមដកស្រង់៖ "នៅពេលដែលមានការប្រយុទ្ធគ្នាខ្លាំងក្លា គេឲ្យខ្ញុំកាន់វិទ្យុទាក់ទងជាមួយនឹងខាងយួន, ខាង ហេង សំរិន, ហ៊ុន សែន។ កាលណោះ ខ្ញុំអត់ដឹងអីទេ។ ខ្ញុំបាននិយាយជាមួយលោក តាព្រំ ឌិន។" បញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកនៅនឹកឃើញទេថាលោកបានឆ្លើយអ៊ីចឹង ទៅកាន់អ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា?

[១០:៥៤:៤៤]

**ឆ៖** បាទ ខ្ញុំបាននិយាយមែន។ ខ្ញុំអត់ដឹងអីមែន ខ្ញុំនៅ -- មិនមែនបឹងកុកទេ ខ្ញុំនៅបឹងកក់ បឹងកក់ ត្រពាំងកក់ គេហៅត្រពាំងកក់។ មិនមែនបឹងកុក បឹងកុកខ្ញុំអត់ស្គាល់។ បាទ ខ្ញុំនិយាយអ៊ីចុះមែន។

**ស៖** ខ្ញុំសូមទោសចំពោះអំណានរបស់ខ្ញុំទីតាំងនេះ វាអានមិនបានច្បាស់លាស់។ ឥឡូវខ្ញុំសូមចូលទៅផ្នែកមួយនៃសម្រង់ដដែល លោកថា៖ "នៅពេលដែលយើងវ៉ៃគ្នាខ្លាំងហ្នឹង បានបើកវិទ្យុទាក់ទងគឺបើវិទ្យុទាក់ទងខាងយួន ខាងហេង សំរិន, ហ៊ុន សែន ហ្នឹងឯង។" តើលោកចង់និយាយថាម៉េចត្រង់ចំណុចនេះលោក?

**ឆ៖** ខ្ញុំឮវិទ្យុនិយាយផង ហើយស្តាប់តាមវិទ្យុផង គេប្រដៅណែនាំឲ្យខាងកងខ្មែរក្រហមនេះរួបរួមគ្នា ដើម្បីកុំធ្វើសង្គ្រាមសម្លាប់តែខ្មែរគ្នាឯងទេ។ បាទ ខ្ញុំចាំបានត្រង់នោះឯង។

**ស៖** បាទ ឥឡូវខ្ញុំសូមសួរមួយចំណុចម្តង មួយចំណុចម្តងចុះ។ តើហេតុអ្វីបានជាលោកបើកវិទ្យុ ហើយទៅទាក់ទងជាមួយខាងវៀតណាម?

**ឆ៖** បាទ ខ្ញុំបើកទៅគេចុចចូលមក។ ខ្ញុំបើកស្តាប់គេណ៎ា ខ្ញុំមិនមែនបើកទាក់ទងទេ ខ្ញុំបើកស្តាប់គេ គេនិយាយគ្នាទៅ យើង -- គេតាមដានយើង យើងតាមដានគេប៉ុណ្ណោះឯងទេ។

**ស៖** ខ្ញុំយល់ហើយ តើលោកមានបានទាក់ទងជាមួយនឹងកងទ័ពវៀតណាមនោះ ដោយផ្ទាល់ដែរឬទេ?

[១០:៥៧:០៤]

**ឆ៖** ខ្ញុំអត់ដែលបានទាក់ទងជាមួយកងទ័ពវៀតណាមទេ ខ្ញុំអត់ចេះវៀតណាមទេ ប៉ុន្តែបានជាឮគេបើកចូល ក៏ដេរគ្នាទៅវិញទៅមកប៉ុណ្ណោះឯង។

**ស៖** តើលោកធ្វើការទាក់ទងតាមវិទ្យុដោយផ្ទាល់ជាមួយនឹងកងទ័ព ហេង សំរិន, ហ៊ុន សែន ដែរឬទេ?

**ឆ៖** កាលនោះខ្ញុំអត់ដឹងមានកងទ័ពនោះហើយនៅទេ ឮកងទ័ពខ្មែរដែរ គឺខ្ញុំបើកទៅចូល។ ចូលទៅគេនិយាយប្រាប់មកខ្ញុំអីថា ពួកឯងទម្លាក់អាវុធទៅ ចូលរួបរួមគ្នាទៅ ឈប់វ៉ៃខ្មែរទៅ ឯងទៅមើលខាងក្រោយអ្ហ៎! ម៉ែឪឯង គេសម្លាប់អស់ហើយ។ និយាយ គេណែនាំដែរ ក៏ខ្ញុំៗជឿដែរ ខ្ញុំមិនមែនថាមិនជឿទេ ប៉ុន្តែខ្ញុំមិនដឹងទៅណា ក៏ខ្ញុំចេះតែនៅ ទ្រាំទៅ ព្រោះខ្ញុំក្រោមបទបញ្ជាទេ។

**ស៖** ឥឡូវខ្ញុំសួរតាមរបៀបផ្សេងវិញ។ តើកងទ័ពវៀតណាមមានបានទាក់ទងតាមវិទ្យុជាមួយនឹងកងទ័ព ហ៊ុន សែន, ហេង សំរិន ដែរឬទេ?

**ឆ៖** ខ្ញុំឮតែខ្មែរដែលនិយាយមកជាប់ប៉ុណ្ណោះឯងទេ គឺខ្មែរទេនិយាយ តែវៀតណាមនិយាយភាសាវៀតណាម ក៏ខ្ញុំស្តាប់មិនបាន ខ្ញុំអត់ចេះភាសាវៀតណាមដែរ។

**ស៖** លោកសាក្សី តើលោកដឹងថា នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅពេលមួយនោះ គាត់គឺជាកងទ័ពចំណុះឲ្យកងទ័ពភូមិភាគឧត្តរ លោកដឹងដែរទេ?

[១០:៥៩:២៤]

**ឆ៖** កាលនោះអត់មានដឹងទេ។ អត់មានដឹងថាលោក ហ៊ុន សែន គាត់ខាងនោះទេ អត់មានដឹងទេ។

**ស៖** តើលោកធ្លាប់ឮគេនិយាយថា នាយករដ្ឋមន្ត្រី ហ៊ុន សែន និងយុទ្ធជនរបស់គាត់បានភៀសខ្លួនទៅវៀតណាមនៅខែមិថុនា ១៩៧៧ លោកធ្លាប់ឮគេនិយាយថាអ៊ីចឹងទេ?

**ឆ៖** បាទ នៅតែក្នុងព្រៃ អត់មានដឹងអីទេ។ ខ្ញុំនៅតែក្នុងព្រៃ វាអត់មានដែលបានឮដំណឹងទេ។ វិទ្យុគេមិនឲ្យបើកផង។ ឮតែតាមវិទ្យុជាមួយវៀតណាម ហើយនិងគេនិយាយតេអ្វូមកខ្មែរណេះ ក៏ស្តាប់បណ្តោយ ប៉ុន្តែអត់មានដឹងថា គាត់នៅខាងណោះ ឬខាងណាទេ អត់មានដឹងសោះ។

**ស៖** តើលោកធ្លាប់ឮថា នាយករដ្ឋមន្ត្រី ហ៊ុន សែន និងកម្លាំងរបស់គាត់បានចូលរួមជាមួយកងទ័ពវៀតណាមនៅចុងឆ្នាំ៧៧ ដើម្បី<ភ្ជាប់>ទំនាក់ទំនង<>ជាមួយកងទ័ពដែលដឹកនាំដោយ ហេង សំរិន ដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** មួយជំនាន់នោះ អត់ដែលបានឮទេ ខ្ញុំនៅដាច់ៗពីគេ អត់មាននៅចុងគេទេ នៅនឹងព្រៃ នៅកាំភ្លើងធំមួយក្រុមៗទេ អត់មានដឹងរឿងហេតុថាគាត់ចូលទៅខាងណោះអីទេ ប៉ុន្តែឮគេ វិទ្យុវៀតណាមហ្នឹងឯងបើកមកផ្សាយឲ្យខ្មែរនិយាយមកថា កុំឲ្យចូល ម៉ែឪឯងគេសម្លាប់អស់ហើយ កុំឲ្យខ្មែរគ្នាឯងសម្លាប់តែគ្នាឯងណោះ។ ខ្ញុំឮតែប៉ុណ្ណោះឯង បើថាឲ្យខ្ញុំដឹងម៉េចទៀតគឺអត់ដឹងទេ។ កាលខ្ញុំឆ្លើយពីមុនមក ក៏ខ្ញុំអត់មានពាក់ព័ន្ធខាងណោះដែរ។

[១១:០១:៣៨]

**ស៖** ខ្ញុំនឹងផ្លាស់ប្តូរប្រធានបទថ្មី ប្រហែលក្រោយពេលឈប់សម្រាក ខ្ញុំនឹងអាចសាកសួរបន្តប៉ុន្តែឥឡូវនេះ ខ្ញុំនៅសល់មួយសំណួរទៅលើចំណុចនេះដែរ គឺលោកអត់ទាន់ឆ្លើយ។ លោកបាននិយាយជាពិសេសអំពីកងទ័ព ហេង សំរិន និងកងទ័ព ហ៊ុន សែន។ ដូច្នេះខ្ញុំចង់សួរថា ហេតុអ្វីបានជាលោកនិយាយអំពីកងទ័ព ហេង សំរិន និងកងទ័ព ហ៊ុន សែន ប្រាប់អ្នកសាកសួររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបែបនេះ?

**ឆ៖** ខ្ញុំធ្លាប់ឮគេនិយាយបន្តិចៗ រហៀងៗដែរ ប៉ុន្តែខ្ញុំអត់ដឹង អត់ដឹងថា គាត់នោះនៅខាងណោះទេ ឮគេថា កាលនោះគេហៅថា "ចោរព្រៃៗ" គេមិនមែនថាទ័ព ហ៊ុន សែន ឯណា អត់ទេ។ គេថាពួកចោរព្រៃទេ។ ខ្ញុំដឹងតែប៉ុណ្ណោះឯង។

**ស៖** មិនអីទេ ឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត គឺជាមូលហេតុសំខាន់បំផុតដែលលោកត្រូវបានគេកោះហៅមកនៅពេលនេះ។ ខ្ញុំសូមសួរដូចតទៅនេះ តើលោកចាំអំពីការចាប់ខ្លួនមេបញ្ជាការកងពលរបស់លោក ឈ្មោះ អឿន ដែរឬទេ? ហើយប្រសិនបើលោកចាំ តើលោកចាំអ្វីខ្លះទាក់ទងទៅនឹងការចាប់ខ្លួននេះ?

**ឆ៖** បាទ ខ្ញុំបានចាំ។ កាលណោះគាត់គេហៅទៅទទួលភ្ញៀវ ហៅទទួលភ្ញៀវ ក៏បាត់គាត់។ បាត់គាត់ទៅ ទៅនីរសារគាត់មកថា គេចាប់គាត់បាត់ហើយដឹង បើគាត់បាត់ៗយូរអត់ឃើញមក រហូតអ្នកដែល ពួកអ្នកដែលគេចុះមកក្តាប់ បានគេហៅខ្ញុំមកប្រជុំនៅកន្លែងវត្តភ្នំនេះ បានខ្ញុំឮ។ ហើយគេចាក់កាសែត តាមកាសែត ថាជាភាសាខ្មែរនេះឯង ចាក់កាសែត ក៏ឮច្រវាក់ក្រោកក្រាកៗ ក៏គេបានសួរខ្ញុំថាឯងស្គាល់ទេ នរណានេះ? ខ្ញុំថាអត់ស្គាល់ទេ។ ថានេះហើយម៉ែឪឯង ម៉ែឪឯង គេសម្លាប់ -- អ៎! គេចាប់អស់ហើយ ជាប់ច្រវាក់ ជាប់គុកអស់ហើយ។ ខ្ញុំបានដឹងតែប៉ុណ្ណោះឯង។

[១១:០៤:២០]

**សៈ** ខ្ញុំនឹងសួរអំពីចំណុចនេះនៅពេលក្រោយបន្តិចទៀត ប៉ុន្តែឥឡូវនេះខ្ញុំបន្តពីអ្វីដែលលោកឆ្លើយ។ លោកឆ្លើយថា អឿន ត្រូវបានគេហៅទៅកន្លែងមួយ។ ប៉ុន្តែលោកចាំទេថាគេហៅ អឿន ហ្នឹងទៅកន្លែងណាដែរមុនពេលដែលគេចាប់ខ្លួនគាត់?

**ឆៈ** ខ្ញុំមិនសូវចាំច្បាស់ទេ ខ្ញុំមិនស្គាល់ទាំងកន្លែង។ អង្កាល់ណោះគេមិនដែលឲ្យទៅប៉ៀតបតទេ ឮតែនីរសារគាត់ថាទៅកន្លែងទទួលភ្ញៀវ។ ទទួលភ្ញៀវដឹងនៅកន្លែងណា ខ្ញុំអត់ស្គាល់ដែរ។ ខ្ញុំនៅទីក្រុងភ្នំពេញមែន ប៉ុន្តែខ្ញុំនៅ មិនដែលដើរទៅណានឹងគេ មិនដែលឲ្យដើរទៅណាផង។

**សៈ** បាទ ត្រឹមត្រូវហើយ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកនិយាយអំពីភ្ញៀវចិន ប៉ុន្តែឥឡូវនេះខ្ញុំសូមអាននូវអ្វីដែលលោកបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា E3/7523 អង់គ្លេស 00875576, បារាំង 00884234, ខ្មែរ 00061165។ សំណួរ លោកឆ្លើយថា៖ "អឿន ត្រូវបានគេហៅទៅប្រជុំនៅទូតចិន។ តាអឿន ទៅ នីរសារហៅនីរសារជាអ្នកជូនទៅ។ នៅពេលដល់ប្រជុំគេភ្ជង់។ អាទី ឬក៏អាណាទេភ្លេចហើយ វាជាអ្នកប្រាប់ខ្ញុំ។ សំណួរ៖ អ៊ីចឹង អាទី គេអត់ចាប់ទេ? ឆ្លើយ៖ អត់ទេ នីរសារគេឲ្យមកវិញ។ អ៊ីចឹងនីរសារនិយាយប្រាប់ពូអ្នេះ? បាទ វានិយាយប្រាប់ខ្ញុំ។ គេហៅ អឿន ទៅពេទ្យចិនមែនទេ? អត់ទេ ទៅ<ស្ពាន>ទូត<ចិន>។" តើលោកចាំថាលោកឆ្លើយចម្លើយបែបនេះប្រាប់អ្នកសម្ភាសលោកដែរឬទេ?

[១១:០៦:៥៣]

**ឆៈ** បាទ ខ្ញុំបានឆ្លើយមែន ព្រោះខ្ញុំបានឮពីគេនិយាយអ៊ីចឹងមែន។ ខ្ញុំឆ្លើយប្រាប់អ្នកសម្ភាសមែនអ៊ីចុះឯង។ ខ្ញុំដឹងប៉ុណ្ណោះឯង ខ្ញុំថាឆ្លើយប៉ុណ្ណោះប្រាប់គាត់។

**សៈ** តើលោកចាំទេថា ទូតចិនហ្នឹងនៅកន្លែងណាដែរ? គឺកន្លែងដែល អឿន ហ្នឹងគេកោះហៅទៅនោះ?

**ឆៈ** ខ្ញុំអត់បានចាំទេ ខ្ញុំភ្លេចហើយ ប៉ុន្តែមិនដឹងត្រង់ទេ កន្លែងទូតៗគេនោះ។ ខ្ញុំដឹងកន្លែងត្រង់ណាគេទេ មិនដឹងឯណាមិនដឹងឯណី វាអត់មានដឹង កន្លែងត្រង់ណាទូតត្រង់ណាអី វាមិនដែលដឹង គេមិនឲ្យទៅប៉ៀតទេ គេអ្នកនៅនោះ។

**សៈ** ខ្ញុំយល់។ ប៉ុន្តែតើទូតចិននៅពេលហ្នឹង គឺនៅកន្លែងតែមួយទូតចិនសម័យបច្ចុប្បន្នដែលនៅតាមផ្លូវម៉ៅសេទុងហ្នឹងមែនទេ?

**ឆៈ** បាទ អត់ដឹងទេ។ ខ្ញុំមិនដឹងនៅត្រង់ណាទេ។ ប៉ុន្តែឮគេនីរសារគាត់ថាទូតចិនៗ ខ្ញុំថាតាម

គាត់តែប៉ុណ្ណោះឯង មិនដឹង។

**សៈ** ដោយសារវាជាព័ត៌មានលម្អិតតិចតួច ខ្ញុំមិនចំណាយពេលវេលាសួរលោកច្រើនទេ ប៉ុន្តែខ្ញុំដឹងថា<>កងទ័ព<ម្នាក់ផ្សេងទៀតនៃ>កងពល៣១០ <ក៏បាននិយាយផងដែរអំពីការ>ចាប់ខ្លួន អឿន ហើយ<និងការកោះហៅគាត់ទៅ>។ គឺលោកប្រធាន ខ្ញុំសូមលើកឯកសារ E3/5641 គឺនិយាយអំពីយុទ្ធជននៅកងពល៣១០ <ERN> ភាសាអង់គ្លេស <00881783>, ខ្មែរ 00055140 និងបារាំង 00892737។ "អឿន មិនត្រូវបានទៅហៅទូតចិនទេ ប៉ុន្តែត្រូវហៅយកទៅចាប់ខ្លួននៅទូតកូរ៉េ។" តើវាអាចទេដែលថា អឿន ត្រូវបានគេនាំយកទៅចាប់ខ្លួននៅទូតកូរ៉េ?

[១១:០៩:២៩]

**ឆៈ** បាទ ខ្ញុំឃើញគេឮគេថានាំទៅឯណោះឯង មិនដឹងទូតចិន មិនដឹងទូតកូរ៉េឯណាកាលនោះ អត់មានស្គាល់អីផង ខ្ញុំនៅក្មេងដែរ។

**សៈ** លោកសាក្សីខ្ញុំចង់សួរថា តើលោកដឹងទេហេតុអ្វីបានជាគេចាប់ អឿន ហើយនិងអ្នកដទៃទៀត?

**ឆៈ** បាទខ្ញុំដឹងថា ឮគេថា ក្បត់ៗ។ ខ្ញុំអត់ដឹងទេ ថាក្បត់បក្ស ក្បត់បក្ស។

**សៈ** ខ្ញុំយល់។ ប៉ុន្តែខ្ញុំចង់សួរអ៊ីចេះ តើខ្លួនលោកផ្ទាល់លោកដឹងទេ? ខ្ញុំមិនសួរថាលោកស្តាប់ឮគេនិយាយថាអី ឬក៏គេចោទថាអីទេ ប៉ុន្តែខ្ញុំចង់សួរថា ខ្លួនលោកផ្ទាល់ លោកដឹងថាគេចាប់ខ្លួនដោយហេតុអ្វីដែរ?

**ឆៈ** អត់ដឹងពីមូលហេតុអីទេ។ ឮតែគេថាចាប់អី ថាក្បត់ៗ ដឹងគេម៉េច ខ្ញុំឮអ៊ីចុះនោះឯង។

**សៈ** ខ្ញុំយល់អ្វីដែលលោកឆ្លើយ ប៉ុន្តែនៅពេលនោះ នៅពេលដែល អឿន ហើយនិងអ្នកដទៃទៀតនៅក្នុងកងពល៣១០នុំង ពួកគេរៀបចំផែនការក្បត់បះបោរដើម្បីផ្តួលរំលំ ប៉ុល ពត ទេ?

**ឆៈ** បាទ ខ្ញុំដឹងមែន។ អានោះខ្ញុំដឹងថា តាអឿន នេះគាត់រៀបផែនការ រៀបចំផែនការបំផុសដើម្បីវាយទៅលើខាងរាជរដ្ឋាភិបាលខាងណោះឯង។

**សៈ** តើលោកដឹងអ្វីខ្លះ ចង់និយាយថាចំណុចជាក់លាក់អ្វីខ្លះដែលលោកដឹងអំពីការរួមគំនិត ឬក៏ការចូលរួមរបស់ អឿន ហើយនិងអ្នកដទៃទៀតនោះ?

[១១:១១:៤៩]

**ឆៈ** បាទ ខ្ញុំបានដឹង ព្រោះខ្ញុំឃើញគេរៀបក្នុងមួយកន្លែង មួយកន្លែងគេរៀបខោអាវ កាំភ្លើង

មួយក្រុមៗ មួយកងៗ ខោអាវប៉ាវ៉ា ស្បែកជើង។ ហើយគេរៀបចំមួយកន្លែង មួយកន្លែងដាក់ ម្ដុំៗនេះ កងនេះ នោះកងនោះ។ ខ្ញុំចាំតែកងវរៈ១៣ទេ។ ខ្ញុំឃើញគេរៀបកងធំនេះ ដាក់កន្លែងនេះ កងធំនោះដាក់កន្លែងនោះ។ ពេលដែលគេផ្ទុះអាវុធទៅ គេនឹងចាប់ស្លៀកបំពាក់ខោអាវនោះ ដើម្បីតស៊ូជាមួយគេទេ។ បាទ ខ្ញុំដឹងតែប៉ុណ្ណោះឯង។ ឃើញ ៗគេធ្វើនៅមុខវត្តភ្នំ គេរៀបកន្លែង។

**ស៖** លោកបាននិយាយអំពីការរៀបចំខោអាវ តើលោកចង់មានន័យយ៉ាងម៉េចដែរ?

**ឆ៖** គេរៀបចំកាលនោះ វាអត់មានពាក់អាវនេះទេ មានតែខោខ្មៅអាវខ្មៅ។ តែគេរៀបចំសម្រាប់កងទ័ពនោះ គេរៀបទុកមួយបន្ទប់ មួយបន្ទប់ដែលគេរៀបមួយក្រុមមាន១០កំប្លេអ៊ីចេះ មួយក្រុម១២កំប្លេ មួយក្រុម១២កំប្លេអ៊ីចឹង។ គេរៀបមួយត្រង់នេះ ម្ដុំៗទុកសម្រាប់ឲ្យកងទ័ព។ ប៉ុន្តែកន្លែងដែលកងទ័ពស្លៀកពាក់នោះ សុទ្ធតែខោអាវខ្មៅ ខោអាវជ្រលក់ទេ ពាក់នៅក្នុងនោះៗ អត់មានខោអាវប៉ាវ៉ា ខោអីទេ។

**ស៖** ខ្ញុំសួរលោកបែបនេះ ព្រោះថានៅពេលដែលលោកឆ្លើយទៅនឹងចម្លើយបែបនេះ អំពីការរៀបចំផែនការក្បត់នោះ លោកមិនបាននិយាយខោអាវលាក់ខ្លួនទេ ប៉ុន្តែលោកនិយាយថា ខោអាវប៉ាវ៉ា។ <ប្រហែលជាមានបញ្ហាបកប្រែហើយ> អ៊ីចឹង<ថាតើឯកសណ្ឋានហ្នឹង គឺវាដូចគ្នាទៅនឹង>ខោអាវប៉ាវ៉ា<ទេ>?

**ឆ៖** ក្រឡេក្រឡា ខោអាវក្រឡេក្រឡា ដូចខោអាវប៉ាវ៉ាអ៊ីចេះ ខោអាវកាត់ក្រឡាជាកង់ៗ។ ប៉ុន្តែខោអាវនោះអត់ល្អទេ វាស្រមុយៗ អត់ហ្មត់ខោអាវ។

[១១:១៤:៣០]

**ស៖** ខ្ញុំអានជូនលោកស្តាប់វិញ អ្វីដែលលោកឆ្លើយ គឺប្រាប់អ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថាតើលោកយល់ស្របទៅនឹងអ្វីដែលលោកឆ្លើយនោះអត់។ "សំណួរ៖ តាមដែលលោកដឹង នៅពេលដែលលោកនៅក្រោមគ្រប់គ្រងរបស់ តាអឿន តើគាត់មិនទាន់រៀបចំផែនការទេ? លោកឆ្លើយ៖ គឺគាត់រៀបចំផែនការហើយ។ សួរ៖ តើលោកអាចប្រាប់បានទេ? លោកឆ្លើយថា៖ ខ្ញុំដឹង ថាគាត់រៀបចំផែនការក្បត់ ព្រោះខ្ញុំឃើញថាពួកគេរៀបចំខោអាវប៉ាវ៉ា។ នៅពេលនោះ ខ្ញុំនៅជ្រោយចង្វា ប៉ុន្តែខ្ញុំអាចធ្វើដំណើរទៅវិញទៅមក ព្រោះខ្ញុំនៅជាប់ជាមួយមេរបស់ខ្ញុំ។ ខ្ញុំឃើញគេរៀបចំខោអាវទាំងអស់នោះ ហើយពេលខ្លះខ្ញុំចូលទៅមើលពួកគេរៀបចំ។ ប៉ុន្តែអត់មានអ្នកណាប្រាប់ថា គេកំពុងធ្វើអីនោះទេ។ ទើបតែពេលក្រោយមក ខ្ញុំដឹង ព្រោះថា -- ខ្ញុំដឹងអំពីផែនការក្បត់នោះ នៅពេលក្រោយ។" សូមបញ្ចប់

ការដកស្រង់។

លោកសាក្សី មុននេះលោកឆ្លើយថា លោកនៅវត្តភ្នំ ប៉ុន្តែក្នុងចម្លើយដែលលោកឆ្លើយនោះ លោកឆ្លើយថា នៅជ្រោយចង្វា នៅពេលដែលលោកឃើញខោអាវប៉ាវ៉ានោះ។ តើលោកនៅកន្លែងណា វត្តភ្នំ ឬក៏ជ្រោយចង្វា?

**ឆ៖** បាទ ខ្ញុំនៅ ខ្ញុំបាទនៅជ្រោយចង្វា ប៉ុន្តែកន្លែង ៗវាច្រើន កន្លែងជ្រោយចង្វាខ្ញុំនៅ កន្លែងគេនៅមួយជួរវត្តឃោសនា អ៎ មុខឃោសនាការនោះ ក្រោយផ្សារថ្មីនោះ អ៎មុខផ្សារថ្មី។ ទល់មុខឃោសនាការនោះមួយកន្លែង ឃើញគេរៀបកន្លែងនោះឯង ខ្ញុំទៅ ព្រោះកងជាមួយគ្នានោះ ទៅមកៗ។ បាទ ប៉ុន្តែកន្លែងខ្ញុំនៅជ្រោយចង្វាទេ។

[១១:១៦:៣៥]

**ស៖** លោកនិយាយអំពីស្បែកជើង ប៉ុន្តែខ្ញុំចង់សួរថាតើខោអាវឯកសណ្ឋាន ហើយនិងស្បែកជើងហ្នឹង គេយកមកពីណាដែរ? <តើនរណាគេឲ្យឯកសណ្ឋាន និងស្បែកជើងទាំងអស់ហ្នឹងទៅ> អឿនុ<>?

**ឆ៖** បាទ ខោអាវនោះ គេរំដោះបានមក បានពីអាមេរិក អាកន្លែងខោអាវអាមេរិកជំនួយមក គេរើបានមក គេទុក។ ស្បែកជើងត្រឹមៗណោះ អាស្បែកជើងទាហាន។ និយាយទៅ ខោអាវទាហានតែម្តង ខោអាវទាហាន ទាហានអាមេរិក ខោអាវនោះ។ ទាហាន លន់ នល់ មិនមែនទាហានអាមេរិក។

**ស៖** តើលោកដឹងទេថា អឿន ហើយនិងអ្នកដទៃទៀតហ្នឹង គេយកខោអាវហ្នឹងមកពីណាដែរ ឬមួយក៏ថាពួកគេលាក់ខោអាវ ហើយនិងស្បែកជើង<ទាំងអស់ហ្នឹងនៅកន្លែងណាមួយ>ពីពេលមុន <តើលោកដឹងដែរ ឬទេ>?

**ឆ៖** ខ្ញុំបាទអត់បានឃើញទេ ប៉ុន្តែឃើញតែកន្លែងគេនេះហើយ ដឹងយកពីណាពីណី អត់ដឹង។ ទៅឃើញគេទុកម្តុំៗ ឃើញ។ បើគេយកពីណា ខ្ញុំអត់បានឃើញគាត់យក។

**ស៖** លោកក៏បាននិយាយអំពីអាវុធ។ តើអាវុធហ្នឹងប្រភេទអីដែរ ដែលលោកបានឃើញ នៅពេលដែល អឿន ហ្នឹងគាត់រៀបចំផែនការក្បត់ហ្នឹង? អាវុធហ្នឹង អាវុធប្រភេទអីដែរ?

**ឆ៖** បាទ ខ្ញុំឃើញតែកងកាំភ្លើងធំទេ អារឿងថ្មើរជើង អត់ដឹងប្រភេទអីទេ។ បើកាំភ្លើងធំ កងកាំភ្លើងធំ កងវរៈ១៣នេះគឺកងកាំភ្លើងធំ។ អាហ្នឹងគឺគេមាន ឌូសេត, ដេកា-៧៥, ដេកា-៨២ ហើយក្រូណូក ការូណូក។ អារឿងថ្មើរជើង ខ្ញុំអត់បានដឹងទេ អត់ដែលបានឃើញកន្លែងគេទេ ខ្ញុំឃើញតែកន្លែង

វរៈ១៣នេះឯង កន្លែងកងកាំភ្លើងធំនេះ។

[១១:១៩:១៧]

**ស៖** តើ អឿន ប្រើប្រាស់កាំភ្លើងអាមេរិកដែរទេ នៅពេលដែលគាត់រៀបចំផែនការក្បត់នោះ?

**ឆ៖** បាទ កាំភ្លើងនោះវាចម្រុះស្មើ។ កាំភ្លើងអាមេរិកផង កាំភ្លើងចិនផង កាំភ្លើងសូវៀតផង។ កាំភ្លើងវើបាននោះ វាចម្រុះទាំងអស់ -- កាំភ្លើងអាមេរិកក៏មាន កាំភ្លើងចិនក៏មាន កាំភ្លើងសូវៀតក៏មាន គុយបាក៏មានដែរ។

**ស៖** តើនៅពេលនុ៎ង លោកដឹងអ្វីបន្ថែមទៀត ទាក់ទងទៅនឹងផែនការនោះ? តើលោកដឹងថា វាមាន<>ផែន<ការអីផ្សេងទៀត> មុនពេលដែលលោកឮគេចោទប្រកាន់ ឬក៏ឮគេនិយាយអំពីផែនការក្បត់នេះ?

**ឆ៖** ក្រោយពីនោះទៀត ខ្ញុំអត់មានដឹងអីទេ ឃើញតែគេរៀបចំប៉ុណ្ណោះឯង ក៏គេចាប់គាត់ទៅបាត់ទៅ ក៏ផែនការនោះវាបាត់។ ចាប់មេរហូតៗ ទៅចាប់អស់រលីងទាំងមេតូច មេធំទៅ ទាំងអស់ទៅផែនការនោះក៏បាត់ទៅ អត់មានដឹងទៀតទេ។

**ស៖** តើលោកចាំថា មានជំនួយយោធាពីអាមេរិកដើម្បីជួយ អឿន ហើយនិងអ្នកដទៃទៀតក្នុងការរៀបចំផែនការក្បត់ទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។ ខ្ញុំឃើញតែគេរៀបខោអាវ អត់ដឹងគេ ខោអាវនោះ ខោអាវបែបសល់ខោអាវអាមេរិក ខោអាវសល់ពីអាមេរិក តែដឹងគេជំនួយថ្មី ឬក៏ខោអាវសល់ពីមុន ពីដែលគេវើបាននោះទេ ខ្ញុំអត់ដឹងផង។

[១១:២១:៣៤]

**ស៖** តើលោកដឹងថា មានឯកសារសម្ងាត់អីដែរទេ គឺឯកសារដែលនិយាយអំពីការជំនួយរបស់អាមេរិកទេ?

**ឆ៖** អត់ដែលបានដឹងទេ។ អត់ដែលបានឃើញឯកសារអីៗទេ ឃើញតែកន្លែងគេរៀបប៉ុណ្ណោះឯង។

**ស៖** ឥឡូវនេះខ្ញុំជួយរំឭកការចងចាំរបស់លោកទៀត គឺឯកសារ E3/7523 អង់គ្លេសមានលេខ 00875575, ខ្មែរ<00061164> និងបារាំងមានលេខ <0088433*(ស៊ីក)*>។ "គេក៏រៀបទាំងកងនារីផងដែរ គឺកង៣។ គឺផែនការគេត្រៀមតាមវត្តភ្នំ ប៉ុន្តែគេអត់ប្រាប់ខ្ញុំទេ។ គេប្រាប់ត្រឹមតែប្រធានក្រុម

ប្រធានអីនោះ កាលហ្នឹងខ្ញុំដឹង ខ្ញុំលួចមើលឯកសារគេ។ សំណួរ៖ ចុះពួមានឆ្ងល់គេធ្វើអីទេ? អត់ទេ ឆ្លើយ៖ ឯកសារមួយខ្ញុំមើលទៅឃើញផែនការអាមេរិកមកជួយ ឲ្យទុក២៤ម៉ោង។ សំណួរ៖ ក្រដាសហ្នឹងមានស៊ីញ៉េរបស់អ្នកណាទេ? ឆ្លើយ៖ អត់មានស៊ីញ៉េទេ។ សំណួរ៖ គេសរសេរដៃ ឬក៏គេវ៉ៃអង្គុលីលេខ? ឆ្លើយ៖ គេវ៉ៃអង្គុលីលេខ។ សំណួរ៖ លិខិតហ្នឹងដាក់ម៉េច? ដាក់ថា អាមេរិកមកជួបគ្នា២៤ម៉ោងអ៊ីចឹង? ហើយលោកឆ្លើយថា អាមេរិកឲ្យទុក២៤ម៉ោងគេមកដល់ហើយ ដល់ពេលគេចាប់ពួកនេះ ទើបបែកការណ៍។ ប៉ុន្តែការចាប់នោះក៏មិនដឹងថា មានកំហុសម៉េចដែរ។" ហើយលោកនិយាយបន្តច្រើនតទៅមុខទៀត ប៉ុន្តែខ្ញុំសូមបញ្ចប់ត្រឹមនេះចុះ។ លោកសាក្សី តើលោកចាំទេ ថាលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបែបនេះ?

[១១:២៤:០៨]

**ឆ៖** បាទ ខ្ញុំបាននិយាយមែន ត្រឹមត្រូវ។

**ស៖** តើលោកឃើញឯកសារហ្នឹងនៅពេលណាដែរ ឲ្យប្រាកដ?

**ឆ៖** ដូចអត់បានឃើញទេ ខ្ញុំដូចមិនបាននិយាយអាត្រង់ឯកសារ បើឮគេនិយាយខ្ញុំឮ។ បើឯកសារដូចខ្ញុំមិនបានឆ្លើយ អាត្រង់ឯកសារ អត់ដែលមាន។

**ស៖** ខ្ញុំបានសួរលោកមុននេះ ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាគេបានឲ្យលោកស្តាប់ទេ បានអានឲ្យលោកស្តាប់ទេ ហើយត្រឹមត្រូវទេ ហើយលោកបានឆ្លើយថា ខ្ញុំ -- ហើយនៅក្នុងចម្លើយនោះលោកឆ្លើយថា ខ្ញុំបានមើលឯកសារសម្ងាត់នោះ។ អ៊ីចឹងស្តាប់ទៅវាដូចថា លោកបានឃើញផ្ទាល់នូវឯកសារសម្ងាត់នោះ។ ដូច្នេះខ្ញុំចង់សួរថាតើលោកបានអានឯកសារហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

អញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំជំទាស់ទៅនឹងការសួរនេះ ព្រោះសាក្សីឆ្លើយថា គាត់មិនបានឃើញទេ ប៉ុន្តែគ្រាន់តែឮ។ ហើយ <បើសិនជា>មេធាវីការពារក្តី<ចង់>សួរដេញដោល<ផ្ទៀងគាត់ម្តងទៀត គាត់អាចធ្វើបាន ប៉ុន្តែគាត់មិនគួរសួរសំណួរដោយធ្វើការសន្និតមួយ>ផ្ទុយទៅនឹងអ្វីដែលសាក្សី<ទើបតែ>ឆ្លើយ<នោះទេ>។

[១១:២៦:០១]

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** មិនបញ្ហាទេ ខ្ញុំសួរឡើងវិញ។ លោកសាក្សី ឥឡូវហ្នឹងលោកបានឆ្លើយថា លោកឮ លោកឮអំពីឯកសារហ្នឹង ប៉ុន្តែនៅក្នុងចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលោកឆ្លើយថា កាលហ្នឹងឯងខ្ញុំលួចមើលឯកសារគេ។ ថាតើលោកឮ ឬក៏លោកបានអានឯកសារហ្នឹងដោយផ្ទាល់?

**លោក សែម អ៖**

**ឆ៖** ខ្ញុំឮទេ អត់បានអានឯកសារទេ ព្រោះខ្ញុំមើលនឹងឯកសារខ្ញុំអត់មានដែរ មានបានថាអានឯកសារឯណាទេ។ គ្រាន់តែឮៗគេនិយាយពីមួយទៅមួយ អត់មានបានអានទេ។

**ស៖** ប៉ុន្តែខ្ញុំចង់សួរថា អ្នកណាជាអ្នកប្រាប់លោក<>អំពីឯកសារ<ហ្នឹង ជាឯកសារវាយអង្គុលីលេខ ពុំមាន>ចុះហត្ថលេខាអីនោះ?

**ឆ៖** ខ្ញុំឮតាមនីរសារ តាអឿន គាត់និយាយ ប៉ុន្តែខ្ញុំអត់បានអាន បានអី ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកចាំថានីរសារ តាអឿន ប្រាប់អីខ្លះទៀតអំពីលិខិតនោះ? តើគាត់ជាអ្នកប្រាប់លោកថា ជំនួយ ផែនការជំនួយយោធាហ្នឹងមកក្នុងរយៈពេល២៤ម៉ោងហ្នឹងដែរមែនទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ខ្ញុំប្រាប់ថា អត់បានដឹង អត់បានដឹងថា គេជំនួយមកពីណាពីណីអត់ដឹងទេ។ ប៉ុន្តែគ្រាន់ឮគេថា ឲ្យទុក២៤ម៉ោង ខ្ញុំឮមែន។ ខ្ញុំឮគេប្រាប់ពីមេបញ្ហាការអីគេប្រាប់អីចេះដែរ។ ខ្ញុំឮតាមគេ។

**ស៖** លោកសាក្សី តើលោកដឹងទេថាខាងឧត្តរ ហើយនិងកងទ័ពអាមេរិក ឬក៏ភ្នាក់ងារអាមេរិកអីហ្នឹង តើពួកគេហ្នឹងមានទំនាក់ទំនងពិសេសអ្វីដែរឬទេ? ឧទាហរណ៍ថា អឿន ឬក៏ កុយ ធួន ហ្នឹងគាត់មានទំនាក់ទំនងពិសេសអីជាមួយអាមេរិកទេ?

[១១:២៨:៤២]

**ឆ៖** បាទ ខ្ញុំអត់បាន ខ្ញុំបាទអត់ដែលបានដឹងទេ ដឹងគាត់មានទំនាក់ទំនងអ្វី គឺអត់ដឹងសោះ។

**ស៖** ឥឡូវនេះខ្ញុំនឹងអាននូវចម្លើយរបស់យុទ្ធជនកងពល៣១០ <ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា> គឺឯកសារ E3/5641, អង់គ្លេសមានលេខ 00881777, ខ្មែរមានលេខ 00055134 ដល់ 35 និងបារាំងមានលេខ 00892731។ នេះគឺជាអ្វីដែលយុទ្ធជនរូបនោះបានឆ្លើយ៖ "ខាងឧត្តរចូលរួមជាមួយអាមេរិក។ ចំណែកអ្នកនៅខាងស្វាយរៀង និងព្រៃវែងគឺចូលដៃជាមួយយួន។ ខាងនិរតីនៅខាង

ខ្មែរក្រហម គឺខុស គឺវាមានបក្សបី។ សំណួរ៖ តើគេចូលដៃជាមួយអាមេរិកហ្នឹងដោយរបៀបណា? <ពួក>គេមានទំនាក់ទំនង<គ្នា> ឧទាហរណ៍ថា ប្រសិនបើគេផ្តួលខាងណាមួយទៅ គឺអាមេរិកជាអ្នកជួយតាមក្រោយ។” សូមបញ្ចប់ការដកស្រង់។ តើលោក<អាច>មានប្រតិកម្ម<>ចំពោះអ្វីដែលយុទ្ធជន<កងពល៣១០> រូបនេះបានឆ្លើយ?

**ឆ៖** ខ្ញុំមិនមានប្រតិកម្មអីទេ។ គេដឹងគេឆ្លើយ ខ្ញុំអត់ដឹង ខ្ញុំអត់ឆ្លើយដែរ ព្រោះខ្ញុំអត់ដឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

វាជាទូទៅគឺ ជាការព្យាយាមក្នុងការព្យាយាមស្វែងរកចម្លើយ គឺយើងត្រូវសួរសំណួរជាក់លាក់ជាជាងការសំណួរទូទ <គឺ “តើលោកមានប្រតិកម្មយ៉ាងដូចម្តេចទៅនឹងចម្លើយនេះ?”>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវខ្ញុំនឹងសួរសំណួរជាក់លាក់។ លោកសាក្សីតើលោកដឹងទេថា អឿន មានទំនាក់ទំនងជាមួយអាមេរិកដែរឬទេ? តើលោកអាចដឹងអំពីតួនាទីកន្លងមករបស់ អឿន ក្នុងកងទ័ពដែរទេ?

**លោក សែម អំ៖**

**ឆ៖** បាទ ខ្ញុំអត់បានដែលដឹងទេ ពីរឿងគាត់ទំនាក់ទំនងជាមួយអាមេរិក ឬជាមួយកងទ័ពម៉េចៗអត់ដឹងទេ ព្រោះការជំនាន់នោះ ឋានៈប៉ុនខ្ញុំអី មិនអាចទៅបៀតគាត់បានទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលឈប់សម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អង្គជំនុំជម្រះអញ្ជើញលោកសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ ឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រលប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:០០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជាបន្តសំណួរ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ក្នុងពេលឈប់សម្រាកអាហារថ្ងៃត្រង់ហ្នឹង យើងមានឱកាសបានស្ដាប់ទៅលើការថតសំឡេង ការសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយប្រសិនបើអ្វីៗដំណើរការតាមយើងគ្រោង ប្រហែលជាពេលបន្តិចទៀតនេះ គឺយើងនឹងស្នើសុំឲ្យមានការចាក់ឡើងវិញនូវខ្សែអាត់សំឡេង អំពីអ្វីដែលលោកបាននិយាយពាក់ព័ន្ធទៅនឹងឯកសារសម្ងាត់មួយនេះ គឺឯកសារសម្ងាត់ដែលយើងនិយាយគ្នាមុនពេលឈប់សម្រាក។ នៅក្នុងខ្សែអត់សំឡេង លោកបាននិយាយថា គឺលោកផ្ទាល់ហ្នឹងបានឃើញឯកសារ។ ប៉ុន្តែមុនពេលដែលយើងរៀបចំរួចរាល់ហើយហ្នឹងឥឡូវនេះខ្ញុំសូមបន្តសំណួររបស់ខ្ញុំមុនពេលឈប់សម្រាកបន្តិចសិន លោកសាក្សី។--

[១៣:៣២:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណ។ មុនពេលមេធាវីចាប់ផ្ដើមសួរសំណួរ ខ្ញុំអនុញ្ញាតសុំលេខ<យោង E3 នៃ>ខ្សែអាត់សំឡេងដែលមេធាវីការពារក្ដីចង់លើកមកនិយាយ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាខ្សែអាត់ហ្នឹងអត់មានលេខE3ទេ គឺវាមានតែជាខ្សែអាត់សំឡេងរបស់មជ្ឈមណ្ឌលឯកសារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កម្ពុជាតែប៉ុណ្ណោះ។ នេះគឺតាមដែលគេប្រាប់ខ្ញុំ។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

ប្រសិនបើវាត្រូវបានទទួលយកជាឯកសារភស្តុតាង គឺប្រាកដជាមានលេខ <E3> ហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

អត់ទាន់ទេ។ ខ្សែអាត់សំឡេងហ្នឹងមិនទាន់<ទទួលយក>នោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

ប្រសិនបើអ៊ីចឹង យើងត្រូវតែឆ្លងកាត់នីតិវិធីក្នុងការដាក់ឲ្យចូលសិន។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែនៅក្នុងឃ្លាំងផ្ទុកឯកសាររួមគឺមានលេខ KT1 -- <សូមទោស> គឺ KTI0818។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

គឺលោកធ្វើសំណើដើម្បីកំណត់ត្រា។

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែខ្ញុំមានពេលវេលាតិច ដូច្នេះខ្ញុំសួរសិន។ ដូច្នេះខ្ញុំនឹងចាំមើលថាតើអង្គជំនុំជម្រះអនុញ្ញាតដល់ខ្ញុំដល់កម្រិតណា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី <យើង>បាននិយាយអំពី អឿន <និង កុយ ធួន និង>ទំនាក់ទំនងជាមួយអាជ្ញាធរអាមេរិក។ ដូច្នេះខ្ញុំសូមអាននូវអ្វីដែលយុទ្ធជនដទៃទៀតបាននិយាយអំពី អឿន ផងដែរ។ គឺ E3/2073 អង់គ្លេសមានលេខ 00876433, ខ្មែរមានលេខ 0005210*(ស៊ីក)*, បារាំងមានលេខ 0089 2884។ គេនិយាយថា៖ “ខ្ញុំមិនជឿថា កែវ ពក មានទំនាក់ទំនងជាមួយអាមេរិកទេ ព្រោះគាត់ជាកុម្មុយនីស្តវ៉ាឌី-កាល់។ ហើយខ្ញុំជឿជាក់ថា អឿន ប្រហែលជាមានទំនាក់ទំនង ព្រោះគាត់ជាវរៈនៅក្នុងរបបចាស់ គឺគាត់នៅជាមួយ ទួន ចាយ។” សូមបញ្ចប់ការដកស្រង់។ តើវាអាចទេដែលថា អឿន មានទំនាក់ទំនងជាមួយនឹងអាមេរិកាំង ដោយសារគាត់ជាទាហានចាស់នៅជំនាន់មុន?

**ឆ៖** បាទ ខ្ញុំបានអត់ដឹងទេ រឿងគាត់។ ដឹងទំនាក់ទំនងទៅអាមេរិកាំងអី ខ្ញុំអត់បានដឹងគាត់។

[១១:៣៥:២២]

**ស៖** មិនអីទេ លោកសាក្សី។ ឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទថ្មី គឺថានៅមុនពេលឈប់

សម្រាកអាហារថ្ងៃត្រង់ហ្នឹង គឺយើងបាននិយាយអំពីការចាប់ខ្លួន អឿន ហើយយើងបាននិយាយអំពីការដែលគាត់<និងអ្នកផ្សេងទៀត>ត្រូវបានគេ<>ហៅឲ្យទៅស្ថានទូតចិន។ មិនច្បាស់ដែរ ថាតើទូតចិន ឬក៏ទូតកូរ៉េនោះទេ ប៉ុន្តែឥឡូវនេះខ្ញុំនឹងអានអ្វីដែលលោកឆ្លើយទាក់ទងទៅនឹងការចាប់ខ្លួន។ គឺ E3/7523, អង់គ្លេសមានលេខ 00875577, ខ្មែរមានលេខ 00061166, បារាំងមានលេខ <00884234> និង <35>។ លោកបាននិយាយថា៖ "គឺស្ថានទូតចិន។ សំណួរ៖ តើគេហៅគាត់ទៅទទួល<ស្វាគមន៍ឯកអគ្គរដ្ឋ>ទូតចិន មែនទេ? <លោកឆ្លើយថា៖> មិន<មែន>ទេ <គឺគេកុហក>។ អ៊ីចឹងអ្ហ៎! ចុះនៅពេលដែលគាត់ទៅហ្នឹង គេចាប់ខ្លួនគាត់ហ្មង? តើទាហានខ្មែរក្រហមមានភ្ជង់កាំភ្លើងគាត់ទេ? លោកឆ្លើយថា បាទ គឺគេភ្ជង់គាត់ពីគ្រប់ទិសឯណោះ។ តើវានៅភ្នំវត្ត មែនទេ? អត់ទេ គឺវានៅខាងលិចភ្នំវត្ត។" តើលោកចាំទេ ថាលោកបានឆ្លើយនូវចម្លើយបែបនេះ? ថាតើលោកបានឃើញផ្ទាល់ ឬមួយក៏ឮគេនិយាយទេ?

**ឆ៖** បាទ ខ្ញុំអត់បានឃើញទេ ឮតែគេនិយាយ។

**ស៖** តើលោកដឹងទេ អ្នកណាគេចាប់ខ្លួនមុន កុយ ធួន ឬក៏មេបញ្ជាការ អឿន?

**ឆ៖** បាទខ្ញុំដឹងតែ តាអឿន មួយទេគេចាប់។ ដឹងអ្នកណាមុន អ្នកណាក្រោយ ខ្ញុំអត់បានដឹងទេ។

**ស៖** ខ្ញុំនឹងជួយឲ្យលោកចងចាំឡើងវិញ គឺនៅក្រោយបន្តិចហ្នឹង នៅក្រោមបន្តិចនៃទំព័រដដែលហ្នឹង។ នៅពេលដែលគេសួរថា៖ "តើ តាអឿន គេចាប់មុន ឬក៏ កុយ ធួន គេចាប់មុន? ហើយលោកបានឆ្លើយថា៖ មុន គឺកុយ ធួន គេចាប់មុន, តាអឿន ក្រោយ ប៉ុន្តែសឹងតែជាមួយគ្នា។ ខ្មែរក្រហមមិនទុកឲ្យអ្នកក្បត់រត់គេចនោះឡើយ <អ៊ីចឹងបានខ្ញុំថា>ប្រសិនបើ<>ផែនការ<បានធ្វើពីពេលនោះមកប្រហែលវាមិនសូវស្លាប់មនុស្សច្រើនទេ>"។ តើវាត្រឹមត្រូវទេ ដែលថាលោកឆ្លើយបែបនេះ លោកសាក្សី ដែលថាគេចាប់ខ្លួន កុយ ធួន មុន តាអឿន?

[១៣:៣៨:២៨]

**ឆ៖** បាទ ខ្ញុំបានឮគេនិយាយចុះឯង គេចាប់ កុយ ឃួន មុន ហើយនិង តាអឿន ក្រោយ។ ប៉ុន្តែតែថា អារឿងខ្ញុំបានឃើញនឹងភ្នែក មិនបានឃើញទេ។

**ស៖** ខ្ញុំយល់ ប៉ុន្តែតើលោកបាន<ឮអំពី>ការចាប់ខ្លួនរបស់ កុយ ធួន <ដែរ ឬទេ?> ហើយលោកឮអំពីការចាប់ខ្លួន អឿន នៅទូតចិន ប៉ុន្តែថាតើលោកដឹងទេថា កុយ ធួន ហ្នឹងគេចាប់ខ្លួននៅកន្លែងណា នៅទីណា ឬក៏នៅពេលណា?

**ធ៖** ខ្ញុំបាទអត់បានដឹងទេ។ អត់ដឹងគេចាប់នៅកន្លែងណាទេ ស្រាប់តែបាត់ទៅ ក៏មិនដឹងបាត់កន្លែងណា ខ្ញុំអត់ដឹងរឿងគេ។ ហើយកាលជំនាន់នោះ គ្មានអ្នកណាបៀតកន្លែងគេបានទេ គេអ្នកធំៗ ថ្នាក់តូចៗដូចខ្ញុំ មិនហ៊ានបៀតទេ។

**ស៖** ខ្ញុំនឹងជួយឱ្យរំឭកដល់ការចងចាំរបស់លោក។ មុននេះបន្តិច លោកបាននិយាយអំពីនាយករដ្ឋមន្ត្រី ហ៊ុន សែន។ យើងមានភស្តុតាងរបស់យុទ្ធជនកងពល៣១០ ដែលនិយាយថា ដែលនិយាយអំពី ហ៊ុន សែន ខ្ញុំសូមដកស្រង់គឺ -- <ដើម្បីកុំឱ្យមានការជំទាស់ ខ្ញុំសូមផ្តល់លេខឯកសារគឺ> E3/7583, អង់គ្លេសមានលេខ 00876559, ខ្មែរមានលេខ 00053869 និងបារាំងមានលេខ <00407996> គឺយុទ្ធជនរូបនេះបាននិយាយថា៖ “មេបញ្ជាការ អឿន ស្ថិតនៅក្នុងក្រុមជាមួយគ្នានឹង ហ៊ុន សែន”។ ហើយនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានសម្ភាសដោយអ្នកស្រាវជ្រាវអូស្ត្រាលីគឺលោក ប៊ែន ឃៀរនិន ។ ឯកសារE3/1593 នៅ<ក្នុងសៀវភៅជា>ភាសាអង់គ្លេស <ត្រង់ទំព័រ 325 ហើយ ERN> អង់គ្លេសមានលេខ<01150169>, បារាំងមានលេខ<00639102>, ខ្មែរមានលេខ <00637857> នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា៖ “កុយ ធួន ត្រូវបានចាប់ខ្លួន -- ខ្ញុំសូមអភ័យទោស -- គឺត្រូវបានគេដាក់ឃុំខ្លួនក្នុងផ្ទះនៅជិតវិមានឯករាជ្យ។” សូមបញ្ចប់ការដកស្រង់។ តើលោកឮអ៊ីចឹងដែរទេ ដែលថាគឺដូចដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយអ៊ីចឹងគឺថា កុយ ធួន ត្រូវបានគេឃុំខ្លួននៅក្នុងផ្ទះនៅជិតវិមានឯករាជ្យនោះ?

[១៣:៤២:១២]

**ធ៖** ខ្ញុំបាទអត់ដែលបានឮទេ អត់! អត់ឮទេ។

**ស៖** មិនអីទេ ព្រោះថាវាមានព័ត៌មានមួយផ្សេងទៀតនិយាយអំពីការចាប់ខ្លួន កុយ ធួន ដែរ។ ប្រហែលជា<វាអាចជួយរំឭកដល់ការចងចាំរបស់លោកបាន>គឺ <E3/2117> គឺជាឯកសារនិយាយអំពីកងពល៧០៣ អង់គ្លេសមានលេខ <00081344> មិនមានភាសាបារាំងទេ គឺភាសាខ្មែរ 00192 975។ អ្នកនិពន្ធបាននិយាយជាមួយនឹងអតីតយុទ្ធជននៅក្នុងកង <វរសេនាតូចពិសេសលេខ704> ឈ្មោះ ម៉េង <ហាក់> ដែលត្រូវបានគេចាត់តាំងឱ្យចាប់ខ្លួន កុយ ធួន។ ដែលតាមអ្នកនិពន្ធ គឺថាគាត់ស្នាក់នៅខាងជើងវត្តភ្នំ។ “វាចំណាយពេល<>ពីរថ្ងៃ<មួយយប់>មុនពេលដែលយើងអាចចាប់ខ្លួន កុយ ដោយសារតែមានទាហានជាច្រើនការពារគាត់។ កងកម្លាំងដែលត្រូវមកចាប់ខ្លួន គឺ<កម្លាំងចម្រុះ>មកពីកង<វរសេនាតូចលេខ៧០៤> និងមកពី<>សេនាធិការផងដែរ <ដែលត្រូវបានពង្រាយ>កម្លាំងតាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពីមុខវ៉ារថទេះភ្លើងរហូតទៅដល់វត្តភ្នំ។" បញ្ចប់ការដកស្រង់។ តើវាអាចត្រឹមត្រូវទេលោកសាក្សី ដែលថា កុយ ធួន ស្នាក់នៅខាងជើងវត្តភ្នំ ហើយវាចំណាយពេល<>ពីរថ្ងៃ<មួយយប់>ឯណោះដើម្បីចាប់ខ្លួនគាត់ ហើយថាគេត្រូវការកងទ័ពជាច្រើនដើម្បីចាប់ខ្លួនគាត់នោះ?

**ឆ៖** ខ្ញុំបាទ អត់បានដឹងទេរឿងនោះ រឿងគេចាប់ពីរយប់ពីរថ្ងៃណា អត់ដឹងទេ។

[១៣:៤៤:៣២]

**ស៖** ចុះ កុយ ធួន ស្នាក់នៅខាងជើងវត្តភ្នំ យ៉ាងម៉េចដែរ? ព្រោះលោកក៏បោះទីតាំងនៅ<ក្បៀរ>វត្តភ្នំដែរ ដូច្នេះតើលោកដឹងទេថា កុយ ធួន ត្រូវបានគេឃុំខ្លួនក្នុងផ្ទះនៅ<ក្បៀរ>វត្តភ្នំនោះ?

**ឆ៖** ខ្ញុំនៅខាងកើតវត្តភ្នំដែរ ប៉ុន្តែមិនដែលឃើញ អត់មានដែលឃើញទេ។ ខ្ញុំនៅនោះ នៅគល់ស្ពានជ្រោយចង្វាអត់ដែលឃើញ កុយ ធួន ណានៅក្បែរនោះសោះ អត់។

**ស៖** ឥឡូវនេះខ្ញុំនឹងពិភាក្សាអំពីកាលបរិច្ឆេទវិញម្តង ខ្ញុំដឹងថាវាពិបាក ប៉ុន្តែលោកសាក្សី អឿន ប្រហែលជាត្រូវបានគេចាប់ខ្លួននៅក្នុងថ្ងៃ១៧, ១៨ កុម្ភៈ ៧៧។ ហើយ កុយ ធួន ប្រហែលជាត្រូវបានចាប់ខ្លួននៅថ្ងៃ២៥ មករា ៧៧។ តើវាអាចទេដែលថា អឿន គាត់ទៅស្ពានទូតចិននៅប្រហែលជាក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី កូប៉េ លោកអាចឲ្យ<ឯកសារយោង ពាក់ព័ន្ធនឹង>កាលបរិច្ឆេទនៃការចាប់ខ្លួន អឿន ហើយនិង កុយ ធួន <ដែលលោកទើបតែលើកឡើងបាន>ដែរឬទេ? សូមឲ្យកាលបរិច្ឆេទឲ្យច្បាស់ ហើយនិង<>ឯកសារ<យោង>ឲ្យច្បាស់មកមើល?

[១៣:៤៦:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងផ្តល់ជូនលោកចៅក្រម។ គឺនៅក្នុងឯកសារស-២១ ហើយក៏មានយោងនៅក្នុងសៀវភៅរបស់ ប៊ែន ឃៀរនិន។ លោកចៅក្រម ខ្ញុំសូមអនុញ្ញាតបង្ហាញជូននៅពេលក្រោយ ប៉ុន្តែឥឡូវនេះនៅក្នុងសៀវភៅរបស់ ឆេនដ័ល័រ ហើយនិង ឃៀរនិន គឺថាថ្ងៃ២១ មករា សម្រាប់ កុយ ធួន ហើយសម្រាប់ការចាប់ខ្លួន អឿន គឺប្រហែលជាក្នុងខែកុម្ភៈ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើការចាប់ខ្លួន អឿន នៅស្ថានទូតចិនហ្នឹងអាចទេវានៅក្នុងខែកុម្ភៈ ឆ្នាំ៧៧?

**លោក សែម អ៖**

**ឆ៖** កាលនោះវាមិនសូវដឹងខែណាៗទេ ខ្ញុំមិនសូវស្គាល់ខែណាខែណីទេ គិតពីខ្លាចភ័យ ខ្លាចភ័យ វាអត់មានដឹងថា ថ្ងៃនេះខែណាខែណី អត់ដឹងផង អត់បានចាំផង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ ឥឡូវនេះខ្ញុំនឹងនិយាយអំពីផែនការវិញ ដែលលោកនិយាយថាផែនការកម្ទេច និងផ្តួលរំលំ ប៉ុល ពត។ តើផែនការកម្ទេច និងផ្តួលរំលំ ប៉ុល ពត ហ្នឹងគេគ្រោងហ្នឹងអនុវត្តនៅពេលណាដែរ? តើលោកឮថាគេប្រុងអនុវត្តផែនការហ្នឹងនៅថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** បាទ អត់មានឮគេថាថ្ងៃណាថ្ងៃណី ខែណាខែណីទេ អត់មានឮទេ។

[១៣:៤៩:០៦]

**ស៖** ឥឡូវនេះខ្ញុំសួរលោកអ៊ីចេះវិញ នៅក្នុងការសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺថា លោកថាគេដឹងអំពីផែនការហ្នឹង ហើយគេរកឃើញអំពីផែនការហ្នឹង។ ដូច្នេះខ្ញុំចង់សួរថា គិតចាប់ពីពេលដែលលោកបានឃើញខោអាវប៉ារ៉ា ហើយនិងអាវុធជាដើមហ្នឹង រហូតទៅដល់ថ្ងៃដែលគេចាប់ខ្លួន អឿន ហ្នឹង តើចន្លោះពីពេលដែលលោកឃើញខោអាវប៉ារ៉ា រហូតដល់ថ្ងៃគេចាប់ អឿន ហ្នឹងមានរយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** បាទ ឃើញកន្លែងគេរៀបខោអាវនោះប្រហែលជាកន្លះខែមុន ប្រហែលជា១៥ថ្ងៃ គេចាប់ខ្លួនគាត់។

**ស៖** អ៊ីចឹងអាចទេក្នុងខែកញ្ញា ឆ្នាំ៧៦?

**ឆ៖** បាទ ខ្ញុំអត់បានចាំទេ ព្រោះសម័យនោះវាអត់មានកាឡង់យេ មានអីឯណា អត់មានដឹងចាំអីពីណា។

**ស៖** លោកសាក្សី គឺមានភស្តុតាងមួយចំនួនដែលបញ្ជាក់ច្បាស់ថា ផែនការហ្នឹងគេត្រូវអនុវត្តនៅពេលណា គឺថាការបះបោរហ្នឹងត្រូវអនុវត្តនៅពេលណានោះ។ ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺខ្ញុំនិយាយយោងទៅលើឯកសាររបស់ ប៉ែន ឃៀវនិន E3/1593 អង់គ្លេសមានលេខ <01150177>, បារាំងមានលេខ 00639181, ខ្មែរមានលេខ <00637879> រហូតដល់ 880។ ឃៀវនិន និយាយអំពីភស្តុតាងដែលបង្ហាញថា ផែនការគ្រោងនឹងអនុវត្តនៅថ្ងៃ០១ មករា ៧៧។ គាត់បាននិយាយថា ឥឡូវនេះ

ខ្ញុំសូមអាននូវពាក្យដែលគាត់សរសេរ៖ "នៅខែកញ្ញា ៧៦ ក្នុងកិច្ចប្រជុំមួយនៅឧត្តរមានជ័យ នៅខាងជើងសៀមរាប កុយ ធួន ហើយនិង សុត គ្រោងធ្វើរដ្ឋប្រហារនៅភ្នំពេញនៅថ្ងៃ០១ មករា ៧៧។ ស្ថានីយ៍វិទ្យុត្រូវបានដំឡើងនៅឧត្តរមានជ័យដើម្បីអំពាវនាវឲ្យមានការងើបបះបោរជាទូទៅ ហើយរបាយការណ៍ខ្លះនិយាយថានិយាយថាផែនការហ្នឹងគឺគ្រោងធ្វើនៅថ្ងៃ១៧ មេសា ៧៧ ប៉ុន្តែមិន<ផែនការនោះមិនបានអនុវត្តនោះទេ។">

[១៣:៥២:៣៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី ក្នុងពេលដែលលោកអាន ដូច្នេះតើលោកអាចប្រាប់បានទេថា គាត់ផ្អែកលើភស្តុតាងអីសរសេរបែបនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺគាត់យោងទៅលើជើងទំព័រ១៤៧ ការសម្ភាសរបស់ ប៉ុងសូដ៍ ជាមួយនឹងកម្មាភិបាល<ម្នាក់>ដែលបានរត់គេចខ្លួន។ នៅជើងទំព័រ១៤៨ គាត់និយាយយោងអំពីទស្សនាវដ្ដីអេស៊ាវីក <គឺអត្ថបទចុះថ្ងៃទី២ ខែធ្នូ> ឆ្នាំ៧៧ ហើយខ្ញុំអាចបន្ថែមទៀតបាន គឺយើងបានស្នើសុំឲ្យទទួលយកឯកសារមួយនៅក្នុងសំណើថ្មីៗនេះ <គឺសំណើតាមវិធាន៨៧> គឺយើងដាក់នៅ<ថ្ងៃទី៣០> ខែសីហា <ឆ្នាំ២០១៦> គឺឯកសារ E434។ ហើយ<អត្ថបទបោះពុម្ពផ្សាយនេះ គឺមាននៅក្នុងសំណុំរឿង គឺមានលេខ F2/8.1.29 ដែលមានតែ ERN ជាភាសាអង់គ្លេសប៉ុណ្ណោះ គឺ 01141-->

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឲ្យមេធាវីអានលេខឯកសារឲ្យបានយឺតៗ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអានលេខឯកសារឲ្យបានយឺតៗ ដើម្បីសម្រួលដល់អ្នកបកប្រែ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមទោសលោកប្រធាន ខ្ញុំនឹងអានម្ដងទៀត។ ខ្ញុំនិយាយក្នុងពេលនេះ ខ្ញុំសូមបន្ថែមឯកសារមួយទៀត គឺឯកសារបោះពុម្ពផ្សាយដែលយើងបានស្នើសុំឲ្យទទួលយកជាភស្តុតាង គឺជាផ្នែកមួយនៃ<សំណើតាមវិធាន៨៧> ឯកសារដែលយើងបានស្នើ E434 នៅក្នុងសំណុំរឿង។ ឥឡូវនេះគឺ F2/8.1.29 ហើយវាមាន<តែ>លេខអង់គ្លេសគឺ01141796 ដែលនិយាយអំពីការបះបោរ ឬក៏រដ្ឋប្រហារនៅថ្ងៃ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<២០ មករា ឆ្នាំ១៩៧៧> ហើយក៏មានភស្តុតាងខ្លះដែលខ្ញុំមិនអាចលើកយកមកពិភាក្សាបាន ប៉ុន្តែបាន បង្ហាញ ភស្តុតាងនោះបានបង្ហាញថាការបះបោរ<គ្រោងនឹងធ្វើឡើងនៅថ្ងៃទី១៥ ខែមីនា។>

[១៣:៥៤:៤៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រសិនបើលោកមិនយកមកពិភាក្សាទេ ខ្ញុំស្នើសុំថាកុំឲ្យអានអី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នេះគឺជាការកាលបរិច្ឆេទដែលខ្ញុំចង់និយាយ គឺថ្ងៃ១៥ <មីនា>។ ដូច្នេះតើវាអាចទេដែល ថា<ការបះបោរ ឬ>ផែនការដើម្បីផ្តួលរំលំកម្ទេច ប៉ុល ពត ហ្នឹងគឺគ្រោងនឹងធ្វើនៅប្រហែលជា<នៅ ចន្លោះ>ខែមករា ដល់ខែមេសា ឆ្នាំ៧៧នោះ?

**លោក សែម អ៊ំ៖**

**ឆ៖** បាទ ខ្ញុំអត់ដែលបានដឹងទេ នៅកាលនោះ។ រឿងធ្វើផែនការ ផែនអីរបស់គេ គឺអត់បានដឹង សោះ។

**ស៖** ឥឡូវនេះខ្ញុំសួរលោកអ៊ីចេះវិញ លោក មុននេះលោកបានឆ្លើយ ហើយក៏លោកបាននិយាយ នៅក្នុង<ចម្លើយរបស់លោក ជាមួយនឹង>មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរថា <នៅពេលមួយ កម្លាំងមកពី>និរតីមកគ្រប់គ្រង។ ហើយលោក ហើយនិងយុទ្ធជនដទៃទៀតហ្នឹងត្រូវស្តាប់ចម្លើយ សារភាពរបស់ អឿន ហើយនិងអ្នកដទៃទៀត។ នៅក្នុងការប្រជុំហ្នឹង ខ្ញុំមិននិយាយអំពីការសារភាពទេ ប៉ុន្តែ<នៅក្នុងអំឡុងពេល>ប្រជុំ តើលោកបានឮអ្នកណាម្នាក់និយាយថា គម្រោងរដ្ឋប្រហារហ្នឹងគ្រោង នឹងធ្វើឡើងនៅពេលណាដែរ?

[១៣:៥៦:៣០]

**ឆ៖** បាទក្នុងពេលប្រជុំនោះ គឺគេអត់មាននិយាយពីរឿងធ្វើរដ្ឋប្រហារទេ គឺនិយាយតែពីរឿងចាប់ ខ្លួន តាអឿន តែប៉ុណ្ណោះ។ ហើយយុទ្ធជនខាងភូមិភាគឧត្តរ កម្មាភិបាលយុទ្ធជននៅសល់កុំយកតម្រាប់ តាម តាអឿន តែប៉ុណ្ណោះទេ។ តែរឿងបញ្ហាធ្វើរដ្ឋប្រហារ រដ្ឋអីគឺអត់មានដឹង។ គេអត់ឮនិយាយចំ។

**ស៖** លោកប្រធាន ខ្ញុំគិតថាប្រហែលជាពេលវេលាសមស្របហើយដែលខ្ញុំស្នើសុំឲ្យ គឺស្នើសុំ ជាផ្លូវការ ដើម្បីឲ្យមានការដកស្រង់នូវខ្សែអាត់ថតសំឡេងនៃការសម្ភាសមជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមអនុញ្ញាតចាក់សំឡេងនៅក្នុងសាលសវនាការនេះ។ ហើយខ្ញុំសង្ឃឹមថា សាក្សីគាត់អាចចាំសំឡេង

ផ្ទាល់របស់គាត់។ ហើយប្រសិនបើលោកប្រធានអនុញ្ញាតយើងនឹងស្តាប់ឮទាំងអស់គ្នា ថាតើគាត់និយាយយ៉ាងម៉េចអំពីបញ្ហាឯកសារសម្ងាត់ ដែលនិយាយអំពីការជួយផ្នែកយោធារបស់អាមេរិកនោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកស្នើសុំឱ្យទទួលយកខ្សែអាត់ទាំងអស់ហ្នឹង ឬមួយក៏ស្នើសុំតែមួយផ្នែកតូចមួយទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនចាំបាច់ត្រូវឱ្យទទួលយកទាំងអស់ទេ ព្រោះថាការបកប្រែ<ជាភាសាអង់គ្លេស> គឺដូចគ្នាបេះបិទនឹងអ្វីដែលគាត់និយាយជាភាសាខ្មែរ គឺគ្រាន់តែខ្ញុំចង់ឱ្យសាក្សីស្តាប់ឮសំឡេងរបស់គាត់ឡើងវិញតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញា!

[១៣:៥៨:៣៥]

**លោក ឌេល លីសាក់៖**

ខ្ញុំមិនជំទាស់ទេ<ក្នុងការ>ប្រើប្រាស់ខ្សែអាត់ហ្នឹង<> ប៉ុន្តែវាចាំបាច់ទាល់តែទទួលយកឯកសារហ្នឹងហើយ ទើបយើងអាចចាក់បាន។ ទាល់តែវាជាផ្នែកនៃភស្តុតាងទើបអាចចាក់បាន។ ដូច្នេះ <>វាជាខ្សែអាត់សំឡេង <ប្រសិនបើវាត្រូវបាន>ទទួលកធ្វើជាភស្តុតាង <ខ្ញុំគិតថា>ខ្សែអាត់<សំឡេងទាំងមូល ត្រូវទទួលធ្វើជាភស្តុតាង>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាងទេ គ្រាន់តែចាក់ជាខ្សែអាត់សំឡេងជាភាសាខ្មែរបន្ទាប់មកគេបកប្រែជាភាសាអង់គ្លេស។ <ដូច្នេះវាក្លាយជាផ្នែកមួយនៃប្រតិចារឹក។ នេះគឺជាអ្វីដែលយើងចង់បាននោះ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

វាជាបញ្ហាបច្ចេកទេស ប៉ុន្តែទាល់តែទទួលយកធ្វើជាភស្តុតាង ទើបយើងអាចប្រើប្រាស់បាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែឥឡូវហ្នឹងយើងមានប្រតិចារឹកនៅក្នុងសំណុំរឿង០០១ ដែលចៅក្រម ខាតរាយច៍ គាត់បានប្រើប្រាស់នូវសម្ភារៈ <អេស.អ៊ុម.ឌី> ដោយមិនមានបញ្ហា<នោះទេ>។ អ្វីដែលស្រី<ចៅក្រម>

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01375224



និយាយគឺវាមិនត្រឹមត្រូវនោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺយើងមិន<បានចាំអំពីករណី ដែលលោកបានលើកឡើងនេះទេ។ តាមវិធាន លោកអាចប្រើប្រាស់អ្វី ដែលត្រូវបានទទួលយកជាភស្តុតាង។ ចុះហេតុអ្វីបានជាលោកមិនស្នើសុំឲ្យមានការទទួលយកជាភស្តុតាងទៅ>។

[១៣:៥៩:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវខ្ញុំធ្វើឲ្យវាសាមញ្ញអ៊ីចេះបន្តិចចុះទៅ គឺគិតថា<ស្របតាមវិធាន៨៧> ខ្ញុំស្នើសុំឲ្យទទួលយកខ្សែអាត់សំឡេងនេះជាឯកសារភស្តុតាង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ប៉ុន្តែថាតើមានជំទាស់ពីភាគីផ្សេងដែរ ឬទេ? ខ្ញុំមើលទៅ គឺ>អត់មានទេអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យទទួលយកខ្សែអាត់សំឡេងនេះ ជាភស្តុតាង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<តើលោកអាចនិយាយម្តងទៀតអំពីលេខបានទេ ដូច្នេះយើងអាចដាក់វានៅក្នុងសំណុំរឿង។>

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ វាមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម នៅត្រង់ KTI0818។ ហើយសម្រង់នោះ យើងនឹងនឹងអាន គឺជានៅត្រង់ទំព័រជាភាសាខ្មែរ-->

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារលោក នួន ជា ផ្អាកបន្តិចសិន! ដោយសារមានបញ្ហាខាងអ្នកបកប្រែ។

*(មានបញ្ហាបច្ចេកទេស)*

[១៤:០១:១៤]

**អ្នកបកប្រែ៖**

បាទ អម្បាញ់មិញនេះមីក្រូអត់ដើរ។ បាទ លោកប្រធាន មីក្រូដើរវិញហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01375225



**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីការពារលោក នួន ជា អញ្ជើញបន្ត! មីក្រូហ្វូនដំណើរការវិញហើយ។ លោកមេធាវីផ្អាកបន្តិចសិន ឆ្លងវិញទៀតហើយ។

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា បន្ត!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ដោយអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំសូម<ចាក់សម្រង់ខ្សែអាត់សំឡេង លេខ> E3/7523, ខ្មែរ 00061164, អង់គ្លេស <00875574>, បារាំង 00884233 ដែលគាត់និយាយអំពីការលួចអានឯកសារជាសម្ងាត់ ដែលឃើញថា មានផែនការធ្វើរដ្ឋប្រហារ ហើយសហរដ្ឋអាមេរិកនឹងមកជួយក្នុងរយៈពេល២៤ម៉ោង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឱ្យមន្ត្រីសោតទស្សន៍ដាក់បង្ហាញខ្សែអាត់នេះ។

[១៤:០៤:១០]

*(ការបង្ហាញឯកសារជាសំឡេង)*

*"...ឯកសារគេ ខ្ញុំលួចមើលឃើញថា ផែនការអាមេរិកមកជួយឱ្យទុក២៤ម៉ោង។ ខ្ញុំលួចមើលក្រដាសគេ។ សួរ៖ ក្រដាសហ្នឹងមានសរសេរ ស៊ីញ៉េអីរបស់ពីណាទេ? ឆ្លើយ៖ រឿងវា ដូចពិបាក-- សួរ៖ គេសរសេរដៃ ឬក៏គេវ៉ៃ-- ឆ្លើយ៖ វាយអង្គុយលីលេខ។ សួរ៖ អង្គុលីលេខអ្ហ៎!..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១៤:០៤:៣៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកស្ដាប់បានទេ តើនេះជាសំឡេងរបស់លោកឬ?

**លោក សែម អំ៖**

**ឆ៖** បាទ ដូចជាខ្ញុំស្ដាប់មិនសូវបានទេ រឿងសំឡេងពីណាទេ។ ខ្ញុំឮ ដូចខ្ញុំមិនបាននិយាយអាត្រង់រឿងអានឯកសារអីណាៗ អត់ដឹងផង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សំឡេងនេះហាក់ដូចជាលឿនបន្តិច អ៊ីចឹងខ្ញុំសូមការអនុញ្ញាតចាក់ខ្សែ<អាត់សំឡេង>នេះ ម្តងទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ចាក់ខ្សែអាត់នេះម្តងទៀត។

[១៤:០៥:៣៥]

*(ការបង្ហាញឯកសារជាសំឡេង)*

*"..លោកពូមានធ្លាប់ទេ ឯកសារមើលម៉េច ឯកសារ? ឆ្លើយ៖ ឯកសារគេ ខ្ញុំលួចមើលឃើញថា ផែនការអាមេរិកមកជួយឱ្យទុក២៤ម៉ោង ខ្ញុំលួចមើលក្រដាសគេ។ សួរ៖ ក្រដាសហ្នឹងមានសរសេរស៊ីញ៉េអីរបស់ពីណាទេ? ឆ្លើយ៖ រឿងវា ដូចពិបាក-- សួរ៖ គេសរសេរដៃ ឬក៏គេវ៉ៃ-- ឆ្លើយ៖ គេវ៉ៃអង្គុយលីលេខ។ សួរ៖ អង្គុលីលេខអ៊ំ..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១៤:០៦:០៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ម្តងទៀតលោកសាក្សី លោកស្តាប់សំឡេងរបស់លោកផ្ទាល់នេះបានទេ?

**លោក សែម អំ៖**

**ឆ៖** បាទ សំឡេងនេះដូចជាប្រហែលដែរ ប៉ុន្តែខ្ញុំដូចជាមើលនឹងឯកសាររបស់ខ្ញុំដូចអត់ឃើញមានបាននិយាយរឿងឯកសារឯណាទេ។ ខ្ញុំរកនឹកវាអត់ដឹងថា បានឃើញឯកសារគេផង។ កាលនោះវាដូចអត់មានឯកសារឯណាច្រើនផង។

**ស៖** ដូច្នេះចម្លើយរបស់លោកឆ្លើយទៅជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺ<មិន>ត្រឹមត្រូវទេ <តើនេះគឺជាអ្វីដែលលោកកំពុងតែនិយាយឬ>?

**ឆ៖** បាទ ខ្ញុំវាឮដូចតែសំឡេងខ្ញុំដែរ ប៉ុន្តែកាលដែលមានឯកសារនោះនិយាយ ដឹងឯកសារដឹងអី គឺថាដូចជាមិនដែលមានឯកសារអីៗ។ បើខ្ញុំគ្រាន់តែឃើញគេរៀបចំខោអាវអារុធអី គឺឃើញមែន ដល់តែបានឃើញឯកសារនោះដូចអត់ដែលបានឃើញសោះ។ មិនដែលបានឃើញទេ វានិយាយពិតស្មោះត្រង់។

**ស៖** មិនថ្វីទេ។ លោកសាក្សី មុននឹងខ្ញុំទៅសួរលោកអំពីអ្វីដែលបានកើតឡើងជាមួយនឹងកងទ័ពវៀតណាមនៅពេលដែលលោកឈរជើងនៅស្រុកមេមត់។ ឥឡូវខ្ញុំសួរសំណួរចុងក្រោយពាក់ព័ន្ធទៅនឹងផែនការ<ផ្តួលរំលំ ឬការប៉ុនប៉ង>ធ្វើរដ្ឋប្រហារ។ លោកបាននិយាយអំពីឯកសណ្ឋាន អាវុធ ស្បែកជើង និងឧទាហរណ៍មួយចំនួនទៀត។ តើលោកធ្លាប់បានឮអំពីផែនការវាយប្រហារ និងដណ្តើមកាន់កាប់ព្រលានយន្តហោះពោធិ៍ចិនតុង ទាក់ទងទៅនឹងគោលបំណងនៃការធ្វើរដ្ឋប្រហារនេះដែរឬទេ?

[១៤:០៨:៣៧]

**ឆ៖** បាទ ខ្ញុំបាទអត់ដែលបានឮគេនិយាយអីទេ រឿងធ្វើផែនការ ផែនអីនោះ ខ្ញុំអត់ដែលដឹងពីបញ្ហាផែនការរបស់គេទេ។ ដូចអង្គាល់ជំនាន់ណោះ ដូចដឹងស្រាប់ហើយ គេអ្នកធំគឺគេដឹងតែគ្នាគេទេ អាតូចៗគេដែលឲ្យយើងដឹង គេមិនដែលឲ្យយើងដឹងទេ។ បើមានផែនការអី ក៏គេបញ្ជាទៅប៉ុណ្ណោះឯង។ បើថាគេឲ្យដឹងគឺគ្មាន អត់មានឲ្យដឹង ខ្ញុំអស់។

**ស៖** ដើម្បីជៀសវាងកុំឲ្យមានការយល់ច្រឡំ ខ្ញុំនិយាយអំពីផែនការធ្វើរដ្ឋប្រហារដូចដែលលោកលើកឡើងអ៊ីចឹង។ អាវុធ និងឯកសណ្ឋានដែលលោកបានឃើញ លោកបានស្តាប់ឮហ្នឹង តើលោកគិតថាគេត្រូវយកមកប្រើប្រាស់សម្រាប់កងទ័ពដែលត្រូវវាយប្រហារ និងដណ្តើមយកព្រលានយន្តហោះពោធិ៍ចិនតុងនោះដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានឮហើយ បានខ្ញុំថា ខ្ញុំអត់ដែលបានឮគេថាវាយយក ដណ្តើមយកពោធិ៍ចិនតុងឯណា អត់ដែលបានឮទេ។

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោក ពាក់ព័ន្ធទៅនឹងយុទ្ធជនកងពល៣១០ ដែលមានតួនាទីដូចលោកដែរ ឬក៏ថាធំជាងលោកបន្តិចបន្តួចគឺ E3/7516, ERNអង់គ្លេស 00876520, ខ្មែរ 00020598, បារាំង 00892665។ សែម ហឿន ក៏បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះដែរ។ ហើយនិយាយថា៖ “យើងត្រូវបានគេបញ្ជាឲ្យត្រៀមខ្លួនរួចជាស្រេច ពេលណាដល់ពេលវេលាយើងទៅដឹកជញ្ជូនអាវុធទាំងនេះ ត្រូវដឹកអាវុធទៅកាន់កន្លែង សុន សេន នៅពោធិ៍ចិនតុងដើម្បីវាយប្រហារនិងដណ្តើមកាន់កាប់ព្រលានយន្តហោះពោធិ៍ចិនតុង វាយប្រហារដណ្តើមឃ្លាំង<កាំភ្លើងធំមួយ> ឃ្លាំងរថ<ក្រោះ។ ហើយកងវរសេនាតូចមួយទៀត ត្រូវបានបញ្ជាឲ្យត្រៀម>វាយដណ្តើមយក<ស្ថានីយ៍>វិទ្យុ<>។ ក៏ប៉ុន្តែផែនការរដ្ឋប្រហារនេះក៏ត្រូវបានលេចឮ អ៊ីចឹងអ្នកដែលពាក់ព័ន្ធទាំងអស់ ក៏ត្រូវបានចាប់ខ្លួន ហើយយុទ្ធជនថ្នាក់តូច<ម្នាក់នៃកងពល៣១០ ដែល>ត្រូវបញ្ជូនទៅព្រលានយន្តហោះ<កំពង់ឆ្នាំង

ដឹងរឿងនេះ>។” ហើយចំណុចនេះជួយរំឭកដល់ការចងចាំរបស់លោកបានទេ?

[១៤:១១:៣៦]

**ឆ៖** ខ្ញុំអត់ដែលបានទៅពោធិ៍ចិនតុងនឹងគេទេ អត់បានដឹងថាខ្ញុំ--។ រឿងផែនការគេៗដឹង ខ្ញុំមិនអត់ដឹងអីទេ។ គ្រាន់តែឃើញនៅនឹងកងខ្ញុំប៉ុណ្ណោះឯង ឃើញក៏គេមិនទាន់មានរដ្ឋប្រហារអី គេចាប់ទៅប៉ុណ្ណោះឯងទៅ ខ្ញុំដឹងតែប៉ុណ្ណោះឯង។ រឿងទៅពោធិ៍ចិនតុងទៅអីណាខ្ញុំមិនដែលដឹងផង មិនដែលដឹងបានទៅ ៗចូលតែម្តងពេលរំដោះបានក៏ចូលទៅមួយសន្ទុះ ក៏មកនៅវត្តភ្នំវិញ ក៏នៅរហូត។ មិនដែលគេឲ្យដើរទៅណាផង។

**ស៖** មិនថ្វីទេលោកសាក្សី ដោយសារលោកខ្លួនឯងនេះគឺថា មិនចូលរួមពាក់ព័ន្ធនឹងរដ្ឋប្រហារនេះដោយផ្ទាល់នោះទេ។ ប៉ុន្តែខ្ញុំសូមអានសម្រង់ចេញពីចម្លើយរបស់យុទ្ធជនកងពល៣១០ដែរ ក្រែងលោវាអាចជួយដល់ការចងចាំរបស់លោកគឺE3/509។ នេះគឺជាកំណត់ហេតុស្តាប់ចម្លើយរបស់យុទ្ធជនមកពីកងពល៣១០ ERN អង់គ្លេស 00282217, ខ្មែរ 00270159 ដល់60, បារាំង 00285597 ដល់<98>។ សូមអានសម្រង់នេះឲ្យលោកស្តាប់៖ “មានថ្ងៃមួយនោះគេបានហៅខ្ញុំឲ្យទៅប្រជុំនៅជិតវត្តភ្នំដែលនៅទីនោះ តាឃឹម ដែលជាមេបញ្ជាការវរសេនាតូច បាន<ប្រកាសប្រាប់>យុទ្ធជន<វរសេនាតូច៣០៦> ពាក់ព័ន្ធទៅនឹងផែនការធ្វើរដ្ឋប្រហារ។ គាត់និយាយថានៅម៉ោងបីព្រឹក យើងនឹងបើកការវាយប្រយុទ្ធ ហើយដណ្តើមកាន់កាប់វិទ្យុផ្សាយសំឡេងនៅជិតវត្តភ្នំ ដើម្បីធ្វើការប្រកាស។ នៅយប់នោះ តាអឿន, តាស៊ីនួន អតីតមេបញ្ជាការកងវរសេនាតូចលេខ<៣០៦ ជាមួយនឹង តាអឿន ពេលនោះនៅខាងក្រសួងពាណិជ្ជកម្ម,> តាបន មេបញ្ជាការវរសេនាធំ ហើយនិង តាឃឹម <មេបញ្ជាការវរសេនាតូច> ត្រូវបានអង្គការថ្នាក់លើហៅទៅចូលប្រជុំ ហើយក៏បាត់ខ្លួនទាំងអស់ទៅ។” ខាងក្រោមនេះបន្តិច៖ “តើលោកជឿ<ថា ពិតជាមាន>ផែនការនោះទេ? ឆ្លើយថា៖ <បាទ ជាការពិត> ពីព្រោះថាមានយុទ្ធជនប្រហែលជា៣០០នាក់ បានចូលរួមប្រជុំនៅម៉ោង<បួនល្ងាច> ហើយ តាឃឹម គាត់ប្រកាសអំពីផែនការធ្វើរដ្ឋប្រហារហ្នឹង <ហើយក្រោយមកមានការរៀបចំ>អាវុធ<>។” បញ្ចប់ការដកស្រង់។ តើចំណុចនេះវាជួយធ្វើឲ្យលោកនឹកឃើញទេលោកសាក្សី?

[១៤:១៤:៤៩]

**ឆ៖** បាទ ខ្ញុំអត់មានបានដឹងឮលើផែនការរបស់គេទេ។ បើនឹកឃើញអី បើខ្ញុំអត់បានមានការពាក់ព័ន្ធជាមួយគេ គេអ្នកឆ្លើយអីចឹងគេអ្នកដឹង ខ្ញុំអត់ដឹង។ ខ្ញុំនៅតែមួយក្រុម ខ្ញុំនៅ ប៉ុន្តែគេនៅជាប់នឹង

វរៈជាប់នឹងអី គេដឹង។ បើដូចខ្ញុំនៅឯកាតែមួយក្រុមសេដ្ឋកិច្ច មានដឹងអី។ ខ្ញុំមានចម្លើយតែប៉ុណ្ណោះឯង បើអត់ដឹង ខ្ញុំថាអត់ដឹង បើដឹងខ្ញុំឆ្លើយថាដឹង។

**ស៖** ដូច្នេះអ្វីដែលលោកដឹងនោះគឺដឹងតែអំពីខោអាវ អំពីអាវុធ <និងស្បែកជើង>តែប៉ុណ្ណោះទេ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ បើឃើញរៀបអាវុធ ហើយនិងខោអាវ អានោះខ្ញុំឃើញប្រាកដមែន នៅទល់មុខនឹងឃោសនាឯង ផ្ទះបណ្ដោយថ្ងៃ។ នៅអានោះខ្ញុំឃើញមែន ប៉ុន្តែឃើញតែក្នុងអង្គភាព១១នោះទេ ប៉ុន្តែរឿងគេទៀត ខ្ញុំអត់បានឃើញសោះ។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទចុងក្រោយ ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឮនៅក្នុងការទាក់ទងជាមួយនឹងវៀតណាម ដែលទាក់ទងជាមួយនឹងកងទ័ព ហេង សំរិន, ហ៊ុន សែន។ តើនេះវាជាភារកិច្ចក្នុងការតាមដានខ្មាំងរបស់លោកឬ ដែលលោកបានស្ដាប់ឮទំនាក់ទំនងតាមវិទ្យុរវាងកងទ័ពវៀត-ណាម ជាមួយទ័ព ហេង សំរិន, ហ៊ុន សែន នេះ?

[១៤:១៦:៤៤]

**ឆ៖** កាលជំនាន់នោះ ខ្ញុំកាន់វិទ្យុទាក់ទងមែន តែខ្ញុំបើកមានម៉ោង តែឮខ្មែរនិយាយ ណែនាំមកតាមវិទ្យុខ្ញុំនោះឯង កុំឱ្យខ្ញុំវាយប្រហារទៅលើវៀតណាម ព្រោះថាពួកផ្ទៃក្នុងខាងក្នុងនេះ គេសម្លាប់ជិតអស់ទៅហើយ ឯងត្រូវថយក្រោយទៅ។ ខ្ញុំឮតែប៉ុណ្ណោះហើយ ខ្ញុំអារឿងវិទ្យុទាក់ទងកាលនោះ ក៏មិនមែនបើកសេរី បើកតែក្នុងមួយភ្លែតៗទេ។ យើងបើកសេរី គេចាប់កំហុសយើងទៀត ម្ល៉ោះហើយអត់ហ៊ានបើកទេ។ បើតែមានការប្រយុទ្ធគ្នា ហើយនិងមានការទាក់ទងរាយការណ៍អីប៉ុណ្ណោះ បិទទៅ។ អត់មានទៅនិយាយអីវែងឆ្ងាយបានទេ។

**ស៖** ក៏ប៉ុន្តែ<តើ>លោកស្ដាប់ឮ<រឿងនេះ> តាមរយៈ*កាណាល់*របស់យោធាគេប្រើហ្នឹងឬ? ហើយតើលោកបានស្ដាប់ឮសូរអ្វី<ខ្លះ>ដែរ <តាមរយៈ*កាណាល់*របស់>កងទ័ពវៀតណាមនេះ?

**ឆ៖** ខ្ញុំអត់បានស្ដាប់ឮគេនិយាយគ្នាពីរឿងធ្វើសកម្មភាពម៉េចៗនោះ អត់បានឮទេ។ ឮតែជេរគ្នាទៅវិញទៅមក វាឈ្លោះ វៀតណាមចុចមក ក៏ជេរទៅ ឌូម៉ែ អាខ្ញុំក៏មិនចេះភាសា ក៏អាយួនស៊ីកន្ទក់ស៊ីអីទៅ ប៉ុណ្ណោះឯង។ ប៉ុណ្ណោះគេលួចតាមដានទៀត គ្រាន់តែជេរគ្នាប៉ុណ្ណោះ គេតាមដាន គេបិទទៅ អត់ហ៊ាននិយាយទេ។ តែវិទ្យុក៏បើកស្ដាប់ខ្មែរ ក៏មិនបានដែរ ស្ដាប់ឮដល់គេ ៗចាប់កំហុសយើងភ្លាម។ ត្បិតតែនៅកងទ័ពមែន ប៉ុន្តែគ្មានសិទ្ធិទេ តែសិទ្ធិតែក្រោមបទបញ្ជាគេ តែប៉ុណ្ណោះហើយ។ ខ្ញុំមានមតិប៉ុណ្ណោះ

ឯង។

[១៤:១៩:១១]

**ស៖** បើខ្ញុំស្ដាប់មិនច្រឡំទេ លោកស្ដាប់ឮសូរគេនិយាយជាភាសាខ្មែរនោះនៅលើ*កាណាល់*របស់កងទ័ពវៀតណាម ហើយលោកថា សំឡេងជាភាសាខ្មែរដែលលោកស្ដាប់ឮតាមរយៈវិទ្យុទាក់ទងរបស់វៀតណាមហ្នឹងគឺ ហើយជាសំឡេងទ័ពរបស់ ហេង សំរិន ឬក៏ជាសំឡេងកងទ័ពរបស់ ហ៊ុន សែន មែនទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមទោសលោកមេធាវី ប្រហែលជាខ្ញុំស្ដាប់មិនទាន់។ ប៉ុន្តែ>តើពេលណាដែលគាត់និយាយថាគាត់<គិតថា គាត់>បាន<>ស្ដាប់*កាណាល់*របស់វៀតណាមហ្នឹង? <តាម>អ្វីដែល<ខ្ញុំយល់នោះគឺ>គាត់<មិន>ដឹង<ថា តើប្រភេទ*កាណាល់* ណាដែលគាត់បានស្ដាប់ផង។ អ្វីដែល>គាត់ស្ដាប់ឮសូរគេនិយាយភាសាខ្មែរ ហើយនិងស្ដាប់ឮសូរភាសាវៀតណាម។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាសំណួរសួរបញ្ជាក់នៅអ្វីដែលគាត់បានឆ្លើយនៅជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជានៅត្រង់ទំព័រ១៦។ គាត់ថា៖ "នៅពេលមានការវាយប្រយុទ្ធគ្នាខ្លាំង យើងបើកវិទ្យុដើម្បីទាក់ទងជាមួយនឹងក្រុមកងទ័ពវៀតណាម និងកងទ័ព ហ៊ុន សែន, ហេង សំរិន។" ប្រហែលជាខ្ញុំច្រឡំចំណុចនេះ ក៏ប៉ុន្តែគាត់បាននិយាយថា គាត់បានស្ដាប់ឮសំឡេងនេះនិយាយជាភាសាខ្មែរ គឺមានសំឡេងនិយាយជាភាសាខ្មែរនៅប្រេកង់មួយ ប្រហែលជាប្រេកង់នេះត្រូវបានកងទ័ពវៀតណាមជាអ្នកប្រើ--។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*◌្◌ំ*<សូមសួរបញ្ជាក់ឲ្យបានច្បាស់លាស់។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹងសុំសួរបញ្ជាក់ឡើងវិញ។ លោកសាក្សី នៅពេលលោកស្ដាប់ឮសំឡេងជាភាសាខ្មែរ តើលោកស្ដាប់ឮសំឡេងដែលគេនិយាយខ្មែរហ្នឹង នៅលើប្រេកង់ដែលកងទ័ពវៀតណាមជាអ្នកប្រើនោះឬ?

[១៤:២០:៤៧]

**លោក សែម អំ៖**

**ឆ៖** បាទ ខ្ញុំឮសំឡេងនោះ ប្រហែលជាតេអូធំ ប្រហែលជាឲ្យតែម៉ោងបី ម៉ោងបីល្ងាចបានឮហើយ។ ម៉ោងបីល្ងាច ខ្ញុំលួចបើកទៅ ឮហើយ ឮនិយាយខ្មែរ ប៉ុន្តែខ្ញុំនិយាយដោយឡែកៗ។ ខាងវៀត-ណាមនិយាយផ្សេងទេ។ ខាងវៀតណាមមានវិទ្យុទាក់ទងគេផ្សេង ហើយខ្មែរគឺមានវិទ្យុផ្សេង។ ផ្សេងនោះ កាលថៃ -- ខ្មែរឮតែថ្ងៃល្ងាចទេ ឲ្យតែម៉ោងបី ម៉ោងបួន ចេញមកមួយសន្ទុះនោះឯង។ មួយសន្ទុះទៅក៏បាត់ទៅ តែប៉ុណ្ណោះ។ អានេះខ្ញុំនិយាយឲ្យដាច់លាក់។ វៀតណាមនោះផ្សេងទៅ។ ទាក់ទងចំវៀត-ណាម បើកទៅចំវៀតណាម ក៏និយាយជាមួយវៀត ឈ្លោះគ្នាជាមួយវៀតណាមទៅ។ ហើយបើកចំខ្មែរក៏និយាយខ្មែរមួយសន្ទុះអីទៅ ក៏លួចបិទទៅ អត់ហ៊ានបើកយូរ។

**ស៖** ប៉ុន្តែតើលោកឮសំឡេងហ្នឹង ជាសំឡេងកងទ័ពរបស់ ហ៊ុន សែន, ហេង សំរិន ដែលនិយាយនៅលើប្រេកង់របស់វៀតណាម ឬ<ក៏វាមានពាក់ព័ន្ធនឹង*កាណាល់*របស់វៀតណាម>? ខ្ញុំៗវាមិនច្បាស់ចំណុចកន្លែងនេះ លោកនិយាយឲ្យបានច្បាស់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សម្រាប់ខ្ញុំក៏មិនច្បាស់ដែរ <ថាវាគឺជា*កាណាល់*របស់>វៀតណាម។ <ខ្ញុំឆ្ងល់ តើគាត់មិនដឹងទាល់តែសោះអំពីកាណាល់ ដែលគាត់បានស្តាប់នោះ ឬក៏យ៉ាងម៉េច។ ប្រហែលជាងាយស្រួលយល់ ក្នុងការសួរសំណួរបែបនេះវិញ៖ លោកបានឮសំឡេងខ្មែរ និងសំឡេងវៀតណាម តើលោកឮសំឡេងទាំងអស់ហ្នឹងនៅលើ*កាណាល់*មួយណាដែរ>?

[១៤:២២:៣៥]

**លោក សែម អ៊ំ៖**

**ឆ៖** បាទខុសគ្នា។ ដូចខ្ញុំថា ដោយឡែកៗអ៊ីចឹង ខុសគ្នា។ ខ្មែរនិយាយផ្សេង វៀតណាមផ្សេង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ចុះសំឡេងដែលនិយាយឮជាភាសាខ្មែរ គេនិយាយពីអ្វីដែរ? តើគេនិយាយអំពាវនាវឲ្យកងទ័ព<ខ្មែរហ្នឹងចុះចូលជាមួយភាគីម្ខាងទៀត គឺ> ចុះចូលជាមួយនឹងកងទ័ពវៀតណាមអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គ្រាន់តែគេនិយាយអំពាវនាវ ប្រាប់មកខាងខ្ញុំនេះថាឈប់តស៊ូទៅ។ ដូចខ្ញុំបាននិយាយហើយថា ឈប់តស៊ូទៅ ទម្លាក់អាវុធទៅ កុំខ្មែរ -- ម៉ែឪខាងក្រោយនោះ គេយកទៅសម្លាប់ចោលអស់ហើយ ឲ្យចូលរួបរួមគ្នាតស៊ូទៅ ដើម្បីវាយកម្ចាត់នោះឯង។ ខ្ញុំឮតែប៉ុណ្ណោះឯង មិនមែនថា ដឹងពី ហ៊ុន

សែន ដឹងពីណាទេ ប៉ុន្តែខ្មែរគឺឮខ្មែរមែន ខ្ញុំចាប់បានសំឡេងហ្នឹង គេអូធំ។ គេអូហ្នឹងប្រហែលជាសេ៤៦ ញវ៉ី ចាប់ ចុចមកញវ៉ី។ គេអូល្អមៗ គាត់គប់បាត់ ដាច់បាត់ទៅណា។ អានេះខ្ញុំចាំបាន។

**សៈ** ខ្ញុំព្យាយាមជួយរំឭកដល់ការចងចាំរបស់លោកបន្ថែមបន្តិចទៀត។ ខ្ញុំយោងទៅលើសៀវភៅ<របស់ ប៉ែន យៀវនិន គឺ E3/1593> អង់គ្លេស 01150194, ខ្មែរ 00637826 ដល់27, បារាំង <00639154>។ ខ្ញុំនឹងអានសម្រង់នេះ ហើយសួរទៅលោកមើល តើអាចជាអ្វីដែលលោកបានស្តាប់ឮពេលនោះឬក៏អត់ទេ។

ប៉ែន យៀវនិន គាត់បានយកព័ត៌មានពីអ្នកផ្តល់ព័ត៌មានដូចតទៅ៖ "នៅថ្ងៃទី២២ ធ្នូ រថក្រោះវៀតណាមពីរបានបើកមក<តំបន់>កណ្តាលជ្រុំ ដើម្បីមកទាក់ទងជាមួយនឹង សោ ភឹម។ ហើយបន្ទាប់មករថក្រោះទាំងអស់នោះ ក៏ត្រឡប់ក្បាលទៅកាន់ព្រំដែនវិញ។ នៅខាងក្នុងរថក្រោះនោះ គឺហាក់មានជនបដិវត្តន៍ខ្មែរមួយចំនួនដែលបានរត់គេចចូលទៅវៀតណាម មាន ហ៊ុន សែន, ហ៊ឹម សាមីន និងប្រាំបីនាក់ផ្សេងទៀតនោះ បានអមដំណើរកងទ័ពវៀតណាម ដោយឆ្លងកាត់ព្រំដែនជាច្រើនកន្លែង។ សាមីនបានព្យាយាមលបចូលមកក្នុងខេត្តស្វាយរៀងស្លៀកពាក់ខោអាវខ្មៅជាមួយ<ក្រុមមួយដែលមាន>អង្គរក្ស១០នាក់។ គាត់<បានឮអំពីការឈឺចាប់របស់>ប្រជាជន ហើយប៉ុន្តែគាត់មិនឲ្យកម្មាភិបាលណាឃើញគាត់ទេ។ <យើង>ព្យាយាមទាក់ទង ប៉ុន្តែ<យើង>មិនអាចទាក់ទងបាន។" បញ្ចប់ការដកស្រង់។

លោកសាក្សី ខ្ញុំសង្ឃឹមថា លោកយល់អំពីសម្រង់មួយនេះ ទោះវាវែងបន្តិចក៏ដោយ។ តើសំឡេងដែលលោកស្តាប់ឮ អាចជាសំឡេងជនជាតិខ្មែរដែលជាសំឡេងរបស់ជនបដិវត្តន៍ខ្មែរ ដោយមានការចូលរួមជាមួយនឹងកងទ័ពវៀតណាម ដោយអំពាវនាវឲ្យលោកហ្នឹងចុះចូលជាមួយនឹងខាងកងទ័ពវៀតណាម វាអាចអ៊ីចឹងទេ?

[១៤:២៦:៥០]

**ឆះ** បាទ ខ្ញុំឮអ៊ីចឹងមែន។ ឮខ្មែរហ្នឹងចុចគេអូមក ក៏ឲ្យរួបរួមគ្នា ចូលពួតដៃគ្នាវាយរំលំ វាយប្រហារទៅលើ ប៉ុល ពត នេះឯង។ ប៉ុន្តែនេះខ្ញុំក៏មិនជឿ អត់ជឿទេ នៅជជែក *(ឮមិនច្បាស់)* នោះឯង ខ្ញុំអត់ដឹងថា គេតស៊ូអី អត់ដឹងដែរ។ មិនបានដូចខ្មែរនៅវៀតណាមនោះឯង។ ប៉ុណ្ណោះឯង ខ្ញុំដឹង ព្រោះខ្ញុំនៅតែក្នុងព្រៃ តាំងពីទៅព្រំដែន មិនដែលនៅវាលនឹងគេទេ នៅតែនៅក្នុងព្រៃ។ មួយក្រុមអីនៅក្នុងព្រៃទៅ មាត់ត្រពាំងត្រង់ណា ក៏នៅត្រង់ណោះឯង។ បើថាឲ្យដឹងរឿងហ្នឹងគេ ពីចេះមួយចុះពីរ គឺមាន អត់ដឹងទេ ដឹងតែថា ពេលវ៉ៃគ្នា ក៏ស្លាប់។ របាយការណ៍របួសប៉ុន្មាន ស្លាប់ប៉ុន្មាន ខ្មាំងចូលពីខាងណោះ ពី

ខាងណោះ ហើយប្រាប់យុទ្ធជនថា គេព័ទ្ធពីក្រោយពីមុខ។ អាន់ុងក្តាប់ជាផែនការនោះឯង។ តែរឿងការស្លាប់ រឿងការតស៊ូតអី គឺអត់ដែលបានដឹងទេ។ រឿងថារាយការណ៍តែពីរឿងថា ទាហានស្លាប់ប៉ុន្មាន របួសប៉ុន្មាន អស់គ្រាប់អស់អី អាហ្នឹងគឺប្រាកដប្រជាមែន។ បើថារឿងការស្តីឯណាណើ គឺអត់មានដឹងទេ។ នៅដូចសត្វក្នុងព្រៃអ៊ីចឹង មូសខាំម្យប់ៗ ខ្ញុំមិនដឹងរឿងគេទេ អត់ដឹងទេ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់អំពីចំណុចនេះ។ មានសំណួរតូចៗពីរចុងក្រោយ។ យើងមានសាក្សីម្នាក់ទើបតែផ្តល់សក្ខីកម្មថ្មីៗ លោកសាក្សី ដែលនិយាយអំពីយោធាឈរជើងនៅជ្រោយចង្វា លោកក៏ឈរជើងនៅទីនោះដែរ នៅស្ពានជ្រោយចង្វា។ នៅថ្ងៃទី០១ កញ្ញា ឆ្នាំ២០១៦ នៅម៉ោងប្រាំបួន<និងម្ភៃនាទី>ព្រឹក ទាហានគឺថាលួចស្បៀក<ជើង ឆ្នាំង និងម្ហូបអាហារ>ពីជនស៊ីវិល។ តើក្រុមរបស់លោក កងរបស់លោក មានចូលរួមលួចយករបស់របរមាន<ម្ហូបអាហារ> ស្បៀកជើង អង្ករជាដើម ។ល។ ដែរឬទេ?

[១៤:២៩:៤៧]

**ឆ៖** អត់ទេ កងខ្ញុំនៅឯនោះ អត់មានដែលលួចយកស្បៀកជើង ឬទឹកដោះគោអី គ្មានទេ។ មួយកន្លែងនោះខ្ញុំនៅជាប់ជាមួយកងពលទី៣ផង មួយកងពលទី៣មួយកន្លែង ខ្ញុំនៅមួយកំណាត់មកត្បូង គេនៅទៅជើង។ អានោះក្រែងពាក់ព័ន្ធនឹងគេណោះ ខ្ញុំអត់ដឹងទេ រឿងកងគេខ្ញុំអត់ដឹងផង។ កងគេផ្សេងគ្នា ខ្ញុំនៅកងខ្ញុំមួយក្រុមតើ នៅគល់ជ្រោយចង្វា សេដ្ឋកិច្ច។

**ស៖** ហើយសំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងឯកសារនេះ ដែលថាលោកនិយាយថា លោកមិនបានអានដោយផ្ទាល់ទេតែលោកបានស្តាប់ឮពីគេ គឺឯកសារនិយាយអំពីការផ្តល់ជំនួយពីសហរដ្ឋអាមេរិក។ តើលោកមានបាន<អាន ឬ>ស្តាប់ឮឈ្មោះភ្នាក់ងារសម្ងាត់អាមេរិកាំងណាម្នាក់នៅក្នុងឯកសារនេះដែរឬទេ?

**ឆ៖** បាទ អត់បានដឹងទេ អត់បានដែលឮពីឯកសារអី ភ្នាក់ងារអី អាមេរិកាំងបានទាក់ទងជាមួយ តាអឿន តាអីគឺអត់បានដឹង អត់។

**ស៖** ចុះឈ្មោះ រីឆាត មេសស្ល័រ – <អឹម-អ៊ី-អេស-អេស-អិល-អ៊ី-អ័រ>។ តើលោក រីឆាត មេសស្ល័រ នេះ លោកអាចនឹកឃើញទេ?

**ឆ៖** អត់ៗដឹងទេ អត់ដឹង មិនទាំងស្គាល់មុខ ឬសំឡេងម៉េចទេ អត់ អត់មានដឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣២ នាទី ដល់ម៉ោង ១៤:៥១ នាទី)*

[១៤:៥០:៤២]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញលោកព្រះរាជអាជ្ញា តាំងសំណួរលើសាក្សីរូបនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី ខ្ញុំសូមចាប់សួរបន្តពីអ្វីដែលអ្វីមេធាវីការពារក្តីទើបតែបានសួរលោក គឺនិយាយអំពីការផ្សាយវិទ្យុដែលលោកបានស្តាប់ឮ <នៅពេលដែលលោកនៅ>សមរភូមិ<នៅខាងបូព៌ា>។ តើលោកប្រាប់បានទេថាក្នុងឆ្នាំ៧៨ហ្នឹង នៅក្នុងខែណាដែលគេបញ្ជូនលោកទៅសមរភូមិនៅខាងបូព៌ា?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារ លោក គួន ជា!

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំគិតថាមិនមែន៧៨ទេ គឺ៧៧ដែលគាត់ត្រូវគេបញ្ជូនទៅ គាត់និយាយអំពីកងទ័ពវៀតណាមចូលនៅក្នុងខែតុលាការ ៧៧ រហូតដល់ខែ<មករា> ៧៨។

[១៤:៥២:៣៣]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ឌេល លីសាក់៖**

ប្រាកដជាខុសហើយ ព្រោះលោកសួរគាត់ផ្ទាល់ហ្នឹងគឺថាក្នុងឆ្នាំ៧៨។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវខ្ញុំសួរអ៊ីចេះ តើលោកសាក្សី តើក្នុងឆ្នាំ៧៧ ឬក៏៧៨ នៅពេលដែលលោកទៅសមរភូមិនៅខាងបូព៌ា?

**លោក សែម អ៊ំ៖**

**ឆ៖** ប្រហែលជាចុង៧៧ ដើមឆ្នាំ៧៨ ព្រោះខែនោះវារងាហើយ។

**ស៖** តើនៅពេលណាដែលលោកបានស្តាប់ឮការប្រកាសតាមវិទ្យុ ដែលគេអំពាវនាវឲ្យប្រឆាំងរបបប៉ុលពត? តើគេប្រកាសភ្លាមៗក្រោយពេលដែលលោកទៅដល់ ឬមួយក៏នៅពេលក្រោយ<មកទៀត នៅចុងបញ្ចប់ពេលដែលលោកនៅក្នុងភូមិភាគបូព៌ា>?

**ឆ៖** បាទ នៅយូរអ្នក! ខ្ញុំនៅរាប់ខែហើយ ខ្ញុំនៅត្រពាំងថ្កុង នៅបួនប្រាំខែ បានឮ។

**ស៖** អ៊ីចឹងមានន័យថា ពាក់កណ្តាលឆ្នាំ៧៨ <តើត្រឹមត្រូវដែរឬទេ?> តើលោកអាចប្រាប់បានទេថា ប៉ុន្មានខែដែរមុនពេលវៀតណាមចូលមកក្នុងប្រទេសកម្ពុជា <នៅក្នុងចុងឆ្នាំ៧៨ ឬក៏ដើមឆ្នាំ៧៩>? ខ្ញុំចង់សួរថាមុនពេលដែលវៀតណាម បើធៀបជាមួយពេលវៀតណាមចូលមកកម្ពុជាហ្នឹង តើប្រហែលជាប៉ុន្មានខែដែរ ដែលគេប្រកាសតាមវិទ្យុឲ្យផ្តួលរំលំរបបប៉ុលពតនោះ?

**ឆ៖** បាទ ក្នុងអំឡុងប្រហែលជាកន្លះខែ ក៏ឮគេប្រកាសតាមវិទ្យុនោះឯង។ ដល់ជិតដាច់ខែក៏ជិតប្រហែលពាក់កណ្តាលខែ៨ បានជិតដល់ខែ៩ បានខ្ញុំឮគេប្រកាស ក៏បែកបាក់គ្នា នាំគ្នារត់ ខ្ញុំកាត់ព្រៃមកបាទ រត់តាមព្រៃ។

[១៤:៥៥:១២]

**ស៖** សូមអរគុណ។ មិនអីទេ ខ្ញុំនឹងលើកមកនិយាយនៅពេលស្អែក។ ឥឡូវនេះខ្ញុំនឹងសួរបន្ថែមបន្តិចអំពីប្រវត្តិរូបរបស់គាត់។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ដល់សាក្សីនេះនូវឯកសារដែលមាននៅក្នុងការសម្ភាសមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7523 គឺមានតែភាសាខ្មែរទេគឺ 00058077 គឺជាប្រវត្តិរូបមួយសន្លឹករបស់គាត់ជាភាសាខ្មែរ។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ប្រគល់ឯកសារនេះជូនដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកមើលទៅលើឯកសារដែលប្រគល់ជូនលោក ហើយលោកអាចបញ្ជាក់បានទេថាហ្នឹង គឺជាប្រវត្តិរូបដែលលោករៀបចំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែនទេ?

**លោក សែម អំ៖**

**ឆ៖** បាទ ហ្នឹងហើយជាប្រវត្តិរូបរបស់ខ្ញុំ ប៉ុន្តែមើលមិនស្គាល់ទេ ដាច់ៗអស់រលីងអ៊ីចេះ។ ចំណាំតិចណាស់នេះ ឃើញជា ព្រុំ អំ។ អានេះគឺប្រាកដមែនហើយបាទ ប្រវត្តិរូបខ្ញុំ។

**ស៖** សូមអរគុណ។ ខ្ញុំដឹងថាវាមានផ្នែកខ្លះមើលមិនដាច់ ផ្នែកខ្លះវាថតមិន ចម្លងមិនល្អ ប៉ុន្តែខ្ញុំបានគូសពណ៌មួយចំនួននៅលើផ្នែក។ ឥឡូវយើងមើលទៅលើកាលបរិច្ឆេទនៅខាងចុង ថាតើវាត្រឹមត្រូវទេ ដែលថានេះគឺជាឯកសារប្រវត្តិរូបដែលលោករៀបចំដែលលោកបានសរសេរនៅថ្ងៃ១១ ឧសភា ៧៦?

[១៤:៥៧:៣៨]

**ឆ៖** បាទ ត្រឹមត្រូវហើយបាទ ត្រឹមត្រូវ។ នេះគឺប្រវត្តិរូបរបស់ខ្ញុំមែននោះឯង។ គេឲ្យខ្ញុំមួយហើយ ប៉ុន្តែខ្ញុំមើលអត់ស្គាល់ ស្គាល់មួយដុបៗ តិចៗ វារលុបអស់ ប្រវត្តិរូបសង្ខេប។

**ស៖** ប្រសិនបើលោកពិនិត្យមើលទៅលើផ្នែកដែលខ្ញុំបានគូសពណ៌ គឺកថាខណ្ឌ៩ និង១០។ កថាខណ្ឌ៩ បានបញ្ជាក់អំពីថ្ងៃចូលបដិវត្តន៍ដែលបញ្ជាក់ថាឆ្នាំ៧៣។ ហើយនៅជួរបន្ទាប់ កថាខណ្ឌទី១០នោះ គឺថ្ងៃចូលយុវកកដែលលោកចូលនៅថ្ងៃ០៧ វិច្ឆិកា ឆ្នាំ៧៤។ តើវាត្រឹមត្រូវទេដែលថាលោកចូលក្នុងយុវកកហ្នឹងនៅខែវិច្ឆិកា ឆ្នាំ៧៤?

**ឆ៖** បាទ ប្រហែលជាប៉ុណ្ណោះហើយ ខ្ញុំចូលយុវកកនៅព្រៃទទឹងយើង ៗនៅកំពង់ចាម ព្រៃទទឹង នៅនឹងព្រៃ ក្នុងព្រៃ។ ខែនោះហើយដឹង ខ្ញុំភ្លាប់មិនបានដែរ ដឹងគេបញ្ចូលៗ។ មិនដែលនឹងបាននឹងមើលឯកសារជំនាន់នោះ។

**ស៖** ហើយនៅជួរចុងក្រោយដែលខ្ញុំចង់សួរលោកផងដែរ គឺជួរទី១៣ ដែលនិយាយអំពីតួនាទីបច្ចុប្បន្ន។ គឺថាលោកសរសេរនៅត្រង់ នៅក្នុងឯកសារនេះ គឺជាអនុប្រធានក្រុម។ តើលោកអាចប្រាប់បានទេ លោកសរសេរថាយ៉ាងម៉េចដែរនៅក្នុងតួនាទីបច្ចុប្បន្នហ្នឹង គឺតួនាទីនៅថ្ងៃ១១ ឧសភា ៧៦ហ្នឹង?

**ឆ៖** ខ្ញុំអត់បាននៅប្រធានក្រុមទេ។ ខ្ញុំនៅខាងនីរសារទេ។ អានេះគេដាក់ប្រធានក្រុម អត់ទេ។ បច្ចុប្បន្នជាអនុក្រុម អត់បាននៅអនុក្រុម អនុអឺ អត់។

**សៈ** សូមលោកអានឲ្យខ្ញុំស្ដាប់បន្តិចបានទេ នៅត្រង់<បន្ទាត់ទី១៣>ដែលនិយាយអំពីតួនាទីបច្ចុប្បន្នហ្នឹង? តើលោកសរសេរយ៉ាងម៉េចនៅក្នុងប្រវត្តិរូបរបស់លោកនោះ?

[១៥:០០:៥៤]

**ឆៈ** ធ្វើនៅថ្ងៃទី ភូមិអីទេ អត់អីទេ រលុបបាត់ហើយ ខ្ញុំមើលមិនស្គាល់។ អានេះធ្វើនៅថ្ងៃទី១១ ខែ៥ ទី៧២ ចិតប៉ុន្មាន ចិត! សែម អ៊ាត នេះឈ្មោះខ្ញុំមែនហើយ។

**សៈ** មិនអីទេ លោកសាក្សី។ លោកបញ្ជាក់ថា នៅក្នុងកងពល៣១០ លោកនៅក្នុង<វរសេនាធំ>១៣។ តើលោកចាំទេថា <>លោកនៅក្នុងវរសេនាតូចមួយណា?

**ឆៈ** នៅវរសេនាតូច១៣។ កាលពីដើមកងវរសេនាធំ ដល់បែកអស់ទៅ នៅវរសេនាតូច១៣។

**សៈ** នៅពេលដែលលោកនិយាយថា គេបំបែកហ្នឹង តើគេបំបែកហ្នឹងនៅពេលណាដែរ?

**ឆៈ** គេធ្វើស្រែ ដើមប្រហែលជាដើមឆ្នាំ៧៧។ ៧៧គេរំសាយអស់ អត់ដឹងគេរំសាយទៅណាទេ ប៉ុន្តែបាត់អស់តែម្ដង បាត់។ ក៏ខ្ញុំទៅនៅ គេឲ្យខ្ញុំទៅនៅខាងកប់ស្រូវ ខាង១៣នេះឯង។ ខ្ញុំបែកពីកន្លែងខ្ញុំនៅ ពីជ្រោយចង្វាទៅ ខ្ញុំទៅនៅស្រែ នៅវាលកប់ស្រូវ អន្លង់ក្ងាន បឹងបាយ៉ាប។ ប៉ុន្តែថាឲ្យរឿងថាគេ តែទ័ពនោះមិនដឹងបាត់ទៅណាទេ មិនដឹងគេដកទៅណាទីណាទេ។ តែនៅមួយកងខ្ញុំហ្នឹង ពីដើមវា ៥០០ យូរៗទៅក៏នៅ៣០០ វាបាត់អស់ មិនដឹងគេដកទៅណា មិនដឹងគេដកទៅណី ខ្ញុំមិនសូវដឹងគេដែរ។

**សៈ** មុនពេលគេរំសាយនុ៎ង អ៊ីចឹងបានន័យថា មុនរំសាយហ្នឹងលោកនៅកងវរសេនាធំលេខ១៣។ ប៉ុន្តែខ្ញុំចង់សួរថា តើលោកនៅក្នុងកងវរសេនាតូចណាមួយនៃកងវរសេនាធំ<១៣>? តើលោកចាំថា វរសេនាតូចហ្នឹងលេខប៉ុន្មាន ឬក៏<តើនរណាជា>ប្រធានវរសេនាតូចហ្នឹងដែរ នៅក្នុងកងវរសេនាធំលេខ១៣ហ្នឹង?

[១៥:០៣:៥៦]

**ឆៈ** ពីដើមវាមានបីវរសេនាតូច។ បីវរសេនាតូចបានវាកើតមួយវរសេនាធំ។ វាមានវរសេនាតូច១៣ វរសេនាតូច១៥ វរៈណាមួយទៀតទេ ខ្ញុំចាំអត់បានផង។ វាមានបីវរៈ។ អាវរៈ១៥នោះ នៅខាងច្រាំងចំរេះ។ វរៈ១៣នោះនៅខាងកប់ស្រូវ។ វរៈមួយទៀតនោះនៅភ្នំពេញ ប៉ុន្តែ អ៎!នៅច្រឡូក ៗយើងបារាយណ៍ នៅធ្វើស្រែ។ ខ្ញុំគេឲ្យទៅនៅខាងវរៈ១៣ ខាងកប់ស្រូវ ខ្ញុំនៅវាលកប់ស្រូវបានចំនួនយូរអង្វាប់ប្រហែលជាមួយឆ្នាំមិនដឹង ខ្ញុំទៅធ្វើស្រែបាចទឹក បាច ជីកប្រឡាយជីកអី ដកសំណាប។ អាហ្នឹងបានយូរដែរ ខ្ញុំនៅជិតយូរណាស់ ខ្ញុំនៅអន្លង់ក្ងាន១។ មុនដំបូងនៅកប់ស្រូវ ពីកប់ស្រូវមកនៅអន្លង់ក្ងាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ៗទៅបានមកនៅបឹងបាយ៉ាប អ៎!បាទបឹងបាយ៉ាប មានប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ បញ្ជាក់ឲ្យច្បាស់បន្តិច គឺខ្ញុំនិយាយអំពីឆ្នាំ៧៥ដល់៧៦។ មុនពេលដែលគេចាត់តាំងលោកឲ្យទៅ<កប់ស្រូវ និងបឹងប្រយ៉ាប> តើលោកជាផ្នែក ជាកងទ័ពនៅក្នុងកងវរសេនាតូចលេខ១៣ មែនទេ? ប្រសិនបើអ៊ីចឹង តើអ្នកណាជាមេបញ្ជាការវរសេនាតូចរបស់លោកនោះ?

**ឆ៖** កាលនៅជ្រោយចង្វានោះ ខ្ញុំនៅក្រុមនីរសារមួយក្រុម និងសេដ្ឋកិច្ច។ មួយក្រុមនៅនឹងជ្រោយៗ ស្ពានជ្រោយចង្វា ហើយក្រៅពីនោះ គេចេញធ្វើស្រែឲ្យអស់ហើយ នៅតែខ្ញុំមួយក្រុមដែលនៅនឹងជ្រោយចង្វានោះ។

**ស៖** អ៊ីចឹង<>លោកមិនមែន<>នៅក្នុងវរសេនាតូចណាមួយទេ លោកនៅក្នុងកងនីរសារ<នៃកងវរសេនាធំរបស់លោក តើអ៊ីចឹង>មែនទេ?

**ឆ៖** បាទ ខ្ញុំនៅក្នុងកងនីរសារ ហើយនិងសេដ្ឋកិច្ចមួយក្រុម ពេទ្យមួយក្រុមគ្នាខ្ញុំតែម្ដង។

[១៥:០៦:៥៥]

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកអំពីហេតុការណ៍មួយចំនួន ដែលលោកបាននិយាយនៅក្នុងការស្ដាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត ក្រោយពេលដែលលោកចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ៧៥។ តើលោកអាចប្រាប់បានទេថា មានអ្វីកើតឡើងចំពោះទាហាន លន់ នល់ ដែលលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញក្រោយពេលដែល<កងទ័ព>ខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ៧៥នោះ?

**ឆ៖** បាទ នៅថ្ងៃ១៧ ៧៥នោះ ខ្ញុំបានចូលទៅនៅទីក្រុងភ្នំពេញ។ ខ្ញុំទៅនៅយាមនៅវត្តភ្នំ នៅវត្តភ្នំបានខ្ញុំដកទៅនៅ គេអត់ប៉ានៅទេ គេឲ្យទៅនៅច្រេះវិញ។ បានល្ងាចនោះ គេបញ្ជូនខ្ញុំមកនៅក្បែរវត្តភ្នំ ទល់មុខកន្លែងឃោសនានេះឯង កន្លែងឃោនាការ។ ខ្ញុំនៅវត្តភ្នំ អ៊ីចឹងក៏ កាលនោះខ្ញុំនៅយាមនោះ អត់មានវ៉ៃទេ ស្ងាត់អស់ហើយ តែមានទាហានខ្លះលួចស្នាក់នៅតាមផ្ទះថ្ម លួចគប់គ្រប់បែក បាញ់កាំភ្លើងខ្លីមកលើខ្មែរក្រហមហ្នឹងឯង ស្លាប់ខ្លះ របួសខ្លះ ក៏ខ្ញុំគេដាក់បទបញ្ជាឲ្យបិទទឹក បិទទឹកក្នុងភ្នំពេញនេះ អត់មានឲ្យមានទឹកទេ។ បិទទឹកម៉ាស៊ីនទឹកអីអស់ បិទភ្លើង បិទទឹក ក៏ទាហាននោះ វាចេញមកពីរបីនាក់ ទៅក៏ខ្ញុំឃើញឈ្មោះ មិត្តរុំ ហើយគាត់ហៅ ៗទៅនិយាយដល់មួយសន្ទុះ ក៏គាត់អូសទៅអីមាត់ទន្លេ ចេញទៅមាត់ទន្លេ គាត់បានសម្លាប់អាទាហានបីនាក់នោះទៅ។ ខ្ញុំឃើញ អានោះខ្ញុំឃើញផ្ទាល់ភ្នែករបស់ខ្ញុំមែន។

[១៥:០៩:២៣]

**ស៖** ឥឡូវនេះ ខ្ញុំនឹងអានឲ្យលោកស្ដាប់នូវសម្រង់មួយចេញពីការស្ដាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត <ដើម្បីសួរបញ្ជាក់ត្រង់ចំណុចនេះ> គឺកំណត់ហេតុស្ដាប់ចម្លើយ E3/5149 គឺខ្មែរមានលេខ 00170633 ដល់34, ភាសាអង់គ្លេសមានលេខ 00205044 និងភាសាបារាំងមានលេខ 00524398។ ឥឡូវនេះខ្ញុំនឹងអានឲ្យលោកស្ដាប់នូវអ្វីដែលលោកបានឆ្លើយ ទាក់ទងទៅនឹងការសម្លាប់ <ដែលលោកបានឃើញផ្ទាល់ភ្នែក>។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំឃើញពួកគេសម្លាប់ទាហានដែលចុះចាញ់នៅស្ពានជ្រោយចង្វា។ ក្នុងចំណោមកងទ័ពទាំងនោះគឺមានប្រួន ទៅ១០នាក់ អ្នកខ្លះគឺដាច់ដៃ ហើយអ្នកខ្លះដាច់ជើង។ ហើយកងទ័ពរុញទម្លាក់ពួកគេចូលទៅក្នុងទឹកទន្លេ ហើយខ្ញុំឃើញដោយផ្ទាល់ភ្នែកមួយទៀតគឺ រុំ ដែលជាប្រធានកងអនុសេនា<ធំ>នៅក្នុងកងពល៣១០ បានបាញ់ទាហាន លន់ នល់ សក់វែងបីនាក់ នៅកំពង់ផែនៅមុខព្រះបរមរាជវាំង។"

ដូច្នេះខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិច តើហ្នឹងគឺជាហេតុការណ៍តែមួយដែលលោកនិយាយហ្នឹងដែលថាមានទាហានមួយចំនួនត្រូវបានគេរុញទម្លាក់ពីលើស្ពានជ្រោយចង្វា ហើយទាហានខ្លះទៀតត្រូវបានគេបាញ់នៅម្តុំកំពង់ផែនៅមុខវាំងហ្នឹង តើមែនទេ ឬមួយក៏វាជាហេតុការណ៍ផ្សេងពីហេតុការណ៍ដែលលោកបានដឹងកន្លងមក?

**ឆ៖** បាទ អានោះខ្ញុំឃើញផ្ទាល់ភ្នែកខ្ញុំមែន កាលណោះទាហានគេប្រមូលពីពេទ្យរុស្ស៊ី ទាហាននោះទាហានដាច់ដៃដាច់ជើង គេយកពីកន្លែងពេទ្យទៅ ពេទ្យរុស្ស៊ីទៅ។ យកទៅគេមានអីអី គេរុញទៅអាស្ពានជ្រោយចង្វាដែលដាច់មួយកំណាត់នោះ រុញទៅក៏គេច្រានទម្លាក់ទៅ។ អាណោះខ្ញុំឃើញមែនឃើញគេសម្លាប់មែន។ ហើយដូច តារុំ គាត់បាញ់សម្លាប់ទាហានបីនាក់នោះ គឺខ្ញុំឃើញមែន អានោះខាងត្បូងវត្តភ្នំ ខាងត្បូវវត្តភ្នំ។ បើអាកន្លែងសម្លាប់ច្រើនស្ពានជ្រោយចង្វានោះ គឺទាហានដែលគេប្រមូលពីមន្ទីរពេទ្យរុស្ស៊ី។ បាទ ខ្ញុំមានតែប៉ុណ្ណេះ។

[១៥:១២:២៧]

**ស៖** តើលោកចាំទេថា ការសម្លាប់ទាំងពីរលើកហ្នឹងកើតឡើងនៅពេលណាដែរ? តើក្រោយថ្ងៃ ១៧ មេសា ៧៥ ប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ ដែលមានហេតុការណ៍សម្លាប់ទាំងពីរនេះកើតឡើង?

**ឆ៖** បាទ នៅពេលនោះគឺវើចូលទីក្រុងភ្នំពេញភ្លាមហ្នឹងឯង គេបោសសម្អាតភ្លាមហ្នឹងឯង ប្រហែលរំលងមួយថ្ងៃ មិនមែនភ្លាមទេ ប្រហែលមួយថ្ងៃ ពីរថ្ងៃបានគេប្រមូលពួកនោះទៅ។ ប៉ុន្តែបើទាហានសក់វែងបីនាក់នោះបានយូរដែរ ទម្រាំគេបិទទឹក គេចេញមកប្រហែលជាប្អូនដប់ថ្ងៃ បានចេញ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មកពីក្នុងផ្ទះថ្ម។ សូមអស់។

**ស៖** អ៊ីចឹងមនុស្សដែលលោកឃើញគេសម្លាប់ គឺទាហានពិការនោះ គឺទាហានដែលគេរុញទម្លាក់ពីលើស្ពាន ហើយនិងទាហានសក់វែងបីនាក់ទៀតដែលគេបាញ់។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកធ្វើយ៉ាងម៉េចបានដឹងថា ពួកគេទាំងអស់ហ្នឹងជាអតីតទាហាន លន់ នល់?

**ឆ៖** បាទ វើៗចូលមក គេថា--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

[១៥:១៤:១៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធានដែលបានបញ្ជាក់ឡើងវិញ។ លោកប្រធាន ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ដោយសារតែសំណួរហ្នឹងវាក្រៅវិសាលភាពនៃសវនាការយើង <០០២/០២>។ ហើយខ្ញុំចង់ជម្រាបអង្គជំនុំជម្រះផងដែរថា ខ្ញុំបានធ្វើការសួរសំណួរប្រហាក់គ្នាអំពី<សមាជិកម្នាក់នៅក្នុង>កងពល<១៦៤> ទាក់ទងទៅនឹងគោលនយោបាយក្នុងការ -- ឬក៏មានអ្វីកើតឡើងភ្លាមៗក្រោយការរំដោះភ្នំពេញថ្ងៃ១៧ មេសា ៧៥។ នៅពេលនោះគឺគេហាមមិនឲ្យខ្ញុំសួរសំណួរនេះទេ ព្រោះថាអ្វីៗដែលកើតឡើងភ្លាមៗក្រោយពេលរំដោះទីក្រុងភ្នំពេញនោះ គឺវាមិនមែនជាផ្នែកមួយនៃសវនាការបច្ចុប្បន្នទេ គឺមិនមែនជាផ្នែកនៃសំណុំរឿង០០២/០២។ ហេតុដូច្នេះ ខ្ញុំជំទាស់ទៅនឹងការសួរសំណួរបែបនេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំមិនដឹងថាតើមេធាវីនិយាយពីអ្វីនោះទេ ប៉ុន្តែនេះគឺជាគោលនយោបាយក្នុងការកំណត់គោលដៅទៅលើទាហានលន់ នល់ ហើយនេះគឺជាផ្នែកនៃសវនាការយើងនេះ ហើយ<ចំពោះ>សំណួរទូទៅ<អំពីការ>ជម្លៀស <គឺមិនស្ថិតនៅក្នុងផ្នែកនៃសំណុំរឿងនេះមែន ក៏>ប៉ុន្តែ<ចំពោះ>ការកំណត់គោលដៅទៅលើទាហាន លន់ នល់ ហើយវាគឺជាផ្នែក<មួយ>សំខាន់<នៃសំណុំរឿងនេះ។ ហើយវាគឺជាភាពពាក់ព័ន្ធ>នៃការសួរសំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតបែបនេះនៅពេលដែលខ្ញុំសួរ។ ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធាន ឆ្លើយ<តប>បន្តិច <វាមិនមែនសួរអំពីគោលនយោបាយទេ> សំណួរហ្នឹងទាក់ទងនឹងអ្វីកើតឡើងភ្លាមៗ <ក្រោយថ្ងៃរំដោះ ថា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តើ>ឧក្រិដ្ឋកម្មសង្គ្រាម <ត្រូវបានប្រព្រឹត្តឡើង ឬក៏អត់ទេ។ ខ្ញុំមិនឃើញថា វាជាផ្នែកនៃការការចោទប្រកាន់គោលនយោបាយនោះទេ ហើយវាពាក់ព័ន្ធអំពី>កងពល១៦៤<> នៅពេលដែលខ្ញុំសួរ<គាត់ ថា តើ>អ្វីដែលគេធ្វើចំពោះទាហាន លន់ នល់ ដែលគេចុះចាញ់ហ្នឹង គឺខ្ញុំត្រូវបានគេហាមភ្លាមៗមិនឱ្យសួរតែម្តង។

[១៥:១៦:០៩]

**លោក ខេល លីសាក់៖**

លោកប្រធានប្រសិន បើគាត់បានពន្យល់នៅពេលហ្នឹង ប្រហែលជាអង្គជំនុំជម្រះមិនហាមគាត់ទេ ព្រោះថាអ្វីដែលយើងធ្វើគឺវាជាផ្នែកនៃសំណុំរឿង។

**ប្រធានអង្គជំនុំ៖**

បដិសេធន៍ការជំទាស់ អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ប្រហែលជាលោកភ្លេចសំណួរខ្ញុំហើយលោកសាក្សី ខ្ញុំចង់សួរថាតើលោកធ្វើយ៉ាងម៉េចបានដឹងថាមនុស្សដែលគេបាញ់សម្លាប់ ឬក៏ដែលគេសម្លាប់ហ្នឹងជាទាហាន លន់ នល់?

**លោក សែម អ៊ំ៖**

**ឆ៖** ខ្ញុំឮគេថាទាហាន លន់ នល់ ក៏ខ្ញុំថាតាមគេ។ ប៉ុន្តែប្រហែលជា លន់ នល់ មែនទេដឹង ប្រជាជនដឹង បើស្លៀកពាក់ស ស្លៀកពាក់ស៊ីវិលយើងទេ អត់មានស្លៀកពាក់ទាហានទេ។ បើគេថាទាហាន ថាតាមគេ។

**ស៖** តើទាហានទាំងពីរក្រុម គឺទាហានដែលគេរុញទម្លាក់ពីលើស្ពានជ្រោយចង្វា និងទាហានដែល<រុំ> បាញ់សម្លាប់ហ្នឹង តើពួកគេមានស្លៀកពាក់ឯកសណ្ឋានជាយោធាដែរឬទេ?

**ឆ៖** អត់មានទេ ស្លៀកពាក់ខោអាវយើងធម្មតា អត់មានស្លៀកពាក់ខោអាវទាហាន។

**ស៖** លោកបញ្ជាក់ថា មនុស្សបីនាក់ដែលគេបាញ់នៅក្បែរវាំងគឺ រុំ អ្នកបាញ់ហ្នឹង។ ដូច្នេះ ខ្ញុំចង់សួរថា រុំ ហ្នឹងជាអ្នកណា? <តើគាត់មានតួនាទីអីដែរ?>

[១៥:១៨:០៦]

**ឆ៖** រុំ នោះគាត់ជាអនុកង កងធំ វរៈនោះឯង។

**ស៖** តើ រុំ គាត់ទទួលបញ្ជាពីអ្នកណាដែរ ឱ្យមកសម្លាប់ទាហានទាំងអស់នេះ?

**ឆ៖** រ៉ុំ នោះគាត់ទទួលបញ្ជាពី តាហុន។ តាហុន គាត់បញ្ជា។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ តើ តាហុន ហ្នឹងគឺជាមេបញ្ជាការកងវរសេនាធំដែលលោកធ្វើការជានីរសារហ្នឹងមែនទេ?

**ឆ៖** បាទ នោះឯង ហុន ហ្នឹងនោះឯង – ហ៊ឹម ហុន។

**ស៖** លោកនិយាយអំពីទាហានបីនាក់ដែលគេបាញ់ គឺទាហានសក់វែងបីនាក់នោះ។ ខ្ញុំចង់ដឹងថាហេតុអ្វីក៏លោករៀបរាប់ទាហានហ្នឹងដោយផ្តោតទៅលើបញ្ហាសក់វែងនោះ?

**ឆ៖** បាទ ខ្ញុំឃើញចេញមកក៏ រ៉ុំ ហ្នឹងគាត់ហៅទៅសួរចម្លើយ។ សួរចម្លើយប្រហែលមួយសន្ទុះទៅ គាត់នាំថាទៅផ្លូវសាឡាងទៅណា ត្រើយម្ខាងកើតនេះទេ ទៅខាងកើត។ ស្រាប់តែឮស្នូរកាំភ្លើងប្រាវៗ ក៏ឃើញគាត់មកវិញ។ ថាម៉េចគេបញ្ជូនទៅហើយ? អ្ហ៎! នោះបញ្ជូនតាមទឹក! ខ្ញុំឮអ៊ីចឹងឯងមែនតែឲ្យខ្ញុំទៅផ្ទាល់អត់ទៅទេ ឮស្នូរតែកាំភ្លើងហើយគាត់មកវិញ។ មកវិញ ខ្ញុំសួរគាត់ថា គេបញ្ជូនទៅហើយ? បញ្ជូនអីនោះ បញ្ជូនតាមទឹក! អ៊ីចេះ ព្រោះមនុស្សខ្ញុំត្រង់ ដូចអត់ដឹងថាគេយកទៅវ៉ៃចោលឯណា អត់។

[១៥:២០:២២]

**ស៖** ពាក់ព័ន្ធទៅនឹងទាហានរងរបួសដែលលោកនិយាយថា គេរុញទម្លាក់ពីលើស្ពានជ្រោយចង្វានោះ តើអ្នកណាជាអ្នកសម្លាប់ទាហានទាំងអស់នោះ?

**ឆ៖** ខាងថ្មើរជើងនេះ ខ្ញុំអត់ស្គាល់មុខគេទេ ខ្ញុំឈរមើលពីចម្ងាយ ពួកថ្មើរជើង និងកងកាំភ្លើងធំ។

**ស៖** សូមអរគុណចំពោះការឆ្លើយរបស់លោកនេះ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅលើសំណួរផ្សេងទៀត <ពាក់ព័ន្ធនឹងការងាររបស់លោក។>

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ។ ខ្ញុំចង់ជម្រាបដល់អង្គជំនុំជម្រះផងដែរអំពីសេចក្តីសម្រេចមួយ។ ខ្ញុំសួរសំណួរប៉ុន្តែគេជំទាស់ គឺខ្ញុំរកឃើញ គឺសំណួររបស់សហមេធាវីនាំមុខនៅថ្ងៃ០៣ កុម្ភៈ ឆ្នាំ២០១៦ អំពីហេតុការណ៍ដែលកើតឡើងនៅថ្ងៃ១៧ មេសា, ១៨ មេសា ហើយលោកប្រធានបាននិយាយដូចតទៅនេះ៖

"សហមេធាវីនាំមុខ តាមពិតទៅសំណួរហ្នឹងអាចពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង០០២/០១ ដែលបានបញ្ចប់រួចទៅហើយ។ ដូច្នេះនៅក្នុងសវនាការនេះ យើងមានវិសាលភាពផ្សេងនៅក្នុងសំណុំរឿង០០២/០២។ ដូច្នេះវាជាអាចជាការចំណាយពេលវេលាឥតប្រយោជន៍ យើងអនុញ្ញាតឲ្យមានការសួរសំណួរតែមួយចំនួនប៉ុណ្ណោះ <ដែលអនុញ្ញាតឲ្យសួរ ដែលស្ថិតនៅក្នុងដែនវិសាលភាព។ ដូចអ្វីដែលអ្នកបានសង្កេតឃើញហើយ គឺមានការជំទាស់ជាច្រើនពីភាគីផ្សេងៗ ពាក់ព័ន្ធនឹង>សំណួរដែលស្ថិតនៅក្រៅវិសាលភាពនៃ<សំណុំរឿង>នេះ"។ នៅពេលនោះ គឺថាព្រះរាជអាជ្ញា<មួយរូប> អត់បានចូលរួមទេ ប៉ុន្តែគឺព្រះរាជអាជ្ញា វាំងសង់ ដែលជាអ្នកចូលរួម <ហើយដូចខ្ញុំនិយាយគឺ ពាក់ព័ន្ធនឹងកងពល ១៦៤>។ ដូច្នេះខ្ញុំគិតថាលោកប្រធាន ហោចណាស់ក៏យើងគួរតែឲ្យមានសង្គតិភាពនៅក្នុងការ<ចេញសេចក្ដីសម្រេច>។

[១៥:២២:៤៧]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំនឹងសួរលោកទៅលើរយៈពេលដែលលោកស្នាក់នៅធ្វើជានីរសាររបស់ ហុន។ តើក្រោយថ្ងៃ១៧ មេសា ៧៥ ប្រហែលជាប៉ុន្មានដែរ ដែលគេចាត់តាំងឲ្យលោកទៅធ្វើជានីរសាររបស់ ហុន?

**លោក សែម អ៊ំ៖**

**ឆ៖** ដល់ខ្ញុំធ្វើនីរសារនោះ យូរណាស់ហើយ តាំងពីខ្ញុំចូលបក្ស ចូលធ្វើទាហានបានមួយខែ ពីរខែ ក៏គេឲ្យមកវ៉ៃផ្លូវជាតិលេខ៦។ វ៉ៃផ្លូវជាតិលេខ៦មក គាត់ហៅខ្ញុំធ្វើនីរសារជាប់រហូតមក។

**ស៖** អ៊ីចឹងបានន័យថា លោកធ្វើការងារជានីរសាររបស់ ហុន តាំងពីមុនថ្ងៃ១៧ មេសា ៧៥ អ៊ីចឹងមែនទេ?

**ឆ៖** បាទ តាំងពីនោះហើយមក។ តាំងពីមុន៧៥ តាំងពីនៅវ៉ៃទាហាន លន់ នល់ តាំងពីនោះជាប់។

**ស៖** ក្រោយ១៧ មេសា ៧៥ នៅពេលដែលកងពល៣១០បង្កើតឡើង ហើយនៅពេលដែលលោកមានវត្តមាននៅភ្នំពេញនោះ តើមន្ទីររបស់ ហុន ហ្នឹងនៅកន្លែងណាដែរ?

[១៥:២៤:៣១]

**ឆ៖** មន្ទីររបស់ តាហុន គាត់នៅវត្តភ្នំ នៅទល់មុខអាឃោសនា។ ដល់ពេលគាត់រៀបប្រពន្ធ ការ

ប្រពន្ធរួច គាត់មកនៅជ្រោយចង្វាដែរ នៅជ្រោយចង្វាបានយូរគ្រាន់ដែរ ប្រហែលជាពីរបីខែ បានគាត់ខ្ញុំបែកពីគាត់ គេឱ្យខ្ញុំទៅនៅកប៉ាល់ស្រូវ។ គាត់នៅជ្រោយចង្វានោះឯង ខ្ញុំទៅនៅកប៉ាល់ស្រូវវិញ។ ទៅតែខ្ញុំមួយទេ មួយកងនោះទាំងអស់ គេដកខ្ញុំម្នាក់។ ខ្ញុំទៅនៅកប៉ាល់ស្រូវម្នាក់ឯងជាមួយកងគេ វរៈ១៣។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ជូនដល់សាក្សីនូវឯកសារមួយគឺ E3/1585 គឺជាបញ្ជីអ្នកចូលរួមនៅវគ្គសិក្សា<សេនាធិការ> ខែតុលា ៧៦។ ហើយខ្ញុំប្រគល់ជូនពីរសន្លឹក ដែលមានអ្នកចូលរួមមកពីកងពល៣១០ គឺខ្មែរមានលេខ 00095533 ដល់34, អង់គ្លេសមានលេខ 00897650, បារាំងមានលេខ 00611637។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះជូនលោកសាក្សី!

[១៥:២៦:៤៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នេះគឺជាបញ្ជីកម្មាភិបាលជាន់ខ្ពស់នៅក្នុងកងពល៣១០ ដែលចូលរួមនៅក្នុងវគ្គរៀនសូត្រសេនាធិការនៅ<ខែ>តុលា ៧៦។ ហើយខ្ញុំបានគូសពណ៌នៅលើឈ្មោះហ្នឹង គឺសមមិត្តហន ដែលបញ្ជាក់ថា ជាសមាជិកមន្ទីរកងពល៣១០។ ហើយគាត់គឺមានឈ្មោះទី៣ គឺនៅពីក្រោយមេកងពល អឿន ហើយនិងអនុប្រធានមួយទៀត។ ហ្នឹងគឺអនុប្រធាន វឿន។ តើ ហុន ហ្នឹងគឺ តាហុន ដែលលោកធ្វើការជាមួយ គឺលោកជានីរសាររបស់គាត់ហ្នឹង តើមែនទេ? <តើគាត់គឺជាសមាជិកម្នាក់នៅក្នុងមន្ទីរកងពល៣១០ ឬ?>

**លោក សែម អ៊ំ៖**

**ឆ៖** បាទ ខ្ញុំជានីរសាររបស់ តាហុន។

**ស៖** សូមលោកមើលទៅលើទំព័រទី២ លេខ២៦ នៅក្នុងបញ្ជីដែលនេះ គឺសមមិត្ត <សុង> ដែលបញ្ជាក់ថា ជាមេបញ្ជាការកងវរសេនាធំ១៣។ តើលោកចាំឈ្មោះ <សុង> នេះទេ? <តើមានពេលណាមួយ ដែល ហុន ត្រូវបានគេដំឡើងឋានៈដែរឬទេ?>

**ឆ៖** ស៊ឹម? បើ សុន អត់ដឹងបានឮទេ អត់ដែលឮ។

**ស៖** ខ្ញុំចង់សួរលោកអ៊ីចេះ តើលោកចាំថា ហុន ហ្នឹងនេះ តាហុន ហ្នឹងក្រោយមកត្រូវបានគេដំឡើង<ឋាន:ពី>មេបញ្ជាការកងវរសេនាធំ១៣ <ទៅជាសមាជិកមន្ទីរកងពល> ដែរឬទេ?

**ឆ៖** បាទ តាហុន នោះគាត់កងវរសេនាធំ១៣ តែគាត់អនុកងពល អនុកងពលផង។ អានោះខ្ញុំដឹងស្រពេចស្រពិលដែរ គាត់ -- ខ្ញុំជិតបែកពីគាត់ហើយ។ គាត់អត់មានជិតស្និទ្ធដូចមុនទេ មុនទៅណាគាត់នាំខ្ញុំទេ ដល់គាត់រៀបការរួចទៅ ខ្ញុំឃ្លាតពីគាត់ហើយ បែកពីគាត់។

[១៥:២៩:៣០]

**ស៖** នៅពេលលោកនិយាយ សមមិត្តហុន នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ <E3/5149, ខ្មែរមានលេខ 00170634,> អង់គ្លេសមានលេខ 00205044, បារាំងមានលេខ <00524398>។ លោកបាននិយាយថា "ចំពោះ ហុន គាត់ត្រូវបានគេចោទថា ជនក្បត់"។ តើលោកដឹងដោយរបៀបណាថា ហុន ហ្នឹងត្រូវបានគេចោទថាជនក្បត់? ហើយលោកដឹងនៅពេលណា?

**ឆ៖** បាទ កាលនោះ សភាពការណ៍ច្របូកច្របល់ បាញ់គ្រប់កន្លែង សម្លាប់ឯង សម្លាប់អញ។ ដល់គាត់ដឹងខ្លួន ខ្ញុំឮគាត់ថា គាត់ដឹងខ្លួន គាត់ទៅមើលស្រែទៅក៏គាត់ជិះម៉ូតូបុកឡានស្លាប់ ឡានឈប់។ តាមខ្ញុំដឹង ប្រហែលជាផុតពីនោះមកក៏ចាប់គ្មានសល់ ម៉ែមួយម៉ែពីរ ម៉ែមួយម៉ែពីរត្រឹមនោះឯង រហូត។ បានខ្ញុំដឹងថា អ៎! ផែនការគាត់គេចោទថា ក្បត់ហើយបានគាត់សម្លាប់ខ្លួនគាត់មុននោះ។ តាមការពិតឡាននៅគីឡូលេខ៦នេះ ឡានឈប់ទេ មិនមែនឡានបើកអីណា គាត់បើកទៅបំបុកបាក់កស្លាប់។ អាហ្នឹងបានខ្ញុំដឹង។

**ស៖** អ្នកណាប្រាប់លោកថា ហុន បានស្លាប់ខ្លួនឯង ដោយជិះម៉ូតូទៅបុកឡានដែលចតនៅមួយកន្លែងស្លាប់ហ្នឹង អ្នកណាប្រាប់លោក?

**ឆ៖** អត់មានអ្នកណាប្រាប់ទេ ប៉ុន្តែខ្ញុំសង្ស័យគាត់ទេ។ ខ្ញុំសង្ស័យតែគាត់ ប្រហែលជាៗគេចោទពីរឿងអីៗហើយ ព្រោះសភាពការណ៍ច្របូកច្របល់ គេចាប់អីលិច ចាប់អីកើត ខ្លះបាញ់ខ្លួនឯងក៏មាន ហើយក៏មានពួកវរសេនាតូច វរសេនាធំ បានខ្ញុំសង្ស័យគាត់អ៊ីចុះឯង បានខ្ញុំលើកឡើង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីលោក ខៀវ សំផន!

[១៥:៣២:១៥]

**លោក គង់ សំអុន៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ទៅលើឈ្មោះ ដែលមាននៅក្នុងឯកសារជាភាសាខ្មែរ។ តាមការបង្ហាញរបស់សហព្រះរាជអាជ្ញារង ឯកសារ E3/1585នេះ ក្នុងលេខរៀងទី៣ គឺមានឈ្មោះថា ហាន់ ជាភាសាខ្មែរ មិនមានឈ្មោះ ហុន ទេ។ ដូច្នេះខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាអាចធ្វើការបញ្ជាក់ចំណុចនេះ ឬក៏ធ្វើការកែតម្រូវ។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

ខ្ញុំព្យាយាមកែតម្រូវអំណានរបស់ខ្ញុំ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** មេធាវីការពារក្តី នួន ជា បានសួររួចមកហើយអំពីឈ្មោះនេះ។ មូលហេតុដែលខ្ញុំសួរលោកអំពីរឿងរ៉ាវរបស់បុគ្គលម្នាក់ហ្នឹង ដែលបើកម៉ូតូទៅបុកឡានចតមួយកន្លែងនេះ <គឺដោយសារ> សមាជិកកងពលឈ្មោះ ហាន់ <នេះ>មាន<នៅក្នុង>បញ្ជីឈ្មោះចូលមកស-២១។

លោកប្រធានខ្ញុំក៏សូមផ្តល់បញ្ជីនេះទៅឲ្យ<សាក្សី គឺមាន>ឯកសារ<ចំនួនពីរ> ទី១គឺ<E3/9843>, ទី២ E3/2285 សូមការអនុញ្ញាត ដើម្បីផ្តល់ឯកសារទាំងពីរឲ្យសាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

សូមមន្ត្រីរដ្ឋបាលតុលាការយកឯកសារហ្នឹង ជូនសាក្សី!

[១៥:៣៤:០៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលផ្តល់ឯកសារនេះទៅឲ្យសាក្សី ដើម្បីប្រតិចារឹក ខ្ញុំសូមបញ្ជាក់អំពីចំណុចនេះបន្តិច។ ទី១ ឈ្មោះពេញរបស់បុគ្គលម្នាក់នេះ ឈ្មោះ រស់ ផាត់ ហៅ ហាន់ ជា<>សមាជិកមន្ទីរនៃកងពល៣១០។ មានលេខ<៧៨៣៥> នៅ<ក្នុងបញ្ជី ស-២១ ដែលចងក្រងដោយការិយាល័យ>សហចៅក្រមស៊ើបអង្កេត ហើយបានចូលមក ស-២១ នៅថ្ងៃទី២៥ មករា ៧៧។ ឯកសារទី១ ដែលផ្តល់ទៅឲ្យសាក្សីនោះគឺ <E3/9843>, ខ្មែរ 0101004*(ស៊ីក)* ជាផ្នែកនៃឈ្មោះអ្នកទោសដែលបានចូលទៅស-២១ នៅខែមករា ១៩៧៧ នៅថ្ងៃទី២៥ <នៃខែដដែលនេះ> ហាន់ គឺនៅលើបញ្ជីនេះគាត់មានលេខរៀង១៩។ ឯកសារទី២ដែលសុំផ្តល់ឲ្យសាក្សីនោះគឺ E3/2285 ខ្មែរ 00009199 ដល់200, អង់គ្លេស <00873411> មិនមានការបកប្រែជាភាសាបារាំងទេ។ នេះជាបញ្ជីអ្នកទោសស-២១ ដែលបានកម្ទេច

នៅថ្ងៃទី០៧ ឧសភា ៧៧ ក្នុងនោះមាន រស់ ផាត់ ហៅ ហាន់ នេះមានលេខរៀងទី៦៤ នៅលើបញ្ជីដែលកម្ទេចចោលនេះ។

លោកសាក្សីសំណួរដំបូងរបស់ខ្ញុំ ដំបូងគឺថា ខ្ញុំបានគូសជាពណ៌*ហាយឡាយ*ឲ្យលោកមើលហើយ គឺឈ្មោះអ្នកទោសដែលចូលមកស-២១ ជាសមាជិកកងពល គាត់ឈ្មោះ ហាន់។ តើ ហាន់ ម្នាក់នេះគឺជាអ្នកដែលលោកធ្វើនីរសារឲ្យគាត់ហ្នឹងឬ?

**លោក សែម អ៊ំ៖**

**ឆ៖** មិនមែនទេ។ ហាន់ ខ្ញុំអត់ស្គាល់ទេ ហាន់។ បើ ហុន ខ្ញុំស្គាល់ ព្រោះ ហុន មានពីរ ហុនមួយនៅខាងថ្មើរជើង, ហុន មួយនៅខាងកាំភ្លើងធំ។ រឿង ហាន់ នេះអត់ដឹងផង អត់ស្គាល់។

[១៥:៣៦:៥០]

**ស៖** ខ្ញុំនឹងត្រឡប់មកសួរលោកឡើងវិញ លោកបានបញ្ជាក់ថា មនុស្សដែលលោកធ្វើការឲ្យហ្នឹងគឺគាត់ឈ្មោះ ហុន ជាសមាជិកដែលមានបុណ្យស័ក្តិខ្ពស់នៅក្នុងកងពល៣១០។ អ្នកដែលលោកធ្វើជានីរសារឲ្យនេះ គឺជាមនុស្សម្នាក់ដែលមានបុណ្យស័ក្តិខ្ពស់នៅក្នុងកងពល៣១០ហ្នឹងឬ?

**ឆ៖** គាត់ក្រោមកងពលទេ ហ៊ឹម ហុន ហ្នឹង។ កាលគាត់វរសេនាធំ ពីដើមគាត់វរសេនាតូចគាត់ឡើងមកវរសេនាធំ ប្រហែលជាជិតគេចាប់ហើយ បានឡើងទៅអនុសមាជិកកងពល។

**ស៖** លោកអានឈ្មោះគាត់ពេញ គាត់ហ្នឹងឈ្មោះ ហ៊ឹម ហុន ហ្នឹងឬ?

**ឆ៖** ឈ្មោះគាត់ពេញគឺ ហ៊ឹម ហុនៗ។ ឈ្មោះអត់មានប្រែមានអីទេ ឈ្មោះគាត់អ៊ីចុះនេះ។

**ស៖** លោកប្រាកដមែនទេដែលថា បុគ្គលម្នាក់នេះបានស្លាប់ទៅហើយនៅក្នុងរបបខ្មែរក្រហមហ្នឹង?

**ឆ៖** ប្រាកដ! ស្លាប់នៅគីឡូលេខ៦ គេយកមកកប់នឹងឫស្សីកែវ អាកន្លែងដើមអូយម៉ូយ ឫស្សីកែវ។ ខ្ញុំឮគេថាទេ ខ្ញុំនៅកប់ស្រូវទេ គេអត់ឲ្យមកទេ។ ឮតែហ្លួងនីរសារគាត់ប្រាប់។

**ស៖** <ដូច្នេះ ដើម្បីឲ្យខ្ញុំយល់ច្បាស់នោះ> មូលហេតុដែលលោកជឿថាឈ្មោះ ហុន នេះបានស្លាប់ដោយសារថា នីរសាររបស់ ហុន នេះបានប្រាប់លោក ថាគាត់ស្លាប់ហើយ។ អ៊ីចឹងមែនទេ?

**ឆ៖** ញ៉ឹម នីរសារគាត់នៅ ញ៉ឹម។ ខ្ញុំទៅ គាត់ប្រាប់ខ្ញុំថា អត់ទៅសួរមេឯងមុនទេ ស្លាប់បាត់ហើយ។ ខ្ញុំទៅណា គេមិនឲ្យទៅ គាត់ស្លាប់ហើយ ស្លាប់នឹងបុកម៉ូតូ អ៊ំ!បុកឡាន គេយកមកកប់នឹងឫស្សីកែវ។ ប៉ុន្តែមិនដឹងគេកប់ត្រង់ណាទេ ឮគេថាឫស្សីកែវៗ ដឹងត្រង់ណា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៣៩:៥១]

**ស៖** តើ ហុន គាត់ស្លាប់នៅពេលណា? តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ បើប្រៀបធៀបទៅពេលវេលាដែល អឿន ដែលគេបានចាប់ខ្លួន អឿន ហ្នឹងណ៎ា តើ ហុន ហ្នឹងគាត់ស្លាប់នៅពេលណា?

**ឆ៖** ស្លាប់ ហុន នោះស្លាប់ក្រោយ អឿន ប្រហែលជាមួយខែ។

**ស៖** សូមអរគុណច្រើន។ ឥឡូវនេះខ្ញុំសួរលោកសំណួរមួយចំនួនអំពីអង្គប្រជុំដែលលោកបានលើកយកមកនិយាយរួចមកហើយ គឺអង្គប្រជុំដែលគេបានចាក់ចម្លើយសារភាពរបស់ អឿន ឲ្យស្តាប់នោះ។ នៅក្នុងអង្គប្រជុំហ្នឹង តើអ្នកណាធ្វើជាអធិបតី? អ្នកណាជាអ្នកឡើងនិយាយហ្នឹង?

**ឆ៖** កាលដែលអង្គប្រជុំនុ៎ង ឡានបរមកគាត់បើកឯកសារពីក្នុងឡានហ្នឹងឯង ចូលប្លុកមកនិយាយ នឹងក្បែរវត្តភ្នំនេះ ខាងក្រោយពេទ្យ កន្លែងពេទ្យ ប្រជុំនៅនោះឯង។ គេថា តាខៀវៗ ប៉ុន្តែមិនដឹង ខៀវ ណាទេ ខ្ញុំមិនស្គាល់ដែរ រាងខ្មៅ មាឌរាងល្អិត។ ថា ខៀវ ប៉ុណ្ណារីៗ ខ្ញុំមិនសូវស្គាល់ដែរ ខ្ញុំថាតាមគេ។

**ស៖** អ្នកដែលអធិបតីនៅក្នុងអង្គប្រជុំនោះ តើជាប្រុស ឬក៏ជាស្រី?

**ឆ៖** បាទ ប្រុសៗ។

**ស៖** តើបុរសដែលមកធ្វើអធិបតីភាពនៅក្នុងអង្គប្រជុំនោះឈ្មោះ ខៀវ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំឮគេថាឈ្មោះ ខៀវ – តាខៀវៗ។

[១៥:៤២:២៥]

**ស៖** តើយុទ្ធជនកងពល៣១០ ទៅចូលរួមប្រជុំហ្នឹងទាំងអស់មានគ្នាប៉ុន្មាននាក់?

**ឆ៖** បាទ ប្រហែលជា១.០០០នាក់។

**ស៖** បើខ្ញុំស្តាប់មិនច្រឡំទេ អង្គប្រជុំដែលមានយុទ្ធជនចូលរួម១.០០០នាក់នេះ គឺគេរៀបចំធ្វើឡើងនៅខាងក្រោយវត្តភ្នំ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះពីទីកន្លែងដែលគេរៀបចំការប្រជុំបានទេ? វារៀបរាប់អំពីបន្ទប់ ពីអគារនោះបានទេ?

**ឆ៖** បាទ កន្លែងនោះគឺដូចគ្មានអគារអីទេ។ កន្លែងដូចរោងបាយ រោងអីគេទេ ខ្ញុំ រោងធំ អារោងនៅកន្លែងនោះធំអ្វា ហើយគេដាក់ប្រក់ស័ង្កសីខ្ពស់។ កន្លែងនោះកន្លែងតែងប្រជុំ តែងរៀនអីរាប់រយរាប់ពាន់នៅកន្លែងនោះហើយ ដែលធំ។

**ស៖** តើអង្គប្រជុំហ្នឹងមានរយៈពេលប៉ុន្មានដែរ? តើគេរៀបប្រជុំហ្នឹងប៉ុន្មានម៉ោង ប្រជុំមួយថ្ងៃពេញ ឬក៏គេប្រជុំរហូតដល់ពីរបីថ្ងៃ? អ៊ីចឹងសរុបមកតើអង្គប្រជុំនោះមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** ប្រជុំនោះអត់យូរទេ មួយព្រឹក។ មួយព្រឹកគេបញ្ចប់ អត់មានផែនការអីនិយាយច្រើនទេ គេនិយាយគ្រាន់តែរៀបរាប់ពីការចាប់ប៉ុណ្ណោះឯង ក៏គេរំសាយឲ្យមកធ្វើស្រែវិញ។

**ស៖** តើលោកអាចរៀបរាប់ជូនតុលាការបានទេ ពាក់ព័ន្ធទៅនឹងការចាក់ខ្សែអាត់សំឡេងឲ្យស្ដាប់នៅក្នុងអង្គប្រជុំនោះ?

**ឆ៖** ខ្ញុំឮគេចាក់--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាល់ឆ្លើយ!

មេធាវីលោក ខៀវ សំផន សូមអញ្ជើញ!

[១៥:៤៤:៥៥]

**កញ្ញា អង់តា ហ្គីសសេ៖**

បើខ្ញុំគិតថា នៅក្នុងចម្លើយរបស់សាក្សី គាត់បាននិយាយថាគេចាក់ចម្លើយសារភាព អ៊ីចឹងបើសួរសាក្សីឲ្យនិយាយអំពីខ្លឹមសារនៃចម្លើយសារភាពនេះ ខ្ញុំសូមជំទាស់លោកប្រធាន។

**លោក ឌេល លីសាក់៖**

ការដែលសួរនេះ មិនមែនឈ្លេចសួរអំពីចម្លើយនៅក្នុងចម្លើយសារភាពនោះទេ។ <ប្រសិនបើយើងចង់ធ្វើបែបនេះ គឺយើងអាចអានចម្លើយសារភាពហ្នឹងបាន>។ គោលបំណងចង់ដឹងថាតើគេបានចាក់អ្វីឲ្យកងទ័ពកងពល៣១០ស្ដាប់? ហើយតើវាប៉ះពាល់ទៅដល់ការដឹងរបស់ពួកគាត់យ៉ាងដូចម្ដេច? ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហា ដោយសារថាមានព័ត៌មានថាគេចោទប្រកាន់យុទ្ធជនទាំងអស់នេះ ថាជាអ្នកចូលរួមនៅក្នុងគម្រោងធ្វើរដ្ឋប្រហារ។ ហើយ<ការប្រើប្រាស់ខ្សែអាត់សំឡេងនៅក្នុងកិច្ចប្រជុំហ្នឹង> គឺជាភស្តុតាងមួយស្របច្បាប់ហើយ ចំណែកខ្លឹមសារនៃចម្លើយសារភាពនោះ អាហ្នឹងជារឿងមួយផ្សេងទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

បើតាមរបៀបសំណួរដែល<រៀបចំឡើងវិញ គឺ>ថាតើលោកចាំខ្លឹមសារ<អ្វីខ្លះ>ដែលគេចាក់ឲ្យស្ដាប់នោះ? អ៊ីចឹងដូចជា<មិនឃើញថា តើគាត់>អាចជៀសផុតពីសួររឿងខ្លឹមសារនៃចម្លើយ

សារភាពហ្នឹង<ដែលត្រូវបានគេចាក់ឲ្យស្តាប់ហ្នឹង ដោយរបៀបណាទេ>។ សំណួរហ្នឹងគឺចោទជាបញ្ហា ហើយ អ៊ីចឹងគួរតែសហព្រះរាជអាជ្ញារៀបចំសំណួរឡើងវិញ <ឬក៏ការពន្យល់របស់ព្រះរាជអាជ្ញាហ្នឹង មិនច្បាស់សម្រាប់ខ្ញុំ តាមអ្វីដែលខ្ញុំបានស្តាប់ឮនោះ>។

[១៥:៤៦:៤៣]

**លោក ឌេល លីសាក់៖**

ខ្ញុំផ្តល់ឧទាហរណ៍មួយជូន។ យើងបានអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពពីស-២១ ដើម្បីយកមកប្រើប្រាស់ជាភស្តុតាង ដើម្បីចង់ដឹងថាតើចម្លើយសារភាពផ្ញើជូនទៅភូមិភាគផ្សេងៗទៀតដើម្បីប្រើប្រាស់<ជាមូលដ្ឋានក្នុងការ>ចាប់មនុស្ស<>។ ហេតុផលដែលចម្លើយសារភាពដែលអាចត្រូវទទួលយកបាន គឺមិនមែនយកចម្លើយសារភាពនេះ មកស្វែងរកកាពិតទេ គ្រាន់តែចង់ដឹងថា តើចម្លើយសារភាពនេះត្រូវបានរបបនោះ យកទៅប្រើប្រាស់ដោយរបៀបណា។ <វាគឺជាអង្គហេតុមួយដ៏សំខាន់ដើម្បីស្វែងយល់។> វាមិនពាក់ព័ន្ធទៅនឹងការស្វែងរកការពិត<នៃ>ខ្លឹមសារនៅក្នុងចម្លើយសារភាព<នោះទេ គឺថា>ប្រើប្រាស់<ដើម្បីដឹងមូលហេតុនៃការសួរចម្លើយ> ការធ្វើទារុណកម្ម <ហើយ>យើងគ្រាន់តែចង់ដឹងថា តើព័ត៌មានក្នុងចម្លើយសារភាពនេះ របបនោះយកទៅប្រើប្រាស់ដោយរបៀបណា? ហើយថាតើគេប្រើប្រាស់សម្រាប់ជាការឃោសនាដោយរបៀបណា ក្នុងការផ្សព្វផ្សាយឲ្យប្រជាជនស្តាប់ដើម្បីបង្ហាញសញ្ញាណហ្នឹង បញ្ជាក់ថាការបោសសម្អាតទ្រង់ទ្រាយធំ គឺថាជាការចាំបាច់ណាស់ពីព្រោះមានផែនការធ្វើរដ្ឋប្រហារ។ អ៊ីចឹងដូចខ្ញុំលើកឡើង គឺថាខ្លឹមសារនេះមិនមែនជាការខិតខំប្រឹងប្រែងយកខ្លឹមសារដើម្បីស្វែងរកការពិតនោះទេ។ យើងគ្រាន់តែដឹងថាតើគេយកចម្លើយសារភាពទៅប្រើប្រាស់នៅក្នុងអង្គប្រជុំនោះដោយរបៀបណា?

**ប្រធានអង្គជំនុំ៖**

សូមព្រះរាជអាជ្ញាធ្វើការកែសម្រួលសំណួរនេះ។

[១៥:៤៨:២៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំមិនចង់ឲ្យលោកប្រាប់មកខ្ញុំថា លោកស្តាប់ឮសួរពីខ្លឹមសារអ្វីពីខ្សែអាត់នោះទេ យើងខ្ញុំគ្រាន់តែចង់ដឹងថា <ប៉ុន្តែលោកអាចរៀបរាប់ប្រាប់យើងជាទូទៅថា តើមានរឿងអ្វីកើតឡើង>នៅពេលដែលឈ្មោះ ខៀវ នេះចាក់ខ្សែអាត់សំឡេងចម្លើយសារភាពនេះ<>?

01375251



**លោក សែម អំ៖**

**ឆ៖** ខ្ញុំឮតែគេចាក់ផ្សាយពីគាត់សារភាព ច្រវាក់ក្រោកក្រាកៗហ្នឹង ខ្ញុំបានឆ្លើយលើកមុនហើយតើ។ គាត់ចាក់មែន ខ្ញុំក៏បានថា ម៉ែឪឯងស្លាប់ហើយ គេចាប់អស់ហើយ អ្អែងកុំហៅ កុំគិតគូរពីម៉ែឪអ្អែងទៀត អ្អែងទៅវិញទៅ ធ្វើស្រែធ្វើភ្លឺណោះ។ ចាប់ពីពេលនោះទៅ ខាងភូមិភាគឧត្តរមានសិទ្ធិសេរីភាពឯណា អត់ទេ! មានតែខាងនិរតីទេ គេក្តោបក្តាប់ជាប់ ក៏ខាងខ្ញុំ ខាងភូមិភាគឧត្តរសុទ្ធតែយុទ្ធជននៅក្រោមគេទាំងអស់ អត់មានអ្នកណាមានត្រឹមប្រធានក្រុមប្រធានអី អត់មានទេ។

**ស៖** ខ្ញុំសូមអានសម្រង់មួយពីចម្លើយឆ្លើយជូនសហចៅក្រមស៊ើបអង្កេតទៅលើបញ្ហានេះ គឺឯកសារ E3/5149, ខ្មែរ 00170634, អង់គ្លេស 00205044, បារាំង 00524398។ នេះគឺជាអ្វីដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត៖ "នៅក្នុងពេលប្រជុំដែលមានយុទ្ធជនចូលរួមប្រហែល ១.០០០នាក់នៅភ្នំពេញ តាខៀវ បានប្រកាសថា ម៉ែឪរបស់ពួកឯងត្រូវបានគេសម្លាប់ចោលអស់ហើយ។ ហើយបន្ទាប់មកបានគេចាក់ខ្សែអាត់សំឡេង តាអឿន។ ខ្ញុំឮសូរសំឡេងច្រវាក់ ហើយឮសូរសំឡេង តាអឿន និយាយរៀបរាប់អំពីប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ នៅពេលដែលគាត់ក្បត់បក្ស។" បញ្ចប់ការដកស្រង់ចំណុចមួយសុំឱ្យលោកជួយបញ្ជាក់ លោកបានលើកឡើងពីរដងហើយនៅថ្ងៃនេះថា "ម៉ែឪរបស់ពួកឯងហ្នឹងគឺគេសម្លាប់ចោលអស់ហើយ" តើនេះគឺជាពាក្យសម្តីចេញពីមាត់របស់ ខៀវ ឬក៏ជាពាក្យសម្តីដែលលោកស្តាប់ឮចេញពីខ្សែអាត់?

[១៥:៥១:២២]

**ឆ៖** បាទ ចេញពី មុនដំបូងគេអត់ទាន់ចាក់ខ្សែអាត់ទេ គេនិយាយក្បាលមីក្រូ។ គេប្រាប់ "ឯងស្តាប់មើលទៅមើល ចាំស្តាប់" ដល់គេនិយាយរួច ក៏គេថា ប្រាប់ថា "ម៉ែឪឯងគេសម្លាប់អស់ហើយ"។ ខ្ញុំធ្លាក់ថ្លើមក្តុកទៅ។ ខ្ញុំថា ចាំស្តាប់គេ ស្តាប់គេ ៗចាក់ខ្សែអាត់ក្រោយ បានឮច្រវាក់ក្រោកក្រាកៗហ្នឹងហើយ មែន។ ចេញពីមាត់គាត់ផ្ទាល់តើ គាត់និយាយ ប្រាប់ថាម៉ែឪឯងគេសម្លាប់អស់ហើយ។ ហើយដល់ចាក់ តាអឿន នោះអត់ទាន់ស្តាប់ណា នៅច្រវាក់ក្រោកក្រាកៗ។ បានតាំងពីនោះមក ក៏ពួកនិរតីក្តាប់ទាំងអស់ អត់មានពួកឧត្តរទេ។

**ស៖** នៅពេល តាខៀវ ចាក់ខ្សែអាត់សំឡេងចម្លើយសារភាពរបស់ តាអឿន តើ ខៀវ មានប្រាប់លោក និងយុទ្ធជនដទៃទៀតថា អឿន នេះត្រូវបានគេធ្វើទារុណកម្ម ត្រូវបានគេវាយដំដែរឬទេ ដើម្បីទទួលបានចម្លើយនុ៎ង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គេអត់មាននិយាយថា គេធ្វើបាបម៉េចម៉ាទេ ប៉ុន្តែឮសូរតែច្រវាក់ គេធ្វើបាបហើយ គេដាក់ច្រវាក់ហើយ។ តែរឿងគេវ៉ៃ គេតប់ អត់ដឹងទេ។

**ស៖** តើលោកដឹងទេថា ហេតុអ្វីបានជា តាខៀវ ចាក់ខ្សែអាត់សំឡេងហ្នឹងឲ្យលោក និងយុទ្ធជនមកពីកងពលរបស់លោកហ្នឹងស្ដាប់?

[១៥:៥៣:២១]

**ឆ៖** គេចង់ឲ្យយើងស្ដាប់ កុំឲ្យយើងធ្វើតម្រាប់តាម កុំឲ្យយើងផុសអ្វីមួយ តស៊ូជំនួសម៉េឌីអីអត់ គេអត់ឲ្យមាន។ អ៊ីចឹងហើយគេឲ្យស្ដាប់ទៅ ឲ្យយើងស្ដាប់។ ហើយគេអត់ឲ្យមានយុទ្ធជនណាមានធំមានអីទេ ខាងភូមិភាគឧត្តរនោះ។ គេបំបិទសិទ្ធិហើយ។ គេប្រើម៉្ងៗ ធ្វើស្រែនៅបឹងបាយ៉ាប។

**ស៖** នៅក្នុងអង្គប្រជុំដែលគេចាក់ខ្សែអាត់សំឡេងនេះ តើអង្គប្រជុំនេះគេរៀបចំធ្វើឡើងរយៈពេលប៉ុន្មានថ្ងៃក្រោយ តាអឿន ត្រូវបានគេចាប់ខ្លួន? លោកចាំដែរ ក្រោយពេលគេចាប់ខ្លួន តាអឿនហើយ តើគេរៀបចំបើកអង្គប្រជុំនេះរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានសប្ដាហ៍ដែរ <ប៉ុន្មានខែដែរ> ក្រោយការចាប់ខ្លួននោះ?

**ឆ៖** បាទ អត់យូរទេ។ ប្រហែលជាបួនប្រាំថ្ងៃ បួនប្រាំថ្ងៃគេចាប់ហែអស់រលីង។ អស់រលីងទៅនៅតែពួកខ្ញុំយុទ្ធជន ឡិងឡង់ៗ អត់ដឹងទេ ដែលគេហៅទៅរៀននេះ អត់ដឹងថាគេចាប់ទេ។ ស្រាប់តែគេហៅទៅរៀនអស់ហើយ។ សួរ ម៉េច គេទៅណាអស់ហើយ? ទៅរៀន។ គេមិនមែនប្រាប់ថាចាប់ ប្រាប់ថាអីទេ ថាទៅរៀន ក៏ចាំតែទៅមើលគេទៅរៀន មិនឃើញមកវិញទៅរៀននោះ ទៅរៀនបួនដប់ថ្ងៃ អត់ឃើញ អាខ្លះទៅរៀនដល់កន្លះខែ អត់មានឃើញពីណាមកវិញមួយសោះ។ បាត់ទៅ ក៏ចាំតែមើលទេ ចាំតែមើល ស្រាប់ដល់ឃើញគេហៅ ខ្ញុំ យុទ្ធជនខ្លះដែលសេសសល់ឲ្យទៅរៀន ទៅភ្នំពេញក៏ខ្ញុំទៅៗ។ ភ័យដែរ ដឹងគេទៅធ្វើអី ប៉ុន្តែភ័យម៉េចកើត បើគេហើយ ចេះតែទៅ។ នៅសុទ្ធតែយុទ្ធជនទេ អត់ទាន់មានអីទេ។ អត់មានកម្មាភិបាលនៅសល់ម្នាក់មួយណា។

[១៥:៥៥:៥១]

**ស៖** ហើយលោកបានឆ្លើយថា ក្រោយពេលស្ដាប់ខ្សែអាត់នៅអង្គប្រជុំនោះរួចមក គឺគេឲ្យលោកទៅធ្វើស្រែ។ ដំបូងឡើយឲ្យធ្វើស្រែនៅកប់ស្រូវ ហើយក្រោយមកទៅធ្វើស្រែនៅបឹងបាយ៉ាប។ តើចាប់ពីពេលប្រជុំរហូតមកដល់ គេបញ្ជូនលោកមកឲ្យធ្វើស្រែនៅកប់ស្រូវ និងបឹងបាយ៉ាបហ្នឹង គឺថាវាមានរយៈពេលគម្លាតពីគ្នាប៉ុន្មានដែរ?

**ឆ៖** បាទ ខ្ញុំធ្វើស្រែហ្នឹងយូរដែរ ប្រហែលជា៣ខែ បីបួនខែ បានគេហៅខ្ញុំឲ្យទៅនៅភ្នំពេញ។ ទៅនោះ អត់ដឹងទេ អត់ដឹងគេហៅទៅអីទេ គេហៅតែខ្ញុំមួយ ខ្ញុំអត់ដឹងផែនការអីទេ។ ស្អីក៏គេមិនឲ្យយកទៅ ត្រឹមតារ៉ុងអី គេឲ្យពាក់តែមួកមួយ អាវមួយខោមួយ បាឡូបាអី គេអត់ឲ្យយកទៅទេ។ ខ្ញុំស្មានតែគេយកខ្ញុំទៅសម្លាប់ហើយ ខ្ញុំទៅ។ ខ្ញុំទៅ ក៏នៅអីហ្នឹង មន្ទីរកងពល មន្ទីរកងពលថ្មី នៅក៏ខ្ញុំអត់ស្គាល់គេ គេមិនឮថាអី។ ខ្ញុំនៅ៣ថ្ងៃ ៣ថ្ងៃបានគេហៅឲ្យខ្ញុំទៅរៀនកាន់តេអូហ្នឹងឯង។ ខ្ញុំរៀនបានប្រហែល១០ថ្ងៃ ក៏គេបញ្ជូនខ្ញុំទៅវៀតណាម ប៉ុណ្ណោះឯង។

**ស៖** សូមអរគុណច្រើន អ្វីដែលលោករៀបរាប់ហ្នឹង <គឺកើតឡើង>ក្រោយពេលដែលលោកចេញពីបឹងបាយ៉ាបទៅ ត្រឹមត្រូវដែរទេ?

[១៥:៥៧:៥២]

**ឆ៖** បាទ ខ្ញុំចេញពីបឹងបាយ៉ាបទៅ ខ្ញុំទៅនៅកន្លែងកងពលរៀនតេអូសិន។ រៀនតេអូបានប្រហែលជា១០ថ្ងៃ។ ១០ថ្ងៃៗនោះខ្ញុំអត់ដឹងគេបញ្ជូនទៅវៀតណាមទេ។ គេអត់ប្រាប់ អត់អីទេ កាំភ្លើងកាំផ្លាំងអី គេអត់បំពាក់ពីទីក្រុងភ្នំពេញទៅទេ។ គេឲ្យខ្ញុំទៅឡើងកប៉ាល់ ១ទឹក។ ឡើងកប៉ាល់ទឹកនោះកាលនោះគេបើកខោអាវថ្មីៗឲ្យម្នាក់ពីរកំប្លេ។ មួយកំប្លេ ពីរកំប្លេ បើកខោអាវ ក្រមា មួកឲ្យទៅខ្ញុំឡើងកប៉ាល់។ ឡើងកប៉ាល់ទៅមួយយប់ ភ្លឺឡើងដល់កំពង់ចាម ទន្លេបិទ។ ដល់ទន្លេបិទ ឡើងទៅដាំបាយហូប។ ដាំបាយហូបទៅ ក៏ខ្ញុំទៅអីមាត់ទន្លេ មាត់ទន្លេក៏ឃើញពួករបួស គេដឹកនៅកប៉ាល់ទឹកមកពីវៀត-ណាម ចូលដល់ជប់ហើយ កៅស៊ូជប់។ ខ្ញុំនៅចុងអង្គ្រង នៅភូមិចុងអង្គ្រង អ៎!ខ្ញុំនៅកំពង់ចាមសិន។ បានឃើញអ៊ីចឹង ខ្ញុំថានោះ! ទៀតហើយយើង ប្រហែលជាគេយកមកធ្វើសង្គ្រាមហើយយ៉ាង។ ក៏ខ្ញុំថាក៏ពួកមិត្តថា ខ្លះថា អ៎! ធ្វើក៏ធ្វើទៅ ឲ្យតែបានបាយស៊ីឆ្អែត ទោះបីគ្រាប់យ៉ាងណាក៏មិនខ្លាចដែរ ឲ្យតែបានបាយឆ្អែត។ ខ្ញុំក៏គេអត់ទាន់បំពាក់កាំភ្លើងបំពាក់អីទេកងទ័ពនោះ។ បានគេដាក់ឡាន ដាក់ឡានទៅក៏គេទៅបើកកាំភ្លើងឲ្យសមរភូមិណោះ កន្លែងភូមិចុងអង្គ្រងនេះ។ កាលនោះវៀតណាមនៅនឹងចម្ការកៅស៊ូ ពួកខ្ញុំនៅកន្លែងចុងអង្គ្រង ដាក់ខ្សែត្រៀមអីនោះឯង។ ដាក់ខ្សែត្រៀមអីនោះឯង បានផ្លោង៨០ចូលទៅ។ ផ្លោង៨០ចូលទៅ ក៏ព្រឹកឡើង ខ្ញុំអត់ចេះតេអូប៉ុន្មានផង ខ្ញុំកម្រិតវប្បធម៌ក៏ខ្សោយ ក៏ឮគេមកប្រាប់ ១ថា អ៎ យួនរត់ហើយ។ រត់ហើយ ក៏នាំគ្នាឡើងឡានតាមពីក្រោយទៅ។ ទៅដល់ភូមិសិរីសុខា ក៏ខ្ញុំនៅគេឲ្យនៅចាំនៅសិរីសុខាហ្នឹង ភូមិសិរីសុខា។ បានគេដកមកជួយច្រូតស្រូវប្រជាជនឯភូមិចំបក់ជាប់មេឃ។ ចំបក់ជាប់មេឃ ខ្ញុំជួយច្រូតជួយឲ្យប្រជាជន ហាត់ទ័ពហាត់អី។ បានគេថា ហាត់៣ខែរួច

01375254



ហើយ គេឲ្យយក ខ្ញុំយកទ័ពមួយក្រុមទៅពង្រឹង ឲ្យយកខ្ទូសេតមួយដើម ៨២មួយដើម ពីរក្រុម ហើយនិងពួកថ្មើរជើង គេមានមេគេក្តាប់។ ដល់ទៅក៏ទៅវ៉ៃវៀតណាម ទៅវ៉ៃម៉េចដាច់ បើគេខ្លាំងដែរ ឯងទើបក្រោកពីស៊ីបបរ ទៅវ៉ៃនៅជិតផ្សារក្រដាស បន្ទាយថាសនេះ។ ទៅវ៉ៃនៅនុំងឯង។ វ៉ៃគេៗវ៉ៃបកមកវិញខ្ញុំដាច់បាយរាប់ខែ ស៊ី ដើររើសផ្លឹងត្រីស៊ី អត់មានបាយគេយកទៅឲ្យ វាឆ្ងាយ វានៅឆ្ងាយ។ បានប្រហែលជាកន្លះខែបានគេយកបាយទៅឲ្យ អង្ករទៅឲ្យហូប ក៏ខ្ញុំនៅជាប់របួត។ ជាប់រ៉្លាជាប់ៗ អត់បានមកក្រោយនឹងគេ ជាប់ៗចេះតែបញ្ជូនទ័ពទៅ ទ័ពទៅ ក៏នៅៗ ឃ្លាតតែខ្ញុំ វៀតណាមវ៉ៃចូលមក ក៏ខ្ញុំរត់ទៅសំដៅអ្នកលឿង។ ទៅអ្នកលឿង គេវ៉ៃគ្នាអ្នកលឿង រត់មកឯក្រូចឆ្មារវិញ អ៊ំ!ក្រូចគួរ អ៊ំ!ក្រូច -- អ៊ំ! ភូមិពោធិ៍ មកឆ្លងទន្លេនឹងភូមិពោធិ៍។ ឆ្លងភូមិពោធិ៍ គេឲ្យខ្ញុំទៅវ៉ៃ ខ្ញុំចូលផ្ទះប្រជាជន ខ្ញុំសារភាព ប្រគល់អាវុធប្រគល់ឲ្យគេ គេអូឲ្យគេ ក៏ស្អែកឡើងខ្ញុំរត់មកផ្ទះ នឹកម៉ែរកតែម្តាយ។ តាំងពីទៅមក មិនដែលបានឃើញម៉ែឪតែបន្តិច រត់មក គេចប់ត្រឹមណោះ។

[១៦:០២:៥៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២១ ខែកញ្ញា ឆ្នាំ២០១៦ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែកអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី សែម អំ បន្តបញ្ចប់ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-1036 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមវេលាកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញ នៅថ្ងៃទីពុធ ទី២១ ខែកញ្ញា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*